01501720 E1/298.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jun-2017, 11:02
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី២៧៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ម៉ាទីន ខារ៉ុបគីន

*(Judge Martin KAROPKIN)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ារី-ជេនី សាដាទិ

*(Ms. Marie-Jeannes SARDACHTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជៀន

*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក ឯក ហឿន (2-TCW-822) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឯក ហឿន ហៅ អុល ហឿន** (2-TCW-822)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ទំព័រ ៦
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី ........................................ទំព័រ ១០
សួរដោយលោកស្រី ទីស្រ៊ីនណា ផ្ដើមពី ........................................ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

មានបញ្ហាបកប្រែភាសា?

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះកំណត់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW៩822 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបង។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោកស្រី ម៉ារី ហ្គ័រ្វ៉ដ៍ មេធាវីនាំមុខអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអវត្តមាននៅសវនាការថ្ងៃនេះ និងថ្ងៃស្អែក ដោយមូលហេតុលោកស្រីមានធុរៈផ្ទាល់ខ្លួន។ ប៉ុន្តែលោកស្រី បានផ្ទេរសិទ្ធិជូនលោក វ៉ែន ពៅ ដែលជាមេធាវីនាំមុខបម្រុង។ ហើយលោក វ៉ិចទ័រ កូប៉េ មេធាវី អន្តរជាតិ ការពារក្តីឲ្យលោក នួន ជា អវត្តមានដោយមូលហេតុផ្ទាល់ខ្លួនផងដែរ នៅសវនាការថ្ងៃនេះ និងថ្ងៃស្អែក។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះគឺសាក្សី ដែលមានរហស្សនាម 2-TCW-822។ សាក្សីរូបនេះនឹងផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបង។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីរ រូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយកាលពីព្រឹកមិញនេះ មុននឹងផ្តល់សក្ខីកម្ម ហើយសាក្សីក៏មិនមានមេធាវីប្រឹក្សាផងដែរ។ សូមអរគុណលោកប្រធាន។

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[០៩:១០:១៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលៗរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិ និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនលោក នួន ជា មានអាការៈវិលមុខ ធឹងធោង ឈឺចង្កេះខ្លាំងពេលអង្គុយយូរ និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:១១:៣៨]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំគ្រាន់តែចង់លើកយកបញ្ហាខ្លីតូចមួយមកជម្រាបជូនអង្គជំនុំជម្រះ<មុនពេលយើងចាប់ផ្តើមសួរសាក្សី>។ ខ្ញុំដឹងថាលោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកស្រីចៅក្រមបានបញ្ជាក់<ហើយ>ថា នៅពេលបន្តិចទៀតនេះនឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ទាក់ទងទៅនឹង<ការប្រើប្រាស់>ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្មនៅក្នុង<ការជំនុំជម្រះ>នេះ។ ខ្ញុំគិតថានេះគឺជាបញ្ហាដែលសំខាន់បំផុតសម្រាប់តុលាការនេះ <ក៏ដូចជាការជំនុំជម្រះនេះដែរ ដោយ>ការធ្វើទារុណកម្ម<ជាសកម្មភាពស្នូលរបស់ពួកខ្មែរក្រហម ហើយឯកសារភស្តុតាងនេះក៏មានសារ>សំខាន់ផងដែរសម្រាប់យុត្តិសាស្ត្រអន្តរជាតិ<។> ទោះបីថាយើងធ្លាប់ដាក់<ឯកសារ>កាលពីពេលកន្លងមក<ក៏ដោយ ក៏វាមានរយៈពេលយូរដែរហើយ> ហើយយើងបានលើកឡើងថា<តុលាការអាចទទួលផលប្រយោជន៍តាមរយៈការស្តាប់ពីភាគីលើបញ្ហានេះ។ ជាសំណើផ្ទាល់របស់ខ្ញុំ ខ្ញុំសូម>ឲ្យមានសវនាការជាផ្ទាល់មាត់ជាមួយភាគីប្រហែលជាមួយម៉ោង ឬមួយម៉ោងកន្លះ ឬក៏អាចថាអង្គជំនុំជម្រះអាចជ្រើសការទទួលជាលាយលក្ខណ៍អក្សរវិញនោះ ប៉ុន្តែយ៉ាងណាក៏ដោយដើម្បីជាប្រយោជន៍ដល់សាធារណជន គួរតែមានសវនាការជាផ្ទាល់មាត់។ ខ្ញុំគិតថាយើងអាចធ្វើនៅថ្ងៃនេះបាន ប៉ុន្តែ<ខ្ញុំឃើញថា>ដោយសារតែភាគីភាគច្រើនមិនមានវត្តមាននៅទីនេះ ដូច្នេះ ខ្ញុំ<ផ្តល់យោបល់ថា យើងគួរលើកមកពិភាក្សាក្រោយពេលសម្រាក។ មានហេតុផលមួយចំនួនដែលខ្ញុំគិតថាវាគួរតែបន្តទៅមុខទៀត។ ជាបឋម គឺថាបញ្ហាហ្នឹងត្រូវបានលើកយកនិយាយនៅក្នុងតុលាការនេះ កាលពីសប្តាហ៍មុន បញ្ហានេះត្រូវបានក្រុមមេធាវី នួន ជា លើកមកឡើងពីរបីដងរួចមកហើយ ដោយ>ពួកគេបានដាក់នូវមូលដ្ឋានមួយនៃ<បណ្តឹង>សាទុក្ខលើកសំណុំរឿង០០២/០១ ដែលថាជាសំណើ ឬក៏ជាញត្តិសុំឲ្យទទួលយកភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម។ <វាមិនត្រឹមត្រូវនោះទេ។>

[០៩:១៤:០៧]

នៅក្នុង<សារណាបណ្តឹងសាទុក្ខដែលមានមូលដ្ឋាន២៧៧របស់ខ្លួន> គេមិនដែលបានលើកយកចំណុចនេះមកធ្វើជាមូលដ្ឋាននៃបណ្តឹងសាទុក្ខ<នោះទេ> ហើយក៏មិនមែន<ស្នើសុំកែប្រែសារណានៃ>សាទុក្ខ<របស់ខ្លួន>ដែរ។ <វាត្រឹមត្រូវហើយ ដែលពួកគេបានដាក់សារណាជាលាយលក្ខណ៍អក្សរលើបញ្ហានេះ>។ ខាងព្រះរាជអាជ្ញាមិនបានឆ្លើយតប<ទេ> ដោយសារតែវាមិនមែនជាមូលដ្ឋាននៃការប្តឹងសាទុក្ខ ហើយដោយសារតែទំព័រដែលយើងអាចដាក់គឺមានការកម្រិតកំណត់ <យើងបានឆ្លើយតបតែទៅនឹងអ្វីដែលជាមូលដ្ឋាននៃបណ្តឹងសាទុក្ខចេញពីសារណារបស់ភាគី>។<ទន្ទឹមនឹងនេះ> ខ្ញុំ<ក៏បានកត់សម្គាល់ដែរ ថាបញ្ហានេះក៏ត្រូវបានលើកឡើងជាច្រើនដងដែរជាមួយនឹងសាក្សី>ក្នុងរយៈពេលប៉ុន្មានសប្តាហ៍កន្លងមកនេះ ប៉ុន្តែខ្ញុំសុំលើកឡើងថាបញ្ហាទាំងអស់ ឬក៏សំណួរទាំងអស់ដែលបានសាកសួរ គឺជា

សំណួរដែលមិនត្រឹមត្រូវព្រោះថាវាមិនពាក់ព័ន្ធ។ ឧទាហរណ៍ដូចជាការសួរសាក្សីថា "តើលោកស្គាល់ ជូ ជេត <តាម>ចម្លើយសារភាពរបស់គាត់<នៅស-២១ ដែលបាន>ឆ្លើយដាក់អ្នកឬក៏អត់?" គឺវាអត់ពាក់ព័ន្ធ<ទាល់តែសោះ>។ តើវាមានប្រយោជន៍អ្វីដែលថាសាក្សីគាត់ដឹង ឬក៏មិនដឹងនោះ? ប្រសិនបើមេធាវីការពារក្តីចង់<សួរសាក្សីថា "តើលោក>ជា សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ ឬក៏<ជាគិញយូន>អី<ជាដើម?" គេអាចសួរសំណួរនេះបាន ហើយសាក្សីអាចឆ្លើយតប។> ប៉ុន្តែវាមិនមានហេតុផលអ្វី<នៅពេលហ្នឹង>ដែលយើងលើកយកបញ្ហានៃចម្លើយសារភាពដែលព្រះរាជអាជ្ញានៅតែបន្តលើឡើងថាមេធាវីការពារក្តីមិនអាចប្រើប្រាស់បានដើម្បីបង្ហាញពីការពិតនោះឡើយ ព្រោះប្រសិនបើធ្វើដូច្នេះ គឺវាមិនអាចជឿទុកចិត្តបាន ទី១។ ទី២ វាជាការជំរុញឲ្យមានការធ្វើទារុណកម្ម ហើយនិងអ្នកដែលទទួលខុសត្រូវក្នុងការធ្វើទារុណកម្ម <ដោយ>ប្រើប្រាស់ចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្មដើម្បីធ្វើយុត្តិកម្ម ទៅលើការធ្វើទារុណកម្ម <និង>ការ<កាប់>សម្លាប់<ដែលខ្លួនប្រព្រឹត្ត>។ ដូច្នេះ ខ្ញុំ<ស្នើថា យើងត្រូវមានសវនាការដោយផ្ទាល់មាត់លើបញ្ហានេះ ក្រោយសម្រាក ប្រសិនណា> អង្គជំនុំជម្រះ<ចង់បានជាសារណាជាលាយលក្ខណ៍អក្សរក៏បានដែរ>។

[០៩:១៦:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៨:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

*(គ្មានការបកប្រែ)*

*(មានបញ្ហាបច្ចេកទេស)*

[០៩:១៩:០៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ តាំងសំណួរសាជាថ្មី ព្រោះអំមិញគឺមានបញ្ហាបកប្រែភាសា។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមសួរទៅសហព្រះរាជអាជ្ញាអន្តរជាតិ ថាលោកត្រូវការពេលវេលាប៉ុន្មាន សម្រាប់ចំណាយពេលទៅលើបញ្ហាពាក់ព័ន្ធទៅនឹងការប្រើប្រាស់ភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម? នេះជាសំណួរទី១។ សំណួរទី២ តើលោកគ្រាន់តែចង់បានការពិភាក្សាគ្នានៅក្នុងសវនាការ ឬក៏លោកចង់មានលទ្ធភាពដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ? ដូច្នេះ ប្រសិនបើបញ្ហា<រសើប>នោះ គឺថាយើងអាចដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរហើយ យើងអាចពិភាក្សាគ្នាជាផ្ទាល់មាត់ទៀត។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកចៅក្រម។ ខ្ញុំគិតថាប្រហែលជាយើងត្រូវការពេលមួយ<ម៉ោង ឬមួយ>វគ្គជាសវនាការសាធារណៈ ហើយក៏យើង<គិតថា បើសិនវាមានប្រយោជន៍នោះ យើង>អាចដាក់ជាសារណាជាលាយលក្ខណ៍អក្សរផងដែរ<។ ខ្ញុំសូមពន្យល់បន្តិចអំពី>បញ្ហាស្មុគស្មាញ<នេះ។ នេះជាគោលជំហររបស់សហ>ព្រះរាជអាជ្ញា<ដោយ>គិតថា<មានការប្រើប្រាស់ជាច្រើនមកហើយអំពីចម្លើយសារភាពទាំងនេះ ដែលចម្លើយសារភាពទាំងនេះត្រូវបានទទួលយករួចហើយ ជាពិសេសគឺប្រឆាំងនឹងអ្នកដែលធ្វើទារុណកម្ម។ ហើយលើសពីនេះ មានសំណួរដែលរសើប ខ្ញុំគិតថា ជាសំណួរដែលស្មុគស្មាញ តើនៅពេលណាដែល>អង្គជំនុំជម្រះ<កំណត់>ថា <កំណត់ហេតុចម្លើយមួយបានមកពីការ> ការធ្វើទារុណកម្ម ហើយយើង<ចង់ដាក់ស្នើចំពោះបញ្ហាហ្នឹង ហើយអ្វីខ្លះជា>ផលវិបាក។

[០៩:២១:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំជម្រះក៏យល់ឃើញថា បញ្ហានេះវាមានចរិតលក្ខណៈពិបាក ហើយនិងសំខាន់ដែរ អ៊ីចឹងហើយបានជាពាក់ព័ន្ធជាមួយនឹងការឆ្លើយតបទៅនឹងមានការប៉ុនប៉ងក្នុងការតាំងសំណួររបស់មេធាវី វ៉ិចទ័រ កូប៉េ ហ្នឹងគឺយើងបានអូសបន្លាយពេលវេលាយ៉ាងច្រើន ហើយជជែកគ្នាលើបញ្ហានេះច្រើន ហើយក៏មានគំនិតច្រើនដែរលើបញ្ហានេះ។ ប្រសិនបើមានបែបផែនសំណើសុំរបស់លោកសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំពិភាក្សាដើម្បីស្ដាប់មតិរបស់ភាគីនោះ គឺអង្គជំនុំជម្រះនឹងពិនិត្យពិចារណាលើបញ្ហានេះនាពេលក្រោយ។ ហើយជម្រាបជូនភាគីជ្រាបលើបញ្ហានេះ។ ហើយអរគុណអរគុណណាស់លោកព្រះរាជអាជ្ញាអន្តរជាតិ ដែលបានលើកឡើងនូវបញ្ហានេះ ហើយមានការចាប់អារម្មណ៍ខ្លាំង។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីសាក្សី! តើលោកស្តាប់យើងបានទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ ស្តាប់បាន។

**ស៖** បាទ អរគុណ។ តើលោកឈ្មោះអ្វី?

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ ឯក ហឿន។

**ស៖** ម្តងទៀត ស្តាប់អត់ច្បាស់ទេ លោកឈ្មោះអ្វី?

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ ឯក ហឿន។

**ស៖** ឯក ធឿន អ៊ីចឹងអ្អេស៎?

**ឆ៖** បាទ

**ស៖** ចុះអ្នកណាឈ្មោះ អ៊ុល ហឿន?

**ឆ៖** ហ្នឹង គេដាក់ជីតា អ៊ុល – អ៊ុល ហ្នឹងជីតា។ ឯក ហ្នឹង គឺឪពុក។

**ស៖** ឥឡូវហ្នឹងលោកប្រើប្រាស់ឈ្មោះអ្វីដែលពិតប្រាកដសព្វថ្ងៃនេះ? ប្រើផ្លូវការ?

**ឆ៖** បាទ សព្វថ្ងៃដែលឈ្មោះពិតប្រាកដ គឺគេដាក់ ឯក ហឿន។ ហើយបើគេចេះតែចុះស្មានគេអត់សួរខ្ញុំ គេដាក់ជីតា អ៊ុល ហឿន។ ឈ្មោះវាគ្រាន់តែស្មួនគ្នា ប៉ុន្តែឈ្មោះតែមួយទេ។

[០៩:២៣:៤០]

**ស៖** បាទ អរគុណ។ អ៊ីចឹងយើងប្រើឈ្មោះ ឯក ហឿន ព្រោះលោកបានប្រើប្រាស់ ឯក ហឿន ជាឈ្មោះផ្លូវការ។ ហើយលោក ឯក ហឿន តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** បាទ នៅជំនាន់នោះខ្ញុំអត់ចាំទេ កើតមកឃើញតែសង្គ្រាមជំនាន់ឥស្សរៈ អត់ដែលដឹងប្រតិទិនអី អត់ដឹងទាំងអស់។

**ស៖** បាទ អរគុណ។ ចុះសព្វថ្ងៃនេះលោកអាយុប៉ុន្មាន?

**ឆ៖** ៧៨ហើយ។

**ស៖** បាទ អរគុណ។ ហើយលោក ឯក ហឿន តើលោកមានទីកន្លែងកំណើតនៅកន្លែងណា?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ កន្លែងកំណើតពីក្មេងនៅខេត្តតាកែវ ស្រុកត្រាំកក់ ឃុំត្រពាំង

ធំខាងត្បូង ភូមិត្រពាំងប្រីយ៍។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្ន លោករស់នៅទីកន្លែងណា?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ សព្វថ្ងៃរស់នៅខេត្តបាត់ដំបង ស្រុកសំឡូត ឃុំតាសាញ ភូមិតាសាញ។

**ស៖** បាទ អរគុណ។ ហើយលោក ឯក ហឿន ប្រកបមុខរបរធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** បាទ ចាស់ជរាហើយ ធ្វើអីលែងកើតអស់ហើយ។ កូនចៅគេធ្វើស្រែ ធ្វើចម្ការ។

**ស៖** បាទ អរគុណ។ តើឪពុកបង្កើតលោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** បាទ ឪពុកខ្ញុំឈ្មោះ អ៊ុល ឯក។ ម្ដាយឈ្មោះ ណាំ ហាង។ ម្ដាយជាជនជាតិយួននៅក្របៅមាត់ជ្រូក។ ឪពុកមានងារការនយោបាយជំនាន់សម្ដេចសង្គមរាស្ត្រនិយម។

[០៩:២៥:៥៦]

**ស៖** បាទ អរគុណលោក ឯក ហឿន។ ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ប្រពន្ធខ្ញុំឈ្មោះ ជា នី។ មានកូនប្រាំមួយនាក់៖ ១) ឈ្មោះ ឯក ភួន, ២) ឈ្មោះ ឯក ឃឿន, ៣) ឈ្មោះ ឯក វឿន, ៤) ឈ្មោះ ឯក វ៉ន, ៥) ឈ្មោះ ឯក នៅ, ៦) ឈ្មោះ ឯក ណន។ ប៉ុន្តែស្លាប់បាត់មួយហើយ។

**ស៖** បាទ អរគុណលោក ឯក ហឿន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ អម្បាញ់-មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹងគឺថា លោកមិនមានឪពុកម្ដាយបុព្វញាតិ ឬបច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃប្រពន្ធ ត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២ទេ។ តើជាការពិតដែរឬទេ?

**ឆ៖** អត់ពិតទេ។

[០៩:២៧:០៥]

**លោក ម៉ម រិទ្ធា៖**

លោកឮច្បាស់ទេ? ឮយល់ទេសំណួរលោកចៅក្រម?

**លោក ឯក ហឿន៖**

អត់ច្បាស់ទេ។

**លោក ម៉ម រិទ្ធា៖**

សុំលោកចៅក្រមម្ដងទៀត។

**លោក ឯក ហឿន៖**

បាទ អត់ទោស សុំមានប្រសាសន៍ម្ដងទៀត ស្ដាប់អត់ច្បាស់។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តាមសមត្ថភាពដែលលោក ហឿន ដឹងហ្នឹង តើលោកអាចដឹងបានទេថាលោកហ្នឹងមិនមានឪពុកម្ដាយ បុព្វញាតិ ឬបច្ឆាញាតិ កូន បងប្អូនប្រុសស្រី បងប្អូនថ្លៃ ឬក៏ប្រពន្ធរបស់លោកត្រូវបានទទួលយកជាភាគីនៃរឿងក្ដីក្នុងរឿង០០២ នេះទេ។ តើពិតមែនដែរទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ ពិតមែនហើយ។

**ស៖** ហើយថាលោកបានស្បថរួចហើយ មុននឹងលោកផ្ដល់សក្ខីកម្មនាពេលនេះ។ តើពិតដែរទេ?

**ឆ៖** បាទ ស្បថពេលនេះរួចហើយ។

**ស៖** តទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោក ហឿន ជាសាក្សី។ អំពីសិទ្ធិលោក ឯក ហឿន ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការឱ្យធ្វើអំណះអំណាងណាមួយជាច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឱ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ចលោក អ៊ុល ហឿន ក្នុងនាមលោកជាសាក្សីត្រូវផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឱ្យចម្លើយតបរបស់លោក ឬការអះអាងរបស់លោកនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ក្នុងនាមលោកជាសាក្សី ត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរទេ?

**ឆ៖** បាទ យល់។

[០៩:២៩:៤១]

**ស៖** អរគុណ លោក ហឿន។ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជាដែរឬទេ ក្នុងរយៈពេលកន្លងមក?

**ឆ៖** បាទ បានសម្ភាសពីរលើក ប៉ុនវាអត់ចាំថ្ងៃចាំខែទេ គាត់មកសម្ភាសពីរលើក។

**ស៖** បាទ អរគុណ ហើយមុននឹងលោក មុនពេលនេះ តើលោកបានអាន និងបានពិនិត្យមើលកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មលើកមុនដែរឬទេ ដើម្បីរំឭកការចងចាំ?

**ឆ៖** បាទ បានអានរួចហើយ អស់សព្វគ្រប់ហើយ។

**ស៖** លោកកត់សម្គាល់ឃើញយ៉ាងម៉េចដែរអំពីខ្លឹមសារនៃកំណត់ហេតុដែលលោកបានអានដើម្បីរំឭកការចងចាំនោះ តើវាសមស្របទៅនឹងខ្លឹមសារនៃអ្វីដែលលោកបានផ្ដល់សក្ខីកម្មដល់អ្នកស៊ើបអង្កេតកាលពីលើកមុនដែរឬទេ?

**ឆ៖** បាទ វាសមស្របតាមមជ្ឈមណ្ឌលស្រាវជ្រាវ លើក ពីរលើកហ្នឹង វាចាំខ្លះ ប៉ុន្តែវាទាស់ថាសរសេរមិនត្រូវតាមតួអក្សរ ចេះតែខុស វាខុសត្រង់ហ្នឹង។

[០៩:៣១:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ឯក ហឿន មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថាភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ ហើយសូមបញ្ជាក់សហព្រះរាជអាជ្ញា រួមទាំងភាគីដទៃទៀតសូមជ្រាបថាលោក អ៊ុល ហឿន គាត់មានបញ្ហាសុខភាព ហេតុដូច្នេះសូមឲ្យមានការរៀបចំនូវសំណួរឲ្យបានខ្លីៗ ច្បាស់លាស់ ហើយសួរសំណួរសាមញ្ញៗទៅដើម្បីឲ្យគាត់ស្ដាប់បាន ហើយអាចឆ្លើយតបបានល្អប្រសើរ។ សង្ឃឹមថាភាគីយល់បញ្ហានេះ ហើយនិងអនុវត្តបានល្អ។

បាទ ជាបន្តនេះសូមផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមជម្រាបសួរភាគីទាំងអស់។

[០៩:៣២:២២]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វាំងសង់ ដេវីល។ ខ្ញុំចោទសំណួរលោកតាំងនាមឱ្យការិយាល័យសហព្រះរាជអាជ្ញានៅព្រឹកនេះ និងរសៀលនេះ។ ជាដំបូង ខ្ញុំសូមអរគុណដែលលោកបានព្រម<មកបង្ហាញខ្លួន>ឆ្លើយទៅនឹងសំណួររបស់យើងខ្ញុំ ទោះបីជាលោកមានសុខភាពទន់ខ្សោយក៏ដោយ។ នៅពេលដែលខ្ញុំសួរសំណួរមិនច្បាស់នោះសូមលោកប្រាប់ខ្ញុំឱ្យខ្ញុំសួរឡើងវិញ ដើម្បីឱ្យលោកយល់សំណួរឱ្យបានច្បាស់។ ប្រសិនបើលោកមិនដឹងចម្លើយទេ សូមលោកកុំស្មាន<>។ លោកគ្រាន់តែប្រាប់ខ្ញុំមកថាលោកមិនដឹងទេ។ ខ្ញុំនឹងសួរសំណួរដំបូងខ្លះៗពាក់ព័ន្ធទៅនឹងក្រុមគ្រួសាររបស់លោកដើម្បីឱ្យដឹងថាតើលោកមានដើមកំណើតមកពីទីណា។

លោកបាននិយាយមុននេះថាម្តាយរបស់លោកជាជនជាតិវៀតណាមនៅកម្ពុជាក្រោម។ ប្រសិនបើខ្ញុំយល់មិនច្រឡំទេលោកបានឆ្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកកម្ពុជា។ យើងមានឯកសារ E305/13.23.451។ ខ្ញុំសូមផ្តល់លេខ ERN ជាភាសាខ្មែរគឺ 00968886, ជាភាសាបារាំង 01053707, ជាភាសាអង់គ្លេសគឺ 01050180។ លោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដូចតទៅ។ ខ្ញុំសូមដកស្រង់៖ “ជីដូនខ្ញុំមកពីវៀតណាម ប៉ុន្តែម្តាយខ្ញុំកើតនៅកម្ពុជា។ ជីតារបស់ខ្ញុំមិននិយាយខ្មែរទេ ហើយបានរៀបការជាមួយនឹងយាយរបស់ខ្ញុំដែលនិយាយខ្មែរ មិនមែនវៀតណាមទេ។ ជីតាខ្ញុំជាវៀតណាម ដើមកំណើតនៅច្វរដុក គឺមកពីខេត្តក្របៅ មាត់ជ្រូក វៀតណាម”។ តើពិតជាត្រឹមត្រូវទេថានេះគឺជាដើមកំណើតរបស់ម្តាយរបស់លោក គឺអ៊ីចឹងមែន?

លោកសាក្សី លោកស្តាប់ខ្ញុំឮទេ? ខ្ញុំសួរលោកអម្បាញ់មិញនេះថា ការអានរបស់ខ្ញុំ អម្បាញ់មិញនេះ គឺត្រឹមត្រូវទេ? គឺយាយរបស់លោកគឺមកពីវៀតណាម ហើយម្តាយរបស់លោកកើតនៅស្រុកខ្មែរ ជីតារបស់លោកហ្នឹងគឺថា គាត់ជាជនជាតិវៀតណាមតែម្តង។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:៣៥:៥០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោករៀបរាប់ថា ម្ដាយរបស់លោកជាជនជាតិវៀតណាម<មកពី>កម្ពុជាក្រោម។ តើលោកអាចជួយពន្យល់បានទេថា នៅពេលដែលលោកនិយាយថាខ្មែរក្រោមនេះ លោកសំដៅទៅលើអ្វី? ពីព្រោះថា ជួនកាលមានការយល់ច្រឡំគ្នារវាងជនជាតិវៀតណាមដែលនៅកម្ពុជាក្រោម ដែលមិនចេះភាសាខ្មែរ ឬក៏មានមួយទៀតគឺ ខ្មែរដែលនៅកម្ពុជាក្រោម ក៏ប៉ុន្តែគាត់មានភាសាកំណើតជាភាសាខ្មែរ។ អ៊ីចឹងលោកអាចបែងចែកឲ្យបានច្បាស់ទេថា <រវាងខ្មែរក្រោម, ជនជាតិវៀតណាម និងវៀតណាមទៅពីប្រទេសកម្ពុជា និងផ្សេងទៀតជាដើម>?

**ឆ៖** បាទ ត្រង់ហ្នឹងវាមិនច្បាស់លាស់ទេ ព្រោះតាខ្ញុំឈ្មោះ តាណាំ ហ្នឹងគាត់មកនៅកម្ពុជា គាត់អត់ចេះខ្មែរទេ មិនដឹងថាគាត់ខ្មែរកម្ពុជា ឬវៀតណាមអត់ដឹងច្បាស់ទេ។ ដឹងតែគាត់និយាយតែភាសាវៀតណាម ហើយយាយខ្ញុំក៏ចេះភាសាវៀតណាមតិចៗដែរ។ ហើយដល់កូនគាត់ ឈ្មោះ--ម៉ែខ្ញុំនេះក៏ ម៉ែខ្ញុំចេះតិចតួចដែរហ្នឹង និយាយភាសាយួនហ្នឹង អត់ចេះជ្រៅជ្រះទេ។ បើចង់ដឹង មានប្អូនគាត់មួយកើតនៅក្របៅមាត់ជ្រូកដែរហ្នឹង គាត់យកមកបកប្រែឲ្យគាត់ស្ដាប់។ ពេលសែនចិន សែនយួនអីគាត់យកប្អូនគាត់មកបកប្រែឲ្យស្ដាប់។ ត្រង់នេះខ្ញុំសន្និដ្ឋានថា វាអត់ច្បាស់ដែរ ខ្ញុំវាអត់បានទៅដល់ក្របៅមាត់ជ្រូកហ្នឹងផង។ ឃើញតែគាត់មកនៅជាតា ជាយាយ ក្នុងស្រុក ក្នុងភូមិ។

[០៩:៣៧:៤៧]

**ស៖** លោកក៏បានឆ្លើយនៅក្នុងកំណត់ហេតុ<នៃការស្ដាប់ចម្លើយ>របស់លោក <លើកទី១> គឺ <E319.1.31 នៅត្រង់>ចម្លើយទី១១។ លោកថា៖ "ដោយសារតែឪពុករបស់លោកហ្នឹងជាមេភូមិនៅសម័យសង្គមរាស្ត្រនិយម ហើយដោយសារតែម្ដាយខ្ញុំជាជនជាតិវៀតណាមនោះ គេចង់បោសសម្អាតគ្រួសារខ្ញុំ។" សូមបញ្ចប់ការដកស្រង់។ នៅចម្លើយទី១៦ នៃឯកសារដដែល លោកឆ្លើយថាលោកបានចូលរួមបដិវត្តក៏ប៉ុន្តែគ្រួសាររបស់លោកហ្នឹង គឺគេចោទថាមាននិន្នាការនយោបាយ។ អ៊ីចឹងដោយសារតែម្ដាយរបស់លោកជាជនវៀតណាម ហើយឪពុករបស់លោកមានតួនាទីនៅក្នុងរបបមុនហ្នឹងហើយបានជាគេចោទថាលោកហ្នឹងមាននិន្នាការនយោបាយ អ៊ីចឹងមែនទេ? លោកអាចពន្យល់បានទេថាអ្នកដែល "ជាប់និន្នាការ" ហ្នឹងមានន័យថាម៉េច? លោកចង់មានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** បាទ អត់ច្បាស់ទេ សូមមានប្រសាសន៍ម្ដងទៀត។

**ស៖** ខ្ញុំនឹងសួរឲ្យស្រួល។ លោកនិយាយថា ឪពុករបស់លោកជាមេភូមិនៅសម័យសង្គមរាស្ត្រនិយម គឺសម័យសម្ដេចសីហនុ។ ហើយម្ដាយរបស់លោកជាជនជាតិវៀតណាម។ អ៊ីចឹងហើយបានជា

គេចង់បោសសម្អាតគ្រួសាររបស់លោកដោយសារតែលោកមាននិន្នាការ ជាប់និន្នាការ។ អ៊ីចឹង <តើខ្មែរក្រហម>ថា គ្រួសាររបស់លោកហ្នឹងមានជាប់និន្នាការហ្នឹងដោយសារតែឪពុកលោកជាមេភូមិ ហើយដោយសារម្ដាយរបស់លោកហ្នឹងជាជនជាតិវៀតណាម។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនហើយច្បាស់ណាស់។

**ស៖** ពាក់ព័ន្ធនឹងក្រុមគ្រួសាររបស់លោកដដែល តើលោកអាចជម្រាបបានទេ ថាលោកមានជាប់សាច់ឈាមអីជាមួយនឹងតាជឹម ដែលជាអនុ<ប្រធាន>ស្រុកកាលនៅឆ្នាំ១៩៧៥ នោះ? <តើលោកមានជាប់សាច់ឈាមអីទេ?>

[០៩:៤០:៣៥]

**ឆ៖** បាទ ប្រពន្ធគាត់ជាប់សាច់ញាតិជាចិន គឺម្ដាយប្រពន្ធខ្ញុំហ្នឹងជាចៅចិន ហើយឪពុកជាខ្មែរ បាទត្រង់ហ្នឹងវា បានខ្ញុំថាជនជាតិចិន។ អាហ្នឹងសូមអស់តែប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំនឹងសួរម្ដងទៀត ប្រហែលជាលោកស្ដាប់សំណួរខ្ញុំមិន<ច្បាស់>។ ខ្ញុំនិយាយអំពីទំនាក់ទំនងសាច់ញាតិរបស់លោកជាមួយ តាជឹម ដែលជាអនុប្រធានស្រុកត្រាំកក់នៅឆ្នាំ១៩៧៥ គាត់ឈ្មោះពេញគាត់ហ្នឹង គឺ ពេជ្រ ជឹម។ តើលោកមានទំនាក់ទំនងសាច់ញាតិអីជាមួយគាត់ទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ តាជឹម ត្រូវជាបងប្អូនជីដូនមួយផង ត្រូវជាបងថ្លៃផង បាទ។

**ស៖** សូមអរគុណ។ ចុះ <សោម> ដន ហៅ ដន នៅមន្ទីរស្រុកជាបងប្អូនជីដូនមួយរបស់លោកដែរឬទេ?

**ឆ៖** បាទ ពិតណាស់។

**ស៖** <តើលោកអាចប្រាប់មុខងាររបស់បងប្អូនប្រុសពីរនាក់របស់លោក ដែលអ្នកទីមួយឈ្មោះហេង> ដែលលោកហៅថាមេទាហាន<ដ៏ខ្លាំងរបស់>ខ្មែរក្រហម?

**ឆ៖** បាទ តាផែន ឆ្នាំ១៩៧៦ គាត់មកឡើងធ្វើជាចៅហ្វាយខេត្តជំនួស តាសោម បានដឹងតែប៉ុណ្ណឹងទេ។

**ស៖** លោកមិនច្រឡំជាមួយនឹង បងយ៉ាវ<(*ស៊ីក*)>ទេឬ? លោកបានឆ្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់ –យ៉ាវ– ហ្នឹងជំនួសតាសោម<នៅកោះអណ្ដែត>។ អ៊ីចឹងតើលោកអាចច្រឡំគ្នាទេជាមួយ យ៉ាវ ជាមួយនឹង ហេង?

**ឆ៖** ដឹងថាម៉េច។ អត់ច្បាស់ទេ សូមមានប្រសាសន៍ម្ដងទៀត។ អន់ត្រចៀក ស្ដាប់អត់ច្បាស់។

[០៩:៤៣:៣៣]

**ស៖** ខ្ញុំនឹងរំឭកអ្វីដែលលោកបានឆ្លើយ។ លោកបាននិយាយថាលោកមានបងពីរនាក់ គឺលោកឆ្លើយនៅមជ្ឈមណ្ឌលឯកសារកម្ពុជាថាមានបងម្នាក់ឈ្មោះ ហេង ដែលលោកថាជាមេទាហានដ៏ខ្លាំងរបស់ខ្មែរក្រហម ហើយស្លាប់នៅឆ្នាំ១៩៧៣។ លោកមានបងប្រុសម្នាក់ទៀតឈ្មោះ យ៉ាវ ដែលជាអនុប្រធានស្រុកកោះអណ្តែតពីឆ្នាំ១៩៧៧ ឬក៏៧៨។ អ៊ីចឹងតើចំណុចហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ គាត់--

**ប្រធានអង្គជំនុំ៖**

កុំអាលៗឆ្លើយលោក ហឿន។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមលោកប្រធានឲ្យតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិបញ្ជាក់អំពីអត្តសញ្ញាណឯកសារដែលលោកដកស្រង់ផង ឈ្មោះ ហេង ហើយនិងឈ្មោះ យ៉ាវ ហ្នឹងនៅត្រង់កន្លែងណានៃឯកសាររបស់ ឌី.ស៊ី.ខេម ព្រោះយើងអត់មាន។ បាទ សូមអរគុណ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ លោកត្រឹមត្រូវហើយ គឺឯកសារហ្នឹង គឺ E305/13.23.451, ERN ជាភាសាបារាំងគឺ 01053714, ជាភាសាខ្មែរ 00968891 គឺនៅចុងទំព័រ <និង>ជាភាសាអង់គ្លេស 01050184។ លោកសាក្សីដោយសារតែលោកមានសាច់ឈាមជាមួយ តាជឹម, សោម ដន ហើយនិងដោយសារតែបងៗរបស់លោកមានតួនាទីនៅក្នុងរបបខ្មែរក្រហម តើលោកមានទទួលបានការការពារទេទោះបីជាលោកមាន ជាប់និន្នាការក៏ដោយ ក៏លោកមានការការពារដែរ ដោយសារតែបងប្អូនរបស់លោកហ្នឹង គឺថាមានតួនាទីក្នុងរបបខ្មែរក្រហម។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍។ ចំពោះបងទាំងពីរហ្នឹង ឈ្មោះបងហេងហ្នឹង គាត់ស្លាប់ឆ្នាំ៧៣។ បើ តាយ៉េវ គាត់នៅខាង នៅស្រុកឆ្ងាយអត់បានមកទាក់ទងគ្នាដល់ទេ។ មានតែ តាជឹម ទេដែលជួយសង្គ្រោះខ្ញុំរួចពី យាយខុម រកសម្លាប់ហ្នឹង។ មានតែ តាជឹម ដែលសាច់ថ្លៃហ្នឹងគេជួយម្តង បានរួចខ្លួន។

[០៩:៤៧:០០]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកចាំអំពីអ្វីដែលលោកបានធ្វើនៅចន្លោះឆ្នាំ៧៤ ទៅដល់

ឆ្នាំ៧៥ តើលោកមានតួនាទីអ្វីនៅក្នុងភូមិ ឬក៏នៅក្នុងសហករណ៍ដែរទេ នៅសម័យនោះ គឺពី ៧៤ ដល់ ៧៥?

**ឆ៖** បាទ កាលនោះគេចាត់តាំងឲ្យខ្ញុំធ្វើប្រធានក្រុម ដល់តែគេបែងចែកវណ្ណៈទៅ គេថាខ្ញុំត្រូវកង់ប្រវត្តិសាស្ត្រកិន។ អ៊ីចឹងៗគេចាត់តាំងកម្លាំងគេថ្មីទៀត គេដកខ្ញុំចេញទៅវិញទៅ បាទ។

**ស៖** តើ តាជឹម មានធ្លាប់ជួយលោកឲ្យមានកាន់តួនាទីនៅក្នុង<>ស្រុកត្រាំកក់ទេ?

**ឆ៖** បាទ គាត់ – យាយខុម គាត់រករឿងសម្លាប់ខ្ញុំ តាជឹម យកទៅលាក់ក្នុងអង្គភាពស្រុក ឲ្យខ្ញុំនៅក្នុងមន្ទីរហ្នឹង សម្រាប់ដាក់អង្ករ ដាក់អំបិលចេញពីឡាន។ តែប៉ុណ្ណឹងទេ ជួយតែប៉ុណ្ណឹង។

[០៩:៤៨:២៦]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរសំណួរពាក់ព័ន្ធនឹងកាលបរិច្ឆេទជាក់លាក់ដែលលោកចូលទៅមន្ទីរស្រុក។ នៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅទំព័រជាភាសាខ្មែរ 00968888, ជាភាសាបារាំង 01053710, ជាភាសាអង់គ្លេស 01050182។ គេសួរលោកថា៖ "តើលោកជាអនុភូមិរហូតដល់ពេលណា?" លោកឆ្លើយថា៖ "ខ្ញុំធ្វើជាអនុភូមិហ្នឹងដល់ឆ្នាំ៧៥ នៅពេលដែលប្រទេសទាំងមូលត្រូវបានរំដោះ។ ពេលនោះគេឲ្យខ្ញុំធ្វើការនៅមន្ទីរស្រុក" (ចុះក្រោមបន្តិចមក) "គេតាំងខ្ញុំនៅថ្ងៃរំដោះនោះតែម្តង"។ សូមបញ្ចប់ការដកស្រង់។ តើលោកចាប់ផ្តើមធ្វើការនៅមន្ទីរស្រុកគឺថានៅចំថ្ងៃរំដោះ<ទីក្រុងភ្នំពេញ ឬ តាកែវ>តែម្តង គឺនៅខែមេសា ឆ្នាំ១៩៧៥ មែនទេ?

**ឆ៖** បាទ លុះថ្ងៃសង្គ្រាមចប់នៅថ្ងៃ នៅៗៗខែមេសាហ្នឹង គឺតាជឹម គេយកខ្ញុំពីផ្ទះមក ឲ្យមកនៅក្នុងៗចាំផ្ទះគាត់ ហើយចាំផ្ទះហើយបានគាត់យកខ្ញុំទៅឲ្យនៅអង្គភាពមន្ទីរស្រុក។

**ស៖** សូមអរគុណ។ លោកបានឆ្លើយបញ្ជាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត បើខ្ញុំមិនច្រឡំទេ ថាលោកបានចាកចេញពីមន្ទីរស្រុក<ត្រាំកក់>គឺនៅចុងឆ្នាំ៧៨ ដើម្បីទៅ<ចូលរួមជាមួយ> ពេជ្រ ជឹម នៅ<>កំពង់ចាម។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេថា តើនៅខែណាដែលលោកបានចាកចេញពីស្រុកត្រាំកក់<>?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ខ្ញុំខ្លាច តាសឿន –ឪអាឈ្លូស– ហ្នឹងរកសម្លាប់។ អ៊ីចឹង តាម៉ុក ត្រូវការកម្លាំងប្រជាជន២០០នាក់ មកខេត្តកំពង់ចាមហ្នឹង។ ហើយខ្ញុំសុំគេមក គេអត់ឲ្យមក ដល់ពេលគេបញ្ចេះឡាន ខ្ញុំរត់ឡើងឡានហ្នឹងគេទៅ ទៅកំពង់ចាមនៅឆ្នាំ១៩៧៧ ខែ៨។ ខ្ញុំរត់ឡើងឡានទៅនៅបូព៌ាជាមួយគេទៅ។ បាទ ជម្រាបប្រសាសន៍។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥១:៣៥]

**ស៖** លោកច្បាស់ទេថានៅឆ្នាំ៧៧? ខ្ញុំគិតថានៅក្នុងចម្លើយមុនៗរបស់លោក លោកឆ្លើយ<ជាច្រើនដងហើយ>ថា ៧៨ គឺច្រើនខែមុនពេលវៀតណាមចូល ឬក៏មួយឆ្នាំ ឬក៏ប៉ុន្មានខែតិចតួចទេ លោករំឭកឡើងវិញទៅមើល៍?

**ឆ៖** បាទ ខ្ញុំចេញពីស្រុក ១៩៧៧ ខែ៨ ទៅដល់ស្រុកគេបានតែបីខែ វៀតណាមចូលស្រុក។

**ស៖** វៀតណាមចូលមកកម្ពុជា គឺដើមខែមករា ឆ្នាំ<៧៨>។ អ៊ីចឹងលោកប្រាកដទេថា គឺប៉ុន្មានខែមុនពេលដែលលោកឡើងឡានទៅកំពង់ចាមនោះ លោកប្រាកដទេ? ខ្ញុំសូមសួរឡើងវិញ <ព្រោះបកប្រែមិនច្បាស់។ ខ្ញុំនិយាយថា>វៀតណាមចូលមក គឺដើមខែមករា ៧៩ <មិនមែន ៧៨ ទេ>។ អ៊ីចឹងលោកចាកចេញប៉ុន្មានខែមុនពេលវៀតណាមវាយចូលមែនទេ?

**ឆ៖** បាទ ខ្ញុំចាកចេញពីខែ៨ ទៅដល់ខែ១២ ថ្ងៃ៣១ ម៉ោងប្រាំកន្លះល្ងាចហ្នឹង គឺយួនចូលវាយនៅមន្ទីរចាត់ការជប់ហ្នឹងហើយ ម៉ោងប្រាំកន្លះល្ងាចគេវាយ រត់ចោលស្រុកតាំងពីថ្ងៃ៣១ ខែ១២ហ្នឹងចូលព្រៃរហូត។

[០៩:៥៣:៥២]

**ស៖** សូមអរគុណ។ អ៊ីចឹងបើ<ការគណនា>ខ្ញុំ<ត្រឹមត្រូវ>គឺថាលោកចូលទៅធ្វើការនៅមន្ទីរស្រុក គឺ<ភ្លាមៗក្រោយ>ពេលវាយយកភ្នំពេញបានបន្តិច ហើយបន្ទាប់មកទៀត លោកបានចាកចេញពីមន្ទីរស្រុកទៅកំពង់ចាម ប្រហែលជានៅ -- ប្រហែលជាបីឆ្នាំកន្លះក្រោយមក។ តើលោកអាចជម្រាបបានទេថាមុខងារចុងក្រោយ របស់លោកដែលនៅមន្ទីរស្រុកត្រាំកក់ហ្នឹង គឺជាអ្វីដែរ<?> លោកបាននិយាយថាលោកចែកចាយអំបិល និងអង្ករ។ អ៊ីចឹងលោកធ្វើការងារហ្នឹងរហូតមែនទេក្នុងរយៈពេល<ជាង>បីឆ្នាំហ្នឹង? ឬក៏មុខងាររបស់លោកហ្នឹងមានផ្លាស់ប្ដូរដែរនៅក្នុងមន្ទីរស្រុកត្រាំកក់ហ្នឹង?

**ឆ៖** បាទ ទៅដល់ឆ្នាំ៧៥ហ្នឹង ដាក់អង្ករចេញពីឡាន កាយអំបិលចេញពីឡាន ៤០តោនអីកាយតែម្នាក់ហ្នឹង។ អង្ករ៣០បាវ មួយបាវ១០០គីឡូហ្នឹងក៏លើកតែម្នាក់ លីតែម្នាក់ហ្នឹងទម្លាក់មកដីហ្នឹង។ ហើយពីហ្នឹងទៅ យាយខុម រកសម្លាប់។ តាជឹម យកទៅទម្លាក់ផ្ទះគាត់ ក៏ឱ្យដើរធ្វើក្រសួងសុរិយោដីជាមួយគេហ្នឹង។ ធ្វើបានពីរឆ្នាំ ដល់៧៨ តាសឿន –ឪអាឈ្លូស– ហ្នឹងរកសម្លាប់ខ្ញុំ ខ្ញុំក៏រត់ផ្លាយមកជប់មក។ ចប់ត្រឹមហ្នឹងហើយ។

**ស៖** អ៊ីចឹង មានន័យថា ជាដំបូងគឺលោកធ្វើការសែងអំបិល សែងអង្ករ រហូតទៅដល់ពេលដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យាយខុម បានចាកចេញ អ៊ីចឹងមែនទេ? គឺលោកបានឆ្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងគឺថារហូតដល់ឆ្នាំ ៧៦។

<**ផះ** បាទ>

<**សះ**> ចុះលោកទទួលខាងសុរិយោដី ខាងបញ្ជីភូមិបាលហ្នឹងនៅក្នុងមន្ទីរហ្នឹងនៅពេលណាដែរ? ហើយរហូតទៅដល់ពេលណាដែរ?

**ផះ** បាទ ធ្វើក្រសួងសុរិយោដីហ្នឹង គ្រាន់តែលីបង្គោលឲ្យគេហ្នឹងវាពី ៧៦ ដល់ទៅ ៧៨ ខែ៨ បានខ្ញុំរត់ចោលការងារហ្នឹងទៅតាម តាជឹម នៅស្រុកគេហ្នឹង។ ធ្វើបីឆ្នាំងនោះ គ្រាន់តែធ្វើក្រសួងសុរិយោដីហ្នឹងចូលបីឆ្នាំហើយ។

[០៩:៥៦:៤១]

**សះ** ខ្ញុំចង់អាននូវចម្លើយរបស់លោក<ម្តងទៀត>នៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាភាសាខ្មែរគឺ <00968897>, ជាភាសាបារាំងគឺ 01053719, ជាភាអង់គ្លេស 01050188។ លោកបានឆ្លើយដូចតទៅ ខ្ញុំសុំដកស្រង់៖ "ខ្ញុំក្លាយទៅជាសមាជិកពិតប្រាកដទទួលបន្ទុកខាងបញ្ជី១០០<ហ្នឹងចាប់ពីឆ្នាំ១៩៧៦>"។ បន្ទាប់មកទៀតលោក ឆ្លើយថា៖ "<>រហូតទៅដល់ឆ្នាំ១៩៧៨ ខ្ញុំទៅចម្ការកៅស៊ូជប់"។ នៅពេលដែលលោក និយាយថា លោកធ្វើជាសមាជិកហ្នឹង តើលោកចង់និយាយថាលោកជាសមាជិកផ្លូវការតែម្តង<នៅមន្ទីរស្រុកហ្នឹង> ឬគ្រាន់តែជាបុគ្គលិកដែលធ្វើការខាងបញ្ជី១០០ហ្នឹង?

**ផះ** បាទ អត់មានកាន់បញ្ជី១០០ អី អត់ដែលកាន់ទេ គឺធ្វើតែកម្លាំងសុទ្ធតែម្តង។

**សះ** តើលោកអាចដឹងទេពីព្រោះថា លោកធ្វើការនៅមន្ទីរស្រុក។ អ៊ីចឹងលោកដឹងថាតើមន្ទីរស្រុកមានតួនាទីអ្វីខាងសេដ្ឋកិច្ច និងខាងពាណិជ្ជកម្មនៅសម័យនោះ?

**ផះ** បាទ សុំមានប្រសាសន៍ កាលជំនាន់ពី៧៥ ដល់ ៧៦ ហ្នឹង ចិនផ្តល់អង្ករមកហូបចុកអីគ្រប់សព្វទាំងអស់ ហើយខ្ញុំគេយកទៅឲ្យដាក់អង្ករចេញពីឡាន ដែលដឹកមកពីខេត្ត។ ពេលដែលអង្ករមកដល់ខេត្ត តាម៉ុក ចែកគ្រប់ខេត្ត។ តាម៉ុក ជាគណៈភូមិភាគ គាត់ចែកគ្រប់ខេត្តទាំងមួយភូមិភាគនិរតីហ្នឹង។ តាម៉ុក ចែកហើយ បានថ្នាក់តំបន់ហៅឡានអង្គភាពស្រុកហ្នឹងទៅយកអង្ករមក។ យកមកដល់មានតែខ្ញុំហ្នឹងនៅមន្ទីរហ្នឹងនៅដាក់អង្ករ។ ដាក់អង្ករប្រាំឡាន ប្រាំមួយឡាន ចែកប្រជាជនថ្មីដែលគេរំដោះមក គេចែកឲ្យហូប ហើយមានតែខ្ញុំទេដើរដាក់អង្ករក្នុងឡានហ្នឹងតែម្នាក់ឯងហ្នឹង ដាក់ចង់ងាប់ចង់រស់អស់ហើយ។ ខ្ញុំសុំជម្រាប។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើមន្ទីរស្រុកហ្នឹងមានតួនាទីអ្វីពាក់ព័ន្ធនឹងផ្នែកសន្តិសុខទេ? គឺថាមន្ទីរស្រុកហ្នឹងគាត់មានកាន់ខាងកងឈ្លប <ឬកាន់>ខាង<ទ័ពស្រុក>អីទេ?

**ឆ៖** មន្ទីរស្រុកហ្នឹង គេមានមុខសញ្ញារបស់គេ ចំពោះខ្ញុំអត់មាននាទីអីទាក់ទាមជាមួយសន្តិសុខហ្នឹងទេ។

[០៩:៥៩:៥៦]

**ស៖** ខ្ញុំយល់ហើយ ខ្ញុំអត់និយាយពីលោកទេ។ ខ្ញុំដឹងថាលោកមានតួនាទីអ្វីហើយ លោកមិនពាក់ព័ន្ធខាងសន្តិសុខទេ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើនៅមន្ទីរស្រុកហ្នឹងមានផ្នែកណាមួយដែលគាត់ទទួលខុសត្រូវខាងសន្តិសុខស្រុកដែរឬទេ? ឧទាហរណ៍ ដូចជាទទួលបន្ទុកខាងឈ្លប ហើយនិងខាងទាហានស្រុក។ តើដឹងអំពីព័ត៌មានហ្នឹង ឬក៏មិនដឹងទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ទទួលការងារពីខេត្តគឺ យាយខុម ហ្នឹងហើយ។ ខេត្តដាក់មកឲ្យ យាយខុម។ យាយខុម ដាក់មកឲ្យ តាជឹម។ តាជឹម ដាក់ឲ្យតាចាយ។ តាចាយ ដាក់ឲ្យ សោម ដន ប្រធានមន្ទីរអ្នកចាត់ចែង។ រឿងហ្នឹងតែប៉ុណ្ណឹង។

**ស៖** អ៊ីចឹង លោកចង់មានន័យថា ការណែនាំ<ខាងផ្នែកសន្តិសុខ>ហ្នឹង<ជាការ>ណែនាំ<ដែល ខុម>ទទួលពីថ្នាក់ខេត្ត<មក មែនទេ>?

**ឆ៖** បាទ អត់ទទួល ពួកសន្តិសុខហ្នឹងគឺដូចថាមនុស្សដែលគេប្រគល់ គេចាប់បញ្ជូនមកដែលមាននយោបាយផ្សេងៗ ដូចថា សេ.អ៊ី.អា, ដូច កា.ហ្សេ.បេ, យួន សូវៀតអី គេផ្ញើមកឲ្យចៅហ្វាយស្រុក។ គឺយាយខុម ហ្នឹងហើយចៅហ្វាយស្រុក។ បើយាយខុម អត់នៅ គឺតាជឹម អ្នកទទួល។ ហើយតាចាយ គាត់អត់បានដឹងរឿងនយោបាយទេ គេឲ្យគាត់កាប់ចម្ការដាំតែសៀងហ្នឹង នៅតែព្រៃទេ។ ហើយសោម ដន គេអ្នកប្រធានមន្ទីរ។ ហ្នឹងនៅលើ តាជឹម ហើយយាយខុម ហ្នឹង។ តាជឹម គេមានកងស្រុកគេមួយកង។ គេសម្រាប់នាំមនុស្សដែលគេបញ្ជូនមកហ្នឹង យកទៅឲ្យយាយ ខុម។ ហើយយាយខុម គេមានកម្លាំងគេមួយក្រុមនៅការពារផ្ទះគេហ្នឹង គេសម្រាប់តែទទួលអ្នកដែលគេនាំមកហ្នឹង។ កម្លាំងយាយខុម ហ្នឹងគេអ្នកដែដល់ហើយ។ គេចាត់ចែងតាមផ្លូវការចិត្តគេទៅ។

[១០:០២:១០]

**ស៖** យើងនឹងត្រឡប់មកនិយាយអំពីចំណុចនេះវិញនៅពេលក្រោយ។ ខ្ញុំមានឈ្មោះមួយចំនួនចង់រៀបរាប់ប្រាប់លោក ដែលប្រហែលជាធ្វើការនៅក្នុងមន្ទីរស្រុកនៅផ្នែកផ្សេងៗ។ តើលោកអាច

និយាយអំពីតួនាទីរបស់ សោម ដន ដែលជាបងប្អូនជីដូនមួយរបស់លោកបានទេ? គាត់ធ្វើអីនៅមន្ទីរស្រុកហ្នឹងជាប្រចាំថ្ងៃ?

**ឆ៖** បាទ សោម ដន ជាប្អូនជីដូនមួយ វាធ្វើខាងបញ្ជី១០០ហ្នឹង។ ដូចថា តាម៉ុក ត្រូវការមនុស្សប៉ុន្មានរយ ឲ្យតាដន ដើរសុំកម្លាំងពីតាមឃុំមក។ តាដន ហ្នឹងគេអ្នកធ្វើបញ្ជី១០០។ ហ្នឹងធ្វើបានតែប៉ុណ្ណឹង ហើយសម្ភារៈដែលចំណាយចេញចូលហ្នឹងគឺនៅលើ សោម ដន គេអ្នកធ្វើបញ្ជី១០០ហ្នឹងហើយ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណឹង។

**ស៖** តើគាត់ជាប្រធានមន្ទីរស្រុក ឬក៏គាត់ធ្វើការនៅមន្ទីរផ្សេង?

**ឆ៖** បាទ សោម ដន ធ្វើការនៅជាប់ក្នុងមន្ទីរស្រុករហូតរាល់ថ្ងៃ។ គាត់ចាំតែទទួលសម្ភារៈពីតាម៉ុក ទទួលសម្ភារៈពីខេត្តយកមកចែកប្រជាជន។ ចែកហើយធ្វើបញ្ជីរាយការណ៍ឡើងខ្វះខាតប៉ុន្មានស្នើអង្គការថែមទៀត។ គេចេះតែផ្តលើមកឲ្យហើយ។ គាត់កាន់បញ្ជី១០០រហូត។

**ស៖** ចុះឈ្មោះ ភី លោកធ្លាប់ស្គាល់ទេ? គាត់ប្រហែលជាធ្វើការនៅមន្ទីរស្រុកដែរ ហើយគាត់មានជើង<>បាំងពៀចៗ។ លោកស្គាល់ទេ?

**ឆ៖** បាទ ស្គាល់ច្បាស់ណាស់ ភី ហ្នឹង។ វាកាលពីឆ្នាំ៧០ ភី ហ្នឹងជានីរសារ តាជឹម ផ្ទាល់។ ដល់៧៦ តាជឹម ហ្នឹងចាត់តាំង ភី ហ្នឹងឲ្យទៅកាន់ស្រុក១០៧។ ដល់ ៧៩ យួនចូលស្រុក ប្រជាជនស្អប់អាហ្នឹង កាប់អាហ្នឹងជញ្ជ្រាំដាច់ដូចប្រហុកអស់ទៅ ងាប់ទៅ។ ធ្វើបាបរាស្ត្រ ធ្វើបាបប្រជាជនៗកាប់។

[១០:០៤:០១]

**ស៖** តើគាត់ធ្វើការនៅមន្ទីរស្រុកត្រាំកក់ទេ ភី ហ្នឹង គឺគាត់មានកាន់ខាងផ្នែកខាងផ្នែកសន្តិសុខទេនៅមន្ទីរស្រុក?

**ឆ៖** បាទ អត់ទេ អត់ដែលកាន់មន្ទីរស្រុកទេ។

**ស៖** ខ្ញុំមិនមែនសួរអីចឹងទេ ខ្ញុំសួរថាតើគាត់មានធ្វើការនៅមន្ទីរស្រុកទេ ឬក៏នៅមន្ទីរណាមួយដែលនៅជិតមន្ទីរស្រុក ហើយគាត់មានទទួលខុសត្រូវអីខាងផ្នែកឈ្លប ឬខាងផ្នែកមន្ទីរសន្តិសុខនៅ<ក្នុង>តំបន់ទេ?

**ឆ៖** បាទ ឈ្មោះភី ហ្នឹង ក្នុងមន្ទីរស្រុក គឺគេអត់ដែលចូលមកបង្ហាញខ្លួនផងហ្នឹង គេនៅមន្ទីរភស្តុភារគេខាងលិច វត្តថ្មីកជ្រុំ ឃ្លាំងធំណា ឃ្លាំងហ្នឹងគឺអង្គការតំបន់ គេចាត់តាំង ភី ហ្នឹងឲ្យនៅទទួលខុសត្រូវឃ្លាំងហ្នឹង។ ហើយដល់ចិតសិបប៉ុន្មានទេ តាជឹម យកមកឲ្យធ្វើចៅហ្វាយស្រុកនៅស្រុក១០៧

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងទៅ អត់ដែលមកដល់មន្ទីរស្រុកទេ។

**ស៖** លោកស្គាល់ឈ្មោះ រស់ ទេ គាត់ប្រហែលជាឈ្លបនៅកន្លែង -- នៅស្រុកហ្នឹង?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ឈ្មោះ រស់។ អារស់ ហ្នឹងក៏វាកម្លាំងជំនាញរបស់យាយខុម នៅការពារ យាយខុម ហើយក៏ជាអ្នកចាប់ចងយកគេទៅព្រៃទៅថ្ងៃត្រង់ហ្នឹង។ ឈ្មោះរស់ ហ្នឹង ដល់៧៩ យួនចូលស្រុក ក៏ប្រជាជនកាប់ចិញ្ច្រាំអស់រលីងទៅ ស្លាប់បាត់ទៅ។

**ស៖** ចុះឈ្មោះ ឃន លោកធ្លាប់ស្គាល់ទេ គាត់អាចប្រហែលជាមានទំនាក់ -- មានមុខងារប្រហាក់ប្រហែលនឹងឈ្មោះ រស់ ហ្នឹងដែរ?

**ឆ៖** ឈ្មោះអី? បាទ អត់ច្បាស់ទេ សូមមានប្រសាសន៍ម្តងទៀត។

**ស៖** ឃនៗ <សហការីខ្ញុំប្រាប់ថាគឺ>ឈ្មោះ ឃន <តើលោកស្គាល់>ទេ?

**ឆ៖** ឈ្មោះ ឃន ហ្នឹងស្គាល់មនុស្សប្រុស។ គាត់ដឹងមានបញ្ហាអីទេ គេដកសិទ្ធិយកមកទុកនៅក្នុងមន្ទីរស្រុកហ្នឹង ឲ្យកាន់ខាងជាង តាឃនៗ ហ្នឹង។

[១០:០៨:១៥]

**ស៖** មនុស្សចុងក្រោយ គឺឈ្មោះ ឌុច ឈ្មោះពេញគាត់ហ្នឹងគឺ អ៊ាប ឌុច។ តើ ឌុច នេះមានធ្វើនៅមន្ទីរស្រុក ឬក៏នៅ<>គណៈស្រុកទេ?

**ឆ៖** ឈ្មោះ ឌុច ហៅ សែម ហ្នឹងអត់ដែលធ្វើការក្នុងមន្ទីរស្រុកទេ គេនៅមន្ទីរស្អីជាមួយតាភី ហ្នឹងរហូតហ្នឹង។ ដល់៧៧ ខែ៨ តាជឹម យកទៅភូមិភាគបូព៌ាដែរទៅ។

**ស៖** ខ្ញុំមិនដឹងថាតើយើងនិយាយអំពី ឌុច តែមួយឬក៏យ៉ាងម៉េច? ខ្ញុំសំដៅ ឌុច ហ្នឹងគឺថា ឌុច ដែលជាអ្នកកាន់ខាងយុវជននៅស្រុក។ លោកៗដឹងទេ លោកដឹងថាមាន ឌុច ណាមួយដែលកាន់ខាងយុវជនស្រុកទេ?

**ឆ៖** បាទ យុវជនស្រុកមានឈ្មោះ វ៉ុន ឈ្មោះវ៉ុន ហ្នឹងឥឡូវហ្នឹងនៅទេ អត់ទាន់ស្លាប់ទេ នៅក្មេងហ្នឹង ប្រធានយុវជនស្រុកហ្នឹង។ ឌុច ហ្នឹងនៅលោកភីរហូត អនុតាភី ហ្នឹង។

[១០:០៩:៣៨]

**ស៖** តើលោកដឹងទេថាអ្នកទាំងអស់ដែលខ្ញុំរៀបរាប់អម្បាញ់មិញហ្នឹង ជាពិសេសឈ្មោះ រស់ <,> ឃន, ឌុច, ឬក៏ភី ហ្នឹងមានធ្លាប់ទៅក្រាំងតាចាន់ទេ? លោកមានដឹងទេនៅពេលដែលលោកធ្វើការនៅមន្ទីរស្រុកហ្នឹង ដឹងថាពួកគាត់ទាំងប៉ុន្មានធ្លាប់ទៅក្រាំងតាចាន់ទេ?

**ឆ៖** បាទ ក្រាំងតាចាន់ហ្នឹង អង្កាល់ឆ្នាំ១៩៧៨ ខែ៨ ខ្ញុំនៅក្នុងស្រុកអត់ទាន់មានក្រាំងតាចាន់ហ្នឹងទេ ដល់តែខ្ញុំទៅស្រុកគេ រត់ចូលព្រៃ ឆ្នាំ២០០០ មកដល់ ខ្ញុំទៅលេងស្រុកគេថា ក្រាំងតាចាន់មានជង្រុកក្បាលខ្មោច។ អាហ្នឹងវាកើតក្រោយខ្ញុំៗ អត់បានដឹងទេ។ កាល៧៨ ខែ៨ហ្នឹង អត់មានជង្រុកក្បាលខ្មោចនៅក្រាំងតាចាន់ហ្នឹង។ ក្រាំងតាចាន់ហ្នឹងជាព្រៃធាតុរបស់ប្រជាជន ៗនៅព័ទ្ធជុំវិញក្រាំងតាចាន់ហ្នឹង។

**ស៖** ប្រហែលនេះជាសំណួរ<ពីរ>ចុងក្រោយមុនពេលឈប់សម្រាក។ លោកសាក្សី នៅមន្ទីរស្រុកតើមានអ្នកណាម្នាក់ដែលជាស្មៀនមន្ទីរទេ? ហើយគាត់ហ្នឹងគឺក៏ទទួលខាងបញ្ជី ខាងឯកសារ ខាងបញ្ជីស្មាមប្រជាជនអីមានទេ? មានស្មៀនអីចឹងទេ?

**ឆ៖** បាទ សោម ដន, ហើយ តាជឹម, តាចាយ ចេញផុតទៅគេមានស្មៀនគេមួយទៀត។ ស្មៀនហ្នឹងគេថ្នាក់ទី១២ បញ្ចប់ហ្នឹង គេឈ្មោះ ប៊ុន យេន មកធ្វើការរហូតទល់៧៩ យួនចូលស្រុក មិនដឹងគេបែកទៅណា ដល់ខ្ញុំទៅលេងស្រុកឃើញ ប៊ុន យេនហ្នឹង មកចាប់ដៃខ្ញុំៗនៅរស់ទេ។ ហ្នឹងស្មៀន ពី ដំណពី សូត្រ ដន។

**ស៖** តើ ប៊ុន យេន ហ្នឹង ដែលជាស្មៀនហ្នឹង គាត់មានរក្សាបញ្ជីឈ្មោះគ្រួសារ អ្នក១៧មេសា ឬក៏បញ្ជីឈ្មោះអ្នកមូលដ្ឋាន ដើម្បីឲ្យដឹងថាតើអ្នកណាខ្លះរស់នៅៗក្នុងស្រុកហ្នឹង។ មានជាបញ្ជីអីចឹងទេ?

[១០:១២:១០]

**ឆ៖** បាទ ឈ្មោះ ប៊ុន យេន ហ្នឹងជាអ្នកស្មៀន គេធ្វើគ្រប់ចប់ទាំងអស់ហ្នឹង បញ្ជីចំណូលចំណាយ ក៏នៅលើ ប៊ុន យេន។ បញ្ជីប្រជាជនមកពីក្រៅ មកពីណាក៏គេ នៅលើ ប៊ុន យេន ហ្នឹង។ ធ្វើការកម្លាំងចេញទៅស្រុកក្រៅ ក៏នៅលើប៊ុន យេនហ្នឹង បញ្ជីគេធ្វើសព្វគ្រប់ទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោង ដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក ឯក ហឿន ឥឡូវនេះ ដល់ពេលសម្រាកហើយ ហើយយើងសម្រាកតាំងពីពេលនេះទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ។

លោក ឯក ហឿន! សម្រាកចុះ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ឯក ហឿន៖**

បាទ បត់ជើងតូចទៀតហ្នឹងណា៎។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្ដីលោក ហឿន!

**លោក ឯក ហឿន៖**

បាទ សួស្ដី!

**ប្រធានអង្គជំនុំ៖**

លោក ហឿន កុំទើសទាល់អី ហើយកុំអល់អែកអី ប្រសិនបើលោកមានបញ្ហាត្រូវទៅបន្ទប់ទឹក បត់ជើង បត់ដៃអី លោកប្រាប់យើង ដើម្បីយើងអនុញ្ញាតឲ្យលោកអញ្ជើញទៅ ធ្វើតាមធម្មតាណា៎។

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំចង់និយាយឲ្យបានលម្អិតបន្តិចជាមួយលោកអំពីហេតុការណ៍ដែលកើតឡើងនៅបន្ទាយក្នុងខេត្តតាកែវ គឺភ្លាមៗក្រោយពេលគេកាន់កាប់បានទីក្រុង ហើយខ្ញុំសូមដកស្រង់នូវ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចម្លើយដែលលោកឆ្លើយ គឺ<E319.1.32> គឺសំណួរ១០៨។ គឺជាចម្លើយដែលលោកបានផ្តល់។ លោកបាននិយាយថា៖ "នៅទីរួមខេត្តតាកែវក៏មានការសម្លាប់ដូច្នេះដែរ ទាំងប្រជាជនស៊ីវិល និងទាហានដែលនៅក្នុងបន្ទាយ។" នេះគឺជាអ្វីដែលលោកបាននិយាយ។ នៅពេលដែលលោកនិយាយថា ទាំងប្រជាជន និងទាហាននៅក្នុងបន្ទាយ តើលោកមិន -- គឺលោកមិនចង់និយាយអំពីអ្នកដែលគេជម្លៀសពីទីក្រុងភ្នំពេញទេ។ អ៊ីចឹងតើលោកចង់មានន័យថា កើតឡើងនៅថ្ងៃដែរគេរំដោះទីរួមខេត្តតាកែវ ឬក៏ភ្លាមៗក្រោយថ្ងៃរំដោះទីរួមខេត្តតាកែវនោះ?

**ប្រធានអង្គជំនុំ៖**

ឯក ហឿន កុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោក គង់ សំអុន!

[១០:៣៥:០០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសុំជំទាស់ចំពោះការតាំងសំណួរនេះរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ដោយសារយើងមិនបានពិនិត្យទៅលើវិសាលភាពដែលកើតមានឡើងនៅក្នុងខេត្តតាកែវទេ គឺយើងពិនិត្យតែទៅលើបញ្ហាត្រាំកក់ ហើយការសម្លាប់ទាហាននៅខេត្តតាកែវហ្នឹងវាជាផ្នែកផ្សេងមិនទាក់ទងនឹងការជំនុំជម្រះរបស់យើងនាពេលនេះទេ។ បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំគិតថាវាផ្ទុយពីនេះទៅវិញ គឺថាយើងចាំបាច់ត្រូវយល់អំពីបរិបទនៃហេតុការណ៍ គឺហេតុការណ៍ កើតឡើងមិនឆ្ងាយប៉ុន្មានទេ <>គឺនៅវត្តចំប៉ាលើក។ យើងក៏ត្រូវដឹងអំពីលក្ខណៈរបស់ខ្មាំង<របបហ្នឹង>ដែលគេកំណត់គោលដៅ។ ដូច្នេះ ខ្ញុំសុំអនុញ្ញាតបន្តចោទសួរសំណួរនេះទៅសាក្សីទៀត សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយអង្គជំនុំជម្រះត្រូវការស្តាប់សក្ខីកម្មសាក្សីឆ្លើយតបហ្នឹងសំណួរនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកសាក្សី តើលោកបានឮសំណួរដែលខ្ញុំបានសួរកន្លងមកទេ ឬមួយក៏លោកចង់ឲ្យខ្ញុំសួរម្តង

ទៀត?

**លោក ម៉ម រិទ្ធា៖**

យល់សំណួរទេ? យល់សំណួរទេពូ?

**លោក ឯក ហឿន៖**

អត់។

**លោក ម៉ម រិទ្ធា៖**

អ៊ីចឹង សូមឲ្យលោកព្រះរាជអាជ្ញាសួរម្ដងទៀតមក។

**លោក ឯក ហឿន៖**

បាទ សុំមានប្រសាសន៍ម្ដងទៀត ស្ដាប់អត់ឮ។

[១០:៣៧:១០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសុំអនុញ្ញាតឲ្យអ្នកបកប្រែគាត់និយាយឲ្យបានឮបន្តិច។ ខ្ញុំគិតថាសាក្សីគាត់ស្ដាប់សំណួររបស់ខ្ញុំមិនច្បាស់លាស់។ <នេះ ខ្ញុំគ្រាន់តែស្នើប៉ុណ្ណោះ។> ខ្ញុំសុំសួរឡើងវិញ។

**សួរដោយ លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកបានប្រាប់អ្នកស៊ើបអង្កេតថា នៅក្នុងទីរួមខេត្តតាកែវ ទាំងប្រជាជនស៊ីវិល និងយោធានៅបន្ទាយត្រូវបានគេសម្លាប់ ហើយខ្ញុំបានបញ្ជាក់ថានេះ<> គឺមិនមែនជាអ្វីដែលបានកើតឡើងនៅពេលដែលជម្លៀសប្រជាជនពីភ្នំពេញទៅវត្តចំប៉ាលើកនោះឡើយ ប៉ុន្តែវាជារឿងហេតុដែលកើតឡើងនៅក្នុងបន្ទាយនៅទីរួមខេត្តតាកែវ។ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលថាប្រជាជនស៊ីវិល ហើយនិងទាហានដែលត្រូវបានសម្លាប់នៅបន្ទាយនៅទីរួមខេត្តតាកែវនោះ ខ្ញុំចង់ដឹងថាតើវាកើតឡើងនៅថ្ងៃដែលគេរំដោះទីរួមខេត្តតាកែវ<តែម្ដង> ឬក៏ភ្លាមៗក្រោយពេលរំដោះទីរួមខេត្តតាកែវនោះ?

**ឆ៖** បាទ ខ្ញុំជម្រាបប្រសាសន៍ ប្រជាជន ទាំងប៉ូលិស ទាំងទាហានស៊ីវិលនៅក្នុងបន្ទាយទីរួមខេត្តហ្នឹងគឺ គេបញ្ចេញមកក្រៅទាំងអស់ មកនៅម្ដុំវត្តចំប៉ាលើក តាំងពីភ្នំពេញ តាំងពីកំពង់សោម កោះកុងអីហ្នឹង មកមូលនៅចំប៉ាលើកហ្នឹងបាទ។

**ស៖** សូមអរគុណលោក ខ្ញុំនឹងពិភាក្សាអំពីបញ្ហានៅវត្តចំប៉ាលើកនៅពេលបន្តិចទៀតនេះ ហើយខ្ញុំចង់ដឹងថាតើមានប្រជាជនប៉ុន្មាននាក់ដែលត្រូវបានគេសម្លាប់នៅក្នុងបន្ទាយនៅទីរួមខេត្តតាកែវនោះ?

**ឆ៖** បាទ អត់ដឹងចំនួនទេ ព្រោះគេវាយគ្នាទៅវាយគ្នាមកហ្នឹង វាមានស្លាប់មានរបួសក៏យើងអត់បានដឹងដែរ រឿងស្លាប់។ ប្រជាជនដែលគេបញ្ចេញទៅនៅចំប៉ាលើកហ្នឹងមកគ្រប់ខេត្តក្រុងទាំងអស់មកជួបជុំនៅហ្នឹងមួយអាទិត្យ បានគេចែកតាមភូមិ តាមឃុំ តាមសហករណ៍។ ពេលហ្នឹងគេប្រើសហករណ៍។ គេចែកទៅតាមសហករណ៍ហើយអស់បានគេចែកទៅតាមហ្នឹង។ ចេញមកដល់ឃុំលាយបូរ យកប៉ុន្មាន គឺថា ៥០០០នាក់អីចឹង គេឲ្យទៅ ៥០០០ទៅ។ មេឃុំគេមកទទួលយក។ ឲ្យទៅត្រពាំងធំមានប៉ុន្មាន? ៥០០នាក់ គេឲ្យឃុំហ្នឹងមកទទួលយកទៅ។ គ្រប់ឃុំទាំងអស់ អស់មនុស្សទាំងអស់ហ្នឹង ចែកគ្រប់ឃុំ។

[១០:៤០:០៨]

**ស៖** សូមអរគុណលោក។ យើងនឹងពិភាក្សាអំពីហេតុការណ៍ដែលកើតឡើងនៅវត្តចំប៉ាលើក។ ខ្ញុំនឹងលើកសំណួរមួយចំនួនទាក់ទងទៅនឹងហេតុការណ៍ ហើយខ្ញុំបញ្ជាក់ថាសំណួរហ្នឹងខ្លី ហើយជាក់លាក់ទេ គឺលោកបានប្រាប់អ្នកស៊ើបអង្កេតនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ <E319.1.32> គឺនៅសំណួរចម្លើយ១១៣ គេសួរលោក ថាតើលោកដឹងអំពីការសម្លាប់ទាហាន<លន់ នល់ និងគ្រួសាររបស់ពួកគេ>នៅក្នុងខេត្តតាកែវដែរឬទេ? ហើយលោកបានឆ្លើយដូចតទៅនេះ។ ខ្ញុំសូមដកស្រង់៖ "ពេលនោះខ្មែរក្រហមប្រកាសជ័យជម្នះថា ឈ្នះហើយភ្នំពេញ។ បន្ទាប់មកទៀត គេបានជម្លៀសប្រជាជនពីភ្នំពេញទៅដាក់នៅវត្តចំប៉ាលើក ដែលស្ថិតនៅខាងលិចអង្គតាសោម៣គីឡូម៉ែត្រក្នុងស្រុកត្រាំកក់។ ក្នុងរយៈពេល៧ថ្ងៃ ខ្មែរក្រហមបានឃោសនាដោយស្វែងរក<អតីតមន្ត្រីយោធា>ដែលធ្លាប់មានបណ្ដាស័ក្តិឲ្យមកចុះឈ្មោះ។ បន្ទាប់<ពីចុះឈ្មោះរួច>មក ពួកគេកម្ទេចមនុស្សទាំងអស់នោះ <ដោយមិនបន្សល់ដានអ្វីទាំងអស់>។ ពួកគេបានបញ្ជូនមន្ត្រី ឬក៏អ្នករដ្ឋការរាប់រយរាប់ពាន់នាក់រហូតទៅ។ សូម្បីតែស័ក្តិ១ និងស័ក្តិ២ ក៏គេមិនទុកដែរ គឺនៅសល់តែប្រជាជនធម្មតា។ គេឲ្យប្រជាជនទាំងអស់នោះត្រឡប់មកស្រុកកំណើតវិញ"។ សូមបញ្ចប់ការដកស្រង់។ តើលោកបានឮអ្វីដែលខ្ញុំអានឲ្យស្ដាប់ដែរឬទេ?

**ឆ៖** បាទ បានដឹងដែររឿងហ្នឹង ប៉ុនវាមិន --

**ស៖** តើលោកដឹងអំពីអ្វីដែលកើតឡើង? ពាក់ព័ន្ធទៅនឹងអ្វីដែលខ្ញុំបានអាន គឺពាក់ព័ន្ធទៅនឹងវត្តចំប៉ាលើក។ ខ្ញុំចង់ដឹងថា វត្តចំប៉ាលើកហ្នឹងនៅក្នុងឃុំអ្វី?

[១០:៤២:៥៧]

**ឆ៖** បាទ វត្តចំប៉ាលើកស្ថិតនៅក្នុងឃុំតាភេម ខាងលិចអង្គតាសោម។

**ស៖** អ៊ីចឹងវានៅក្នុងឃុំតាភេម។ តើក្រោយថ្ងៃ១៧ មេសា ៧៥ ប្រហែលប៉ុន្មានថ្ងៃ ដែលអ្នកជម្លៀសមកពីទីក្រុងភ្នំពេញនិងកំពង់សោម មានមកដល់ទីកន្លែងនោះ? តើពួកគេចំណាយពេលប៉ុន្មាន <ថ្ងៃ ប៉ុន្មានសប្តាហ៍> ទើបមកដល់វត្តចំប៉ាលើកហ្នឹង?

**ឆ៖** បាទ អត់ដឹងចំនួនទេ មកច្រើនណាស់។ មកងងឹតទឹកងងឹតដីពេញលើផ្លូវ ដើរតាមផ្លូវ មកឈប់សម្រាកនៅចំប៉ាលើកហ្នឹងទាំងអស់។

**ស៖** លោកនិយាយថាប្រជាជនមកពីខេត្តតាកែវក៏មកវត្តចំប៉ាលើកដែរ។ អ៊ីចឹងៗ តើប្រជាជនដែលមកពីទីរួមខេត្តតាកែវ គឺជាក្រុមប្រជាជនដំបូងដែលមកដល់វត្តចំប៉ាលើក។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតណាស់។

[១០:៤៤:៣៩]

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី E319.1.32 គឺសំណួរ១២៤ លោកបាននិយាយថា៖ "<ខ្មែរក្រហម>ប្រមូលមនុស្សមកពីគ្រប់ទិសទីតែម្តង គឺក្រោយរំដោះប្រហែលជាបីទៅបួនថ្ងៃ"។ តើលោកចង់មានន័យថាម៉េច នៅពេលដែលលោកនិយាយថា <ខ្មែរក្រហម>ប្រមូលមនុស្សមកគ្រប់ទិសគ្រប់ទីតែម្តង? តើលោកអាចបញ្ជាក់បានលម្អិតបន្តិចបានទេ តើគេធ្វើដោយរបៀបណា?

**ឆ៖** បាទ មកពីកោះកុង មកពីភ្នំពេញ មកពីតែកែវ មកពីៗណាគេមូលមកទុកនៅហ្នឹងចំនួនអាទិត្យ។ ទុកហើយ គេបែងចែកកម្លាំងដែលមានក្នុងហ្នឹង គេធ្វើបញ្ជី១០០ គេដឹងថាកម្លាំងហ្នឹង មានប៉ុន្មាន។ ថាមាន២០.០០០នាក់អ៊ីចឹង។ ដល់២០.០០០នាក់ គេបែងចែកទៅតាមឃុំ ឱ្យទៅនៅតាមឃុំ។ គេចែកហើយ បានគេឱ្យមេឃុំមកនាំផ្លូវដឹក នាំប្រជាជនទៅនៅតាមឃុំរៀងខ្លួនទៅ។ គ្រប់ឃុំទាំងអស់គេធ្វើអ៊ីចឹង។

**ស៖** មុនពេលដែលអ្នកជម្លៀសទាំងអស់នោះមកដល់ គឺតើវាភ្លាមៗក្រោយពេលដែលគេរំដោះទីក្រុងភ្នំពេញ ឬក៏មុនពេលរំដោះទីក្រុងភ្នំពេញ ដែលថាគេមានការរៀបចំប្រជុំ ដើម្បីត្រៀមទទួលអ្នកជម្លៀសទាំងអស់នោះ និងត្រៀមបែងចែកអ្នកជម្លៀសទាំងអស់នោះ?

[១០:៤៦:៣៨]

**ឆ៖** បាទ ត្រង់ហ្នឹង ខ្ញុំហ្នឹងហើយអ្នកដឹកបាយកញ្ចប់យកមកចែកប្រជាជន ដែលគេជម្លៀសចេញ មកហ្នឹងនៅចំប៉ាលើក មកគ្រប់ភូមិទាំងអស់ ដឹកសុទ្ធតែបាយកញ្ចប់មកគ្រប់គ្នាទាំងអស់។ សូមជម្រាបប្រសាសន៍។ ចែកតែបាយកញ្ចប់ អត់មានចែកអីហូប ស្លាម្ហូអី អត់ទេ អត់មានទេ ចែកតែបាយ

កញ្ចប់។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរលោកឡើងវិញ។ អ្វីដែលខ្ញុំចង់ដឹងគឺថាតើប្រជាជនដែលមកដល់ចំប៉ាលើកហ្នឹង ថាតើមានការប្រជុំ គឺកិច្ចប្រជុំត្រៀមនៅកម្រិតថ្នាក់ស្រុក ឬក៏ថ្នាក់<ភូមិភាគ>នុ៎ង? គឺថាតើមានការប្រជុំ ដើម្បីពិភាក្សាថា អ្វីដែលត្រូវធ្វើ<ចំពោះអ្នកទាំងអស់នោះ> ហើយតើលោកដឹងមានការប្រជុំបែបនេះឬក៏អត់?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ គឺប្រជុំចុះឈ្មោះក្នុងបញ្ជីដើម្បីចែកកម្លាំងហ្នឹង ឲ្យទៅនៅតាមៗឃុំ បាទ គឺប្រជុំតែប៉ុណ្ណឹង ដឹងគេប្រជុំដែរ និយាយគ្រប់តែគ្នាថាទៅដល់យើងចែកគ្នា ថាប្រជុំមួយក្រុមហ្នឹង មាន១៥នាក់ គេយកបីបួនក្រុមអ៊ីចឹងមក គ្រប់មួយភូមិ គេៗធ្វើតែប៉ុណ្ណឹងហើយ គេចុះឈ្មោះ។ ដល់ពេលថ្ងៃចេញកម្លាំង គេយកមកកម្លាំងគេហ្នឹងទៅតាមឃុំគេទៅ។ ធ្វើអ៊ីចឹង ប្រជុំអ៊ីចឹង។

[១០:៤៨:៣៣]

**ស៖** ក្នុងពេលប្រជុំរៀបចំនុ៎ង តើគេមានបាននិយាយអំពីជោគវាសនារបស់<អតីតទាហាន និង>អ្នករដ្ឋការ<>របប លន់ នល់ ឬក៏អត់? ថាតើគេមាននិយាយថា ត្រូវ<កំណត់អត្តសញ្ញាណ ឬ> បំបែក<ពួកគេ>ចេញពី<អ្នកដែលគេជម្លៀសផ្សេងទៀត ដោយរបៀបណា>?

**ឆ៖** បាទ អត់ទេ គេចុះបញ្ជីរួម ហើយដល់តែចែកគ្នាតាមៗគ្រប់ឃុំ គ្រប់ភូមិអស់ទៅ។ ទៅដល់សហករណ៍ បានគេចម្រាញ់ចេញអស់ហើយ ស្រេចតែមេឃុំគេអ្នកសម្រេចទេ ស័ក្តិប៉ុន្មានៗ មកលើភូមិឃុំនោះ។ មកដល់ហ្នឹងគ្រាន់តែចែកកម្លាំងទៅតាមសហករណ៍ទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមអាននៃចម្លើយ១១៣ ដែលលោកបានបញ្ជាក់ គឺថា "នៅវត្តចំប៉ាលើក<> អ្នករដ្ឋការរបបមុនត្រូវចុះឈ្មោះក្នុងរយៈពេលប្រាំពីរថ្ងៃ ហើយនៅពេលដែលគេចុះឈ្មោះហើយ គឺគេកម្ទេចដោយមិនទុកស្លាកស្នាម គឺគេបែងចែក ឬក៏បញ្ជូនអ្នករដ្ឋការរាប់រយនាក់ចេញទៅ។" តើគេធ្វើនៅវត្តចំប៉ាលើកដែរឬទេ គឺខ្ញុំចង់និយាយពីការចុះឈ្មោះអ្នករដ្ឋការ លន់ នល់ តើគេធ្វើនៅវត្តចំប៉ាលើកដែរឬទេ ហើយអ្នកណាជាអ្នកចុះឈ្មោះអ្នករដ្ឋការទាំងអស់នោះ?

**ឆ៖** បាទត្រង់ហ្នឹង ខ្ញុំបាទអត់បានដឹងទេ ព្រោះអត់បានចូលរួមគេ អត់ដឹង។

**ស៖** ខ្ញុំមិនមែននិយាយថាលោកចូលរួមនៅក្នុងការងារទាំងអស់នោះទេ អ្វីដែលខ្ញុំចង់សួរលោក គឺថាតើលោកដឹងដែរឬទេ ថាមានការងារបែបនេះ? ថាតើគេមានស្នើសុំឲ្យអ្នករដ្ឋការបញ្ជាក់ថា<តើពួកគេ ជាមន្ត្រីនៅក្នុងយោធា របប>លន់ នល់ <ដើម្បីឲ្យដឹងអំពីតួនាទីរបស់ពួកគេ ដែរឬទេ>? ថាតើ

កម្មាភិបាលខ្មែរក្រហមមានធ្វើឬក៏អត់ មិនមែនលោកទេ តើកម្មាភិបាលខ្មែរក្រហមមានសួរនាំអំពីបញ្ហាហ្នឹង<ទៅអ្នកដែលគេជម្លៀស ដែរឬទេ>?

[១០:៥១:២៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយមូលហេតុជាសំណួរច្រំដែល។ សាក្សីបានបញ្ជាក់រួចហើយ ថាគាត់មិនបានដឹងទេ ហើយគាត់មិនបានចូលរួមក្នុងការប្រជុំទាំងឡាយនោះទេ។ ដូច្នេះ នេះជាចម្លើយច្បាស់លាស់បំផុតដែលសាក្សីបានផ្តល់នៅពេលនេះ។ បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំមិនគិតដូច្នេះទេ។ សាក្សី<>និយាយ<អ៊ីចឹងត្រឹមត្រូវហើយ នៅពេលដែលគាត់>ថា<គាត់>មិនចូលរួម<។ គាត់និយាយអ៊ីចឹង។ ដូច្នេះ គាត់បានចែកដាច់ពីគ្នារវាងព្រឹត្តិការណ៍ និងមុខងាររបស់គាត់ក្នុងព្រឹត្តិការណ៍នោះ។ ទោះយ៉ាងណាក្តី ខ្ញុំនៅតែមិនបាន>ចម្លើយរបស់គាត់<ឲ្យបានច្បាស់នោះទេ ទាក់ទងនឹងហេតុការណ៍ហ្នឹង។ អ៊ីចឹង ខ្ញុំពឹងផ្អែកលើ>កំណត់ហេតុ<នៃការស្តាប់ចម្លើយ>ដែលគាត់ផ្តល់ឲ្យអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះហើយ ទើបខ្ញុំព្យាយាមជួយគាត់ នៅក្នុងផ្នែកនេះ ខ្ញុំធ្វើទៅតាមអ្វីដែលជាការចាំបាច់សម្រាប់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សីចំពោះសំណួរនេះដើម្បីឲ្យបានកាន់តែច្បាស់លាស់។

សាក្សីឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលសំណួរចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើសាក្សីចងចាំ។

**លោក ម៉ម រិទ្ធា៖**

លោកចាំសំណួរទេអំមិញ?

**លោក ឯក ហឿន៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**បាទ**?

**លោក ម៉ម រិទ្ធា៖**

លោកចាំសំណួរចុងក្រោយអំមិញទេ?

**លោក ឯក ហឿន៖**

អត់ទេ។

**លោក ម៉ម រិទ្ធា៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាសួរម្តងទៀត។

**លោក ឯក ហឿន៖**

**ឆ៖** បាទ សូមមានប្រសាសន៍ទៀត អត់ៗចាំទេភ្លេចបាត់ទៅ។

[១០:៥៣:២០]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំមិនមែននិយាយអំពីតួនាទីរបស់លោកទេ ខ្ញុំគ្រាន់និយាយអំពីហេតុការណ៍មួយដូចដែលលោកបាននិយាយ កម្មាភិបាលខ្មែរក្រហមនៅវត្តចំប៉ាលើកបានសួរអ្នកដែលជម្លៀស។ គេសួរអ្នក<>ដែលជា<មន្ត្រីនៅក្នុង>យោធាលន់នល់ ឲ្យចុះឈ្មោះនៅក្នុងបញ្ជីដោយកម្មាភិបាល។ កម្មាភិបាលទាំងនោះប្រាប់ថា<អ្នកទាំងអស់>ហ្នឹងត្រូវទៅទទួលប៉ុស្តិ៍ដដែលឡើងវិញ តើកម្មាភិបាលខ្មែរក្រហមមានធ្វើសកម្មភាពបែបហ្នឹងដែរឬទេ?

**ឆ៖** បាទ ត្រង់ហ្នឹងអត់បានដឹងទេ ព្រោះវាមិនដឹង មិនដែលបានទៅជិតទៅបៀតគេផង ឮតែគេនិយាយតៗគ្នា ហើយគេឲ្យមេឃុំ មេភូមិទៅទទួលមនុស្សដែលគេចែកហ្នឹងមកហ្នឹង តែប៉ុណ្ណឹងដឹង។

[១០:៥៤:៣៨]

**ស៖** ដើម្បីរំឭកការចងចាំរបស់លោក ខ្ញុំសូមអានទូវផ្នែកមួយទៀតនៃកំណត់ហេតុស្តាប់ចម្លើយ<របស់លោក គឺ> E319.1.32 គឺ E319.1.32 គឺសំណួរទី១១៧ ដែលគេសួរលោក៖ "សំណួរ៖ លោកដឹងរឿងនេះដោយលោកធ្វើការនៅសាលាស្រុក តើត្រឹមត្រូវដែរឬទេ?" ចម្លើយ១១៧៖ "បាទ ខ្ញុំបាន<ឃើញខ្មែរក្រហម>ឃោសនា<>ដែលមានទំហំដីប្រហែលជា១០គីឡូម៉ែត្រការ៉េ គឺសុទ្ធតែមនុស្ស។ ខ្មែរក្រហម ប្រកាសថា អ្នកណាធ្លាប់<ធ្វើ>ការអី គេឲ្យធ្វើការនោះវិញ<ដូចរបបមុន>"។ សូមបញ្ចប់ការដកស្រង់។ នៅត្រង់ចំណុចនេះលោកនិយាយថាលោកឃើញខ្មែរក្រហមឃោសនា តើលោក

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅរក្សាចម្លើយដដែលនេះដែរឬទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍។ បញ្ហាហ្នឹងគឺគេឃោសនារកពួកអ្នកមានបណ្ដាស័ក្តិពិតមែនហើយ។

**ស៖** តើ<មាន>យោធា<ជាច្រើន>ធ្លាក់ក្នុងអន្ទាក់ខ្មែរក្រហម ឬក៏ធ្លាក់ក្នុងអន្ទាក់ការឃោសនារបស់ខ្មែរក្រហម ដែរទេ? ថាតើ<មន្ត្រីទាំងអស់នោះ>មានបង្ហាញអំពីឋានន្តរសក្តិ<>របស់ពួកគេ<នៅក្នុងជួរយោធាលន់ នល់>ប្រាប់ទៅខ្មែរក្រហមដែរឬទេ?

**ឆ៖** បាទ ប្រកាសថារកពួកអ្នកបណ្ដាស័ក្តិ ពួកទាហាន ប៉ូលិស មេឃុំ មេជំទប់អី គេប្រាប់ គេធ្វើអីៗគេប្រាប់ទាំងអស់ ខ្មែរក្រហមកត់ត្រាទាំងអស់ ប៉ុនដឹងកត់ហ្នឹងវា គេបញ្ជូនទៅតាមសហករណ៍ គេបញ្ជូនទៅណាអត់បានដឹងផុតចុងផុតគល់ទេ។

[១០:៥៧:២៥]

**ស៖** តើលោកខ្លួនឯងផ្ទាល់ ឬក៏អ្នកដទៃបានឃើញប្រជាជននោះម្ដងទៀតទេ គឺឃើញក្រោយពេលដែលពួកគេ ដែលពួកគាត់ត្រូវបានគេយកទៅកន្លែងផ្សេងហ្នឹង<ដែលលោកមិនស្គាល់>?

**ឆ៖** បាទ ឃើញៗពេលគេចែកកម្លាំងតាមឃុំ តាមភូមិហ្នឹង ឃើញទៅនៅដល់ស្រុក ដល់ភូមិ ដល់ផ្ទះហ្នឹង អត់ដែលមកដល់កន្លែងចំប៉ាលើកហ្នឹងផង។

**ស៖** សូមអរគុណលោក ខ្ញុំនឹងអានន្ទូវសម្រង់មួយទៀតនៃកំណត់ហេតុស្តាប់ចម្លើយ<របស់លោក> គឺ E319.1.32។ ជាដំបូងគឺសួរសំណួរ១១៨ ទៅលោកដូចតទៅនេះ៖ "តើអ្នកណាជាអ្នកគ្រប់គ្រងនៅក្នុងប្រតិបត្តិការឃោសនាទៅដល់មនុស្សរាប់ពាន់នាក់នោះ? ចម្លើយ៖ តាម៉ុកគឺជាអ្នកគ្រប់គ្រង។ សំណួរ១២៤ ខ្ញុំទើបតែមកដល់ចំណុចនេះទេ ចំណុច១២៤ គឺសំណួរចម្លើយដែលគេសួរដោយសហចៅក្រមស៊ើបអង្កេតសួរថា៖ "តើរឿងនេះកើតឡើងនៅពេលណា?" ហើយលោកឆ្លើយដូចតទៅនេះ <សូមស្តាប់ឲ្យច្បាស់>៖ "គឺក្រោយរំដោះប្រហែលជាបីទៅបួនថ្ងៃ គឺ<ខ្មែរក្រហមបាន>ប្រមូលមនុស្សមកពីគ្រប់ទិសគ្រប់ទីតែម្ដង។ នៅពេលធ្វើប្រតិបត្តិការនោះ គឺមាន<វត្តមាន> សោម ដន <ជា>ប្រធានមន្ទីរស្រុកត្រាំកក់។ ធួង ធីម មេឃុំត្រពាំងធំ និង ដែក ស៊ីម អនុប្រធានឃុំត្រពាំងធំ <អ្នកទាំងអស់នេះ>ជាអ្នកទទួលខុសត្រូវ។ សោម ដន ជាប្រធាននៅក្នុងប្រតិបត្តិការឃោសនាដល់ប្រជាជននេះ"។ ឥឡូវនេះលោកបាននិយាយនៅក្នុងឃ្លាមុនថា តាម៉ុកជាអ្នកគ្រប់គ្រងហើយ សោម ដន ជាអ្នកដឹកនាំប្រតិបត្តិការ។ តើអីចឹង<វាយ៉ាងម៉េចទៅ>?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ដែក ស៊ីម ក្រោមថ្នាក់ដឹកនាំរបស់ សោម ដន។ សោម ដន គេក្ដាប់រួមក្នុងមន្ទីរជនដែលគេប្រមូលមកទុកមួយកន្លែងហ្នឹង។

[១១:០០:៣២]

**ស៖** តើលោកឃើញ តាម៉ុក នៅទីកន្លែងនោះដែរឬទេ? គឺនៅវត្តចំប៉ាលើក ឬក៏នៅក្បែរៗវត្តចំប៉ាលើកដែរឬទេនៅពេលដែលប្រជាជនត្រូវបានគេជម្លៀសស្នាក់នៅទីនោះ?

**ឆ៖** បាទ អត់មានឃើញ តាម៉ុក អត់មានឃើញចៅហ្វាយស្រុក លេខាស្រុក អនុស្រុកអីអត់ទេ មានតែ សោម ដន ហើយនិង ដែក ស៊ីម ហ្នឹងតែពីរហ្នឹងទេ គេទៅគ្រប់គ្រងប្រជាជនដែលគេយកមកទុកកន្លែងហ្នឹង។ មានតែពីរហ្នឹងទេ។

**ស៖** បាទ អរគុណ។ នៅពេលដែលលោកនិយាយថា តាម៉ុក ជាអ្នកគ្រប់គ្រងទៅលើប្រតិបត្តិការនេះ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានដែរឬទេ ដោយសារតែគាត់ជាប្រធានភូមិភាគ<>ឬក៏ដោយសារតែគាត់ចូលរួមដោយផ្ទាល់នៅក្នុងប្រតិបត្តិការនេះតែម្ដង។ តើលោកចង់បញ្ជាក់ថាមួយណា?

**ឆ៖** បាទ អត់មានដែលឃើញមុខ តាម៉ុក មកជិត មកបៀតកន្លែងហ្នឹងផង។ សូម្បីចៅហ្វាយស្រុកក៏អត់ដែលមកជិត មកបៀតកន្លែងជនភៀសខ្លួនដែលគេប្រមូលទុកហ្នឹងដែរ អត់ដែរឃើញទាំងអស់។

**ស៖** នៅពេលដែលលោកនិយាយអំពីមេស្រុក តើលោកនិយាយអំពី យាយខុម ដែលជាប្រពន្ធមាស មុត ហ្នឹងមែនទេ?

[១១:០២:២៦]

**ឆ៖** បាទ យាយខុម ក៏គាត់អត់ដែរមកអើតកន្លែងជនភៀសខ្លួនហ្នឹង។ មានតែពីរនាក់ សោម ដន ហើយ ដែក ស៊ីម ហ្នឹង។ ដល់ហើយគេបញ្ជេញទៅ បានគេទទួលស្គាល់តាមភូមិ តាមឃុំហ្នឹង។

**ស៖** អ៊ីចឹងតើខ្ញុំអាចនិយាយថាគឺ<លោក>មិនចំណាយពេលដល់ទៅមួយសប្ដាហ៍ក្នុងការពិនិត្យមើលទៅលើហេតុការណ៍<នៅវត្តចំប៉ាលើកហ្នឹង>ទេ <គឺលោករវល់>ទៅមកៗ<ដឹកអង្ករ។> អ៊ីចឹងមែនទេ?

**ឆ៖** បាទ ដូចអត់ទេ អត់ដែលឃើញអើតផង។ ខ្ញុំក៏ទៅមើលឃើញ ឮគេថាគេប្រមូលប្រជាជនមកនៅចំប៉ាលើកហ្នឹង ក៏ទៅមើលបានគេមួយម៉ោងដែរ ក៏រត់មកផ្ទះវិញ ខ្លាចគេគំរាមកំហែងអី។ អត់ដែរឃើញ ទៅអត់ដែរជួបពួកហ្នឹងទេ ទៅតែម្ដង។ ឃើញតែ សោម ដន ហើយនិង ដែក ស៊ីម នៅ

ជាប់ហ្នឹង។

**ស៖** លោកបាននិយាយអំពី<ការធ្វើ>បញ្ជីឈ្មោះមន្ត្រី<>ឃោធាលន់នល់។ តើបញ្ជីហ្នឹងគឺជាបញ្ជីដែលលោកបានឃើញ នៅពេលដែលលោកទៅដល់ទីកន្លែងហ្នឹង ឬក៏លោកបានស្ដាប់ឮនៅពេលក្រោយនៅមន្ទីរស្រុកទេ?

**ឆ៖** បាទ អត់ទេ។ បញ្ជីហ្នឹងគេទៅដល់តាមភូមិ តាមអី ឃើញឈ្មោះគេកាន់បញ្ជីទៅថា១០០នាក់ ទៅដល់ក្នុងភូមិហ្នឹង គេឲ្យនៅ១០០នាក់ ឃើញបញ្ជីទៅដល់តែ១០០នាក់ហ្នឹង ឃើញ ដឹងតែប៉ុណ្ណឹងទេ។

[១១:០៤:៤៧]

**ស៖** ឥឡូវនេះ ខ្ញុំចង់លើកយកប្រធានបទថ្មីមួយទៀត ដែលយើងនិយាយអំពីការចាប់ខ្លួន ចាប់ខ្លួនមន្ត្រីរដ្ឋការ<>លន់នល់ ប៉ុន្តែនៅ -- គឺហេតុការណ៍នៅក្រោយវត្តចំប៉ាលើកទេ។

ឥឡូវនេះ ខ្ញុំចង់ដកស្រង់នៅកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺ E319.1.32 គឺសំណួរចម្លើយ២៧។ លោកបាននិយាយថា៖ “មានពេលមួយខ្ញុំបានឃើញគេចាប់មនុស្សយ៉ាងច្រើន គេបណ្ដើរមនុស្សទាំងអស់ផង ហើយខ្ញុំសួរថាពួទៅណាហ្នឹងពូ? គេឆ្លើយថាទៅជួបអង្គការ។ <ថ្ងៃបន្ទាប់មក> ទើបខ្ញុំដឹងថា អ្នកទាំងនោះត្រូវគេចាប់ខ្លួន។ ដូច្នេះ ខ្ញុំក៏លែងសួរពួកគេទៀត។ អ្នកទាំងអស់នោះ រួមមានគ្រូបង្រៀន និងអតីតមន្ត្រីរាជការជាដើម”។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះលោកនិយាយថា លោកបានឃើញអតីតមន្ត្រីរាជការ និងគ្រូបង្រៀនត្រូវបានគេចាប់ខ្លួននៅស្រុកត្រាំកក់។

តើលោកចាំទេថានៅពេលណា? តើនៅពេលណាដែលហេតុការណ៍ហ្នឹងកើតឡើង? តើនៅក្រោយថ្ងៃ១៧មេសា ឆ្នាំ៧៥ុ០ះ<>?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ការចាប់ខ្លួនហ្នឹង នៅមុនរំដោះទីក្រុងទាំងប្រទេស ក្នុងឆ្នាំ៧០ ខែ៣។ ខែ៣ហ្នឹងឃើញមនុស្សដើរដង្ហែគ្នាពីផ្លូវលំ ពីជើងទៅត្បូង។ ឃើញដង្ហែដូចទៅបុណ្យអីចឹង ហើយខ្ញុំ ផ្ទះនៅផ្លូវលំពីជើងទៅត្បូងហ្នឹង ឃើញដើរសុទ្ធតែមនុស្សធ្លាប់រៀនសូត្រជាមួយគ្នា ធ្លាប់ធ្វើបុណ្យធ្វើទានជាមួយគ្នាក៏របូតមាត់សួរ “ថាអីទៅណាអ៊ី? គេថា៖ អឺ! ទៅជួបអង្គការ”។ ហើយខ្ញុំឮថាទៅជួបអង្គការខ្ញុំភ័យខ្លួន ខ្ញុំថយទៅក្រោយ។ ថ្ងៃក្រោយឃើញគេមកយកអីចឹង ក៏លែងសួរទៀតរហូតទៅ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅរយៈកាលមួយផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងសវនាការរបស់យើងគឺ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្នាំ៧៥ ដល់ឆ្នាំ<៧៧>។ ខ្ញុំនឹងអានចម្លើយរបស់លោកនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតគឺ E319.1.32 នៃសំណួរចម្លើយ៤៥។ គេសួរលោកថា៖ "តើគេប្រើប្រាស់នីតិវិធីដូចម្តេចដើម្បីកំណត់អ្នកណាជាខ្មាំងនៅក្នុងស្រុកត្រាំកក់ចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៧។" ពេលនោះលោកឆ្លើយថា ដូចតទៅ៖ "ពេលនោះ គេបែងចែកជាវណ្ណៈបីគឺ កម្មករកណ្តាល កម្មករក្រោម និងពលករ ហើយក្រៅពីនេះគឺសុទ្ធតែពួកសក្តិសម្ព័ន្ធដែលគេចោទថាជាខ្មាំង។ ឧទាហរណ៍ដូចជា អតីតគ្រូបង្រៀនជាដើម។ ជនជាតិវៀតណាមក៏ដូចគ្នាដែរ គឺគេបញ្ជូនចេញទៅបាត់ ហើយមិនដែលឃើញត្រឡប់មកវិញទេ"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកដូចតទៅ លោកសាក្សី តើអ្នកណាជាអ្នកប្រកាសថាពួកសក្តិសម្ព័ន្ធ ឬអតីតគ្រូបង្រៀនដែលត្រូវគេចាត់ទុកថាជាខ្មាំង?

[១១:០៨:៥៦]

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ចំពោះពួកដែលគេចាប់ខ្មាំងមុនរំដោះទូទាំងប្រទេសហ្នឹង គេពាក្យឈ្លបរបស់គេ គេនិយាយថា "កម្ទេចឲ្យអស់ពួកសក្តិភូមិ នាយទុន ប្រតិកិរិយា ប្រហារអត់ឲ្យសល់ម្នាក់ កម្ទេចទាំងរបប កម្ទេចទាំងបុគ្គល"។ យាយខុម ប្រពន្ធ មាស មុត គាត់ដើរធ្វើមីទិ្ទងគ្រប់ភូមិគ្រប់ស្រុក គាត់ថាអ៊ីចឹង។ ពាក្យឈ្លបរបស់គេអ៊ីចឹង ហើយគ្រូបង្រៀន ជំទប់ មេភូមិ មេឃុំអី ដូចឪខ្ញុំអ៊ីចឹង និន្នាការនយោបាយគេរកកម្ទេចអ៊ីចឹង មិនមែនចាប់ពួកទាហានលន់ នល់ ណា! ពួកសម្តេចសីហនុដែលនៅក្នុងដីរំដោះហ្នឹង គេថាពួកសក្តិភូមិហ្នឹងហើយគេត្រូវកម្ទេច ហើយម៉ែឪខ្ញុំក៏នៅក្នុងរបបជំនាន់សង្គមរាស្ត្រនិយមហ្នឹងក៏ត្រូវកង់ប្រវត្តិសាស្ត្រគេកិនដែរ។ ហ្នឹងហើយចៅហ្វាយស្រុកគេដើរប្រកាសធ្វើមីទិ្ទងតែអ៊ីចឹង។ បាទ សូមអស់យោបល់។

**ស៖** សូមអរគុណ។ ខ្ញុំ<ចង់សួរ>ទៅលើរយៈពេល៧៥ ដល់៧៧ ក៏ប៉ុន្តែអ្វីដែលលោកឆ្លើយអម្បាញ់មិញនេះ គឺមុនរំដោះឆ្នាំ៧៥ទេ។ អ៊ីចឹងខ្ញុំចង់សួរពីពាក់ព័ន្ធនឹងពាក្យ "ខ្មាំង"នេះ ដែលជាអតីតមន្ត្រីរដ្ឋការ និងគ្រូបង្រៀន ឬក៏ទាហានលន់ នល់នេះ។ តើខ្មាំងទាំងអស់ហ្នឹងជាខ្មាំងដដែលៗមែនទេក្រោយ<ថ្ងៃទី១៧ មេសា>ឆ្នាំ៧៥នោះ គេនៅតែបន្តស្វែងរកខ្មាំងទាំងអស់ហ្នឹងទៀតមែនទេ?

**ឆ៖** បាទ ពិតណាស់។

**ស៖** បន្ទាប់ពីពួកគេទៅដល់ស្រុកត្រាំកក់ប៉ុន្មានខែ ប៉ុន្មានឆ្នាំក្រោយមកនោះ តើអ្នកដែលគេជម្លៀសចេញពីទីក្រុងនោះ ដែលគេហៅថាអ្នក១៧មេសាហ្នឹង ពួកគេត្រូវតែធ្វើប្រវត្តិរូបជាទៀងទាត់នៅក្នុងឃុំ ក្នុងសហករណ៍ ឬក៏នៅគ្រប់ជាន់ថ្នាក់នៃរដ្ឋអំណាចមែនទេ?

**ឆ៖** បាទ ពិតមែនហើយ ប្រាកដហើយ ច្បាស់ណាស់។

[១១:១១:២៤]

**ស៖** តើលោកដឹងទេ ហេតុអីបានជាគេ<ចង់>ដឹងពីប្រវត្តិរបស់អ្នកជម្លៀសទាំងអស់ហ្នឹង ដែលជាអ្នក១៧មេសាហ្នឹង។ តើវា<មានហេតុផលអីនៅពីក្រោយការចង់ដឹងចំពោះអ្វីដែល>អ្នកទាំងអស់ហ្នឹងពីមុនធ្វើអីនោះ?

**ឆ៖** បាទ ដោយគេ ពីអ្នកចង់ដឹងពីអ្នកគេប្រមូលចេញពីទីក្រុងទៅនៅជនបទហ្នឹង គេដើម្បីចង់ដឹងអ្នកហ្នឹងមាននិន្នាការនយោបាយនៅសមរភូមិដីរំដោះដែរអត់ ដូចថាគេឃោសនារកពួកបណ្ដាស័ក្តិហ្នឹងទៅ ប៉ះពាល់ដូចថាខ្ញុំនៅដីរំដោះហ្នឹង មាននិន្នាការបងប្អូនដែលទើបចេញមកហ្នឹងវាត្រូវពាក់ព័ន្ធខាងនយោបាយ។ អីចឹងគេយកខ្ញុំទៅអារ-កទៀតតែពាក់ព័ន្ធ។ ហើយអាបងប្អូនដែលមកហ្នឹងមានបណ្ដាស័ក្តិក៏គេយកទៅអារ-កថែមទៀត។ អាហ្នឹងក៏អីចឹងដូចគ្នា ឃុំណាក៏ឃុំណា ដូចឃុំណាដែរ គេចអត់ផុតទេ កង់ប្រវត្តិសាស្ត្រគេកិន ព្រោះគេថា “ពួកសក្តិភូមិ នាយទុន ប្រតិកិរិយា ប្រហារអត់ឲ្យសល់ម្នាក់ កម្ទេចទាំងរបប កម្ទេចទាំងបុគ្គល” ហើយគេដើរចាប់បានហ្នឹងអត់មានខុសទេ។ ហើយយើងនៅដីរំដោះក៏គេចាប់ មិនចាប់តែអ្នកមកថ្មីទេ។

[១១:១២:៥៤]

**ស៖** តើលោកអាចពន្យល់ពាក្យដែលលោក<>ប្រើជាញឹកញាប់នោះ<គឺពាក្យ>ថា “កង់ប្រវត្តិ-សាស្ត្រ” វិល ហើយកម្ទេចនេះ? លោកអាចពន្យល់ន័យហ្នឹងបានទេ មានន័យថាយ៉ាងម៉េចដែរ? ហើយពាក្យថា កង់ប្រវត្តិសាស្ត្រអីហ្នឹង លោកឮពីណាដែរ ឮពីមាត់ពួកខ្មែរក្រហម ឬក៏ឮពីអ្នកណា?

**ឆ៖** អត់យល់! បាទ ខ្ញុំសូមជម្រាបប្រសាសន៍ អ្នកដែលធ្វើមីទ្ទិងគឺ យាយខុម ប្រពន្ធ មាស មុត ប្រធានស្រុក១០៥ហ្នឹង។ គេដើរធ្វើមីទ្ទិងគ្រប់ឃុំ គ្រប់ស្រុក គេថា “ពួកសក្តិភូមិ នាយទុន ប្រតិកិរិយា ប្រហារអត់ឲ្យសល់ម្នាក់”។ គេដើរធ្វើមីទ្ទិង គេនិយាយតែប៉ុណ្ណឹងទេ “កម្ទេចទាំងរបប កម្ទេចទាំងបុគ្គល” ហើយគេដើរចាប់ហើយ ចាប់តាមដែលគេថាហ្នឹង។

**ស៖** តើលោកដឹងថាវាជាគោលការណ៍ទូទៅទេ ថានៅពេលដែល ខុម និយាយថា ត្រូវតែកម្ទេចពួកប្រតិកិរិយា ពួកនាយទុន ពួកមូលធនហ្នឹង ពួកចក្រពត្តិ ពួកអីហ្នឹង ពួកសក្តិភូមិអីហ្នឹង គាត់និយាយអីចឹង គឺគាត់ទទួលបញ្ជាពីថ្នាក់លើមកឲ្យធ្វើអីចឹង ឬក៏គាត់ធ្វើអីចឹងដោយចិត្តឯងទេ?

**ឆ៖** បាទ អត់ដឹងទេ ដឹងគាត់ទទួលផែនការពីណា គាត់ឲ្យតែធ្វើមីទ្ទិងនិយាយតែទំនុកមួយហ្នឹង។

[១១:១៤:៥២]

**ស៖** តើនៅពេលដែល យាយខុម គាត់ចាកចេញពីស្រុកត្រាំកក់ ហើយមានអ្នកផ្សេងទៀតមកជំនួសគាត់ ដែលធ្វើជាមេស្រុកហ្នឹង <មេ>ផ្សេងទៀតហ្នឹងក៏ប្រើពាក្យដដែល ដូចគាត់ហ្នឹងដែរ ដើម្បីកំណត់ខ្មាំងមែនទេ?

**ឆ៖** បាទ យាយខុម នុ៎ងប្រើទាល់តែដល់រហូតឆ្នាំ៧៦។ តាម៉ុក រកកប់ត្រឹម-ក បររនាស់ជីវាស់គាត់ -- តាម៉ុក ធ្វើមីទ្ទិងផ្ទួនៗបីដង យាយខុម រត់ទៅកោះកុងបាត់ទៅ។ ហើយមានមកក្រោយ គេចប់ -- អាធ្វើមីទ្ទិងចប់អីហ្នឹងអស់ហើយ លែងធ្វើមីទ្ទិង មេអី គេអី គេលែងនិយាយរហូត អស់ពី យាយខុម គេអត់មាននិយាយទេ។

**ស៖** ហេតុអីបានជា តាម៉ុក គាត់ធ្វើមីទ្ទិងហ្នឹង ហើយនៅក្នុងពេលប្រជុំមីទ្ទិងហ្នឹង គាត់និយាយអំពីអ្វីខ្លះ?

**ឆ៖** បាទ គាត់និយាយពីធ្វើទំនប់ ធ្វើប្រឡាយ នៅខ្ពបត្របែកហ្នឹងធ្វើបីដង។ គាត់ថា៖ "អាណាសម្លាប់ជំទប់ ជា? ជំទប់លេខ៣?"។ ជំទប់ហ្នឹងធ្វើការជំនាន់សង្គមរាស្ត្រនិយម ហើយ យាយខុម គាត់លួចសម្លាប់។ ជំទប់ ជា ហ្នឹងគ្តើ តាម៉ុក ។ ហើយដល់ តាម៉ុក បាត់ ព្រួស្សរគេថា "គេសម្លាប់បាត់ហើយ" ដល់អ៊ីចឹង តាម៉ុក ទៅៗមើលគេធ្វើទំនប់ខ្ពបត្របែកហ្នឹង គាត់ធ្វើមីទ្ទិង មនុស្សនៅធ្វើទំនប់ហ្នឹង មួយខេត្តហ្នឹង សុទ្ធតែមនុស្ស។ គាត់ធ្វើមីទ្ទិងថា គេគាត់និយាយពីទំនប់ប្រឡាយហើយ គាត់និយាយពីរឿង "អាណាសម្លាប់ជំទប់ ជា ? អាជំទប់ ជា ហ្នឹងជាមនុស្សស្រី ហេតុអីទៅសម្លាប់វា? វាគិញអីវា វាខ្មាំងអីវា មនុស្សស្រីហ្នឹង។ ឲ្យចៅហ្វាយស្រុកត្រាំកក់ហ្នឹង រកឲ្យឃើញ។ បើរកមិនឃើញទេ ចៅហ្វាយស្រុកហ្នឹង កប់ត្រឹមក បររនាស់ជីវាស់"។ គាត់ធ្វើមីទ្ទិងបីដង យាយខុម ៧៦ រត់ទៅខេត្តកោះកុងបាត់ទៅ។

**ស៖** ខ្ញុំត្រឡប់មកនិយាយអំពីប្រវត្តិរូបឡើងវិញ។ តើគេយកប្រវត្តិរូបហ្នឹងយកទៅរក្សាទុកនៅកន្លែងណា? ទុកនៅក្នុងឯកសារឃុំ ឬក៏ឃុំបញ្ជូនប្រវត្តិរូបហ្នឹងទៅថ្នាក់ស្រុក?

[១១:១៧:៣៨]

**ឆ៖** បាទ រឿងហ្នឹងអត់បានដឹងទេ រឿងប្រវត្តិរូប រឿងអីហ្នឹង អត់ដឹង អត់យល់ផង។ គេមិនដែលឲ្យយើងឃើញ យើងមិនដឹងទេអារឿងអស់ហ្នឹង។

**ស៖** បើតាមការសង្កេតរបស់លោកនោះ អ្នកដែលមានប្រវត្តិរូបមិនល្អ ឬមានប្រវត្តិមិនល្អដូចជាអ្នក១៧មេសាហ្នឹង តើគេតាមដានដោយពួកឈ្លបឃុំ ឬក៏ឈ្លបស្រុកទេ?

**ឆ៖** បាទ កាលនុ៎ងខ្ញុំឃើញគេដើរធ្វើតាមភូមិ តាមឃុំហ្នឹង គឺប្រធានមន្ទីរយុវជនស្រុកគេអ្នកដើរធ្វើបញ្ជី១០០ហ្នឹង។ អាហ្នឹងគេដើរធ្វើប្រធានមន្ទីរ -- ប្រធានយុវជនស្រុក។ គេដើរធ្វើបញ្ជី១០០ សួរពីរឿងនិន្នាការនយោបាយ ធ្វើសព្វគ្រប់ទាំងអស់ហ្នឹង។ ធ្វើបញ្ជីសុំកុមារា កុមារី ពីភូមិ ពីឃុំ យកទៅឲ្យចូលក្នុងបញ្ជី ក្នុងអង្គភាព ក៏គេ -- ប្រធានមន្ទីរស្រុកហ្នឹង គេយកអាបញ្ជីហ្នឹងទៅ។

**ស៖** ពាក់ព័ន្ធទៅនឹងប្រវត្តិរូបនេះ ខ្ញុំនឹងចង់អានសក្ខីកម្មរបស់បុគ្គលម្នាក់ដែលបានឆ្លើយនៅចំពោះមុខអង្គជម្រះនេះ។ គឺមុនដំបូង ខ្ញុំចង់សួរលោកសិន តើលោកស្គាល់ យាយហឿន ហៅ ឃឹម ហឿន ទេ នៅក្នុងស្រុកត្រាំកក់ ឬក៏នៅក្នុងឃុំនៅពេលនុ៎ងនោះ មានស្គាល់ឈ្មោះហ្នឹងទេ?

[១១:១៩:៤៣]

**ឆ៖** បាទ អត់ច្បាស់ សូមអានម្តងទៀត។ ហឿន ឬឈ្មោះអី? ហើយមនុស្សស្រី ឬប្រុស?

**ស៖** គាត់ ជាមនុស្សស្រី។ យាយហឿន –ហ-ឿ-ន– ដែលគាត់ជាមេឃុំ ហើយនិងជាអនុស្រុក នៅពេលនោះ។ លោកស្គាល់គាត់ទេ?

**ឆ៖** បាទ ខ្ញុំបាទស្គាល់ឈ្មោះ យាយហឿន ហ្នឹងប្រពន្ធតាជន។ តាជន មេឃុំពពេល ប្រពន្ធគាត់ឈ្មោះយាយហឿន នៅឃុំក្បាលអូរហ្នឹង -- ឃុំជាងទង ភូមិក្បាលអូរ។ វាធ្វើចៅហ្វាយស្រុកហ្នឹង ខ្ញុំចេញផុតហើយ បានគាត់ឡើងធ្វើចៅហ្វាយស្រុកជាមួយ គ្រូអ៊ួច ហ្នឹង។

**ស៖** នៅពេលដែលលោកនិយាយថា “មេស្រុក” ហ្នឹង លោកសំដៅទៅលើសមាជិកគណៈស្រុក ឬក៏ជាលេខាស្រុក?

**ឆ៖** ស្តាប់អត់បានត្រង់ហ្នឹង។ យាយហឿន ឡើងទៅធ្វើចៅហ្វាយស្រុក តាជឹម, តាចាយ, សោម ដន ចេញផុតអស់ហើយ ទៅឆ្នាំ៧៧ ខែ៨ ហ្នឹងគឺធ្វើអនុស្រុកជាមួយ គ្រូអ៊ួច។ គ្រូអ៊ួច គាត់ប្រធាន, យាយហឿន អនុ ហើយមិនដឹងនរណាទៀតទេ ប៉ុនថាអត់ដឹងទេ។

[១១:២១:៣៣]

**ស៖** គាត់បានផ្តល់សក្ខីកម្មនៅក្នុងសប្តាហ៍នេះ <គាត់គឺជាអតីត>មេឃុំជាងទង និងអនុស្រុកត្រាំកក់នៅចម្លើយ២៥៤ និង២៥៥ គឺ E ឯកសារ E319/12.3.2 គាត់បានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះថាឯកសារនេះមិនត្រូវបានបកប្រែជាភាសាបារាំងទេ។

“ពេលដែលមេឃុំចាប់ផ្តើមប្រមូលប្រវត្តិរូបពីប្រជាជន ហើយរកឃើញថាអ្នកណាម្នាក់ជាប់ពាក់ព័ន្ធរបបលន់ នល់ តើមានអ្វីកើតឡើងចំពោះអ្នកដែលគេរកឃើញថាជាប់ពាក់ព័ន្ធនឹងរបបលន់នល់

នោះ?" ហើយយាយបឿន ក៏ឆ្លើយថា៖ នៅពេលចាប់ផ្តើមចាប់ផ្តើមរបបខ្មែរក្រហមភ្លាម គឺចាប់ផ្តើមធ្វើប្រវត្តិរូបថា អ្នកណាខ្លះធ្លាប់ធ្វើជាគ្រូបង្រៀន អ្នកណាជាប៉ូលិស ឬក៏ជាមន្ត្រីរាជការនៅក្នុងរបបលន់ នល់។ បន្ទាប់មកបញ្ជូនប្រវត្តិរូបទាំងអស់នោះទៅខាងលើ។ នេះគឺជាបញ្ជាពីខាងលើមកឲ្យខ្ញុំធ្វើដូច្នេះ"។ "សំណួរទី២៥៥៖ តាមអ្វីដែលលោកស្រីដឹង តើមានអ្វីកើតឡើងចំពោះអ្នកដែលជាប់ពាក់ព័ន្ធនឹងរបបលន់ នល់? ហើយយាយបឿន ក៏ឆ្លើយថា៖ ក្រោយបញ្ជូនប្រវត្តិរូបទៅខាងលើហើយ ខាងលើបានស្រង់ឈ្មោះអ្នកទាំងនោះមកឲ្យខ្ញុំ បន្ទាប់មក ខ្ញុំបញ្ជាឲ្យគេដើរចាប់អ្នកទាំងអស់នោះ រួចបញ្ជូនទៅខាងលើវិញ។ មានអ្នកខ្លះក៏បានត្រឡប់មកវិញ ហើយអ្នកខ្លះក៏មិនបានត្រឡប់មកវិញទេ មនុស្សដែលត្រូវចាប់ខ្លួន ភាគច្រើនគឺជាទាហាន និងប៉ូលិស គ្រូបង្រៀនមិនសូវត្រូវបានបញ្ជូនទៅនោះទេ"។ សូមបញ្ចប់ការដកស្រង់។

[១១:២៣:៤៤]

នេះគឺជាចម្លើយរបស់ យាយបឿន ពាក់ព័ន្ធទៅនឹងការធ្វើប្រវត្តិរូប និងការចាប់ខ្លួនអតីតប៉ូលិស ទាហាន និងគ្រូបង្រៀននៅឃុំជាងទង។ តើការឆ្លើយរបស់ យាយបឿន ពាក់ព័ន្ធទៅនឹងរបៀបធ្វើការបែបនេះនោះ វាដូចគ្នាទៅនឹងអ្វីដែលលោកបានធ្លាប់ស្តាប់ឮនៅឃុំផ្សេងទៀតនៅស្រុកត្រាំកក់នៅសម័យនោះដែរឬទេ? តើគេធ្វើរបៀបដូចគ្នាអ៊ីចឹងទេ? គឺមានន័យដំបូង គេធ្វើប្រវត្តិរូបសិន បន្ទាប់មកបញ្ជូនអ្នកទាំងហ្នឹងទៅថ្នាក់លើ ក្រោយមកថ្នាក់លើបញ្ជូនមកខាងឃុំវិញ ហើយខាងឃុំក៏ចាប់មនុស្សឲ្យថ្នាក់លើ តើលោកធ្លាប់ឮពីវិធីធ្វើការបែបហ្នឹងទេ?

**ឆ៖** បាទ រឿងហ្នឹងវាប្រជាជនសុទ្ធសាធ វាអត់បានដឹងជ្រៅជ្រះដល់ហ្នឹងទេ ទាល់គេអ្នកធ្វើការបានគេដឹង គេធ្លាប់ធ្វើ ហើយខ្ញុំជាប្រជាជនគេអត់ៗឲ្យដឹងត្រឹមហ្នឹង ដំណើរអស់ហ្នឹងទាំងអស់។

**ស៖** ខ្ញុំនិយាយនេះ គឺខ្ញុំយោងទៅលើមុខតំណែងរបស់លោកនៅមន្ទីរស្រុក ទោះបីជាលោកមិនមែនជាកម្មាភិបាលក៏ដោយ ក៏ប្រហែលជាលោកអាចបានស្តាប់ឮ<គេនិយាយគ្នាដែរ>នៅពេលដែលលោកធ្វើការនៅក្នុងមន្ទីរស្រុកហ្នឹងជាមួយនឹងកម្មាភិបាលផ្សេងៗដែលលោករាប់អានគ្នានោះ។ ឧទាហរណ៍ កម្មាភិបាលឈ្មោះរស់ ឈ្មោះភី ឈ្មោះឃន ឬក៏ប្អូនជីដូនមួយរបស់លោកឈ្មោះ ដន នោះគាត់ធ្លាប់បាននិយាយអំពីរបៀបនៃការកំណត់អត្តសញ្ញាណមនុស្ស ហើយមានការចាប់ខ្លួនបែបហ្នឹងធ្លាប់និយាយអ៊ីចឹងប្រាប់លោកទេ?

[១១:២៥:៤១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ រឿងហ្នឹងវាជាការពិតណាស់ ព្រោះខ្ញុំនៅក្នុងមន្ទីរហ្នឹង ឃើញគេចាប់វាយទាហានបន្ទាយបែកក៏គេបញ្ជូនទៅឱ្យអង្គការស្រុក។ ហ៎! ពីឃុំមានឈ្មោះអីដែលគេត្រូវចាប់ គឺគេមានពីៗលើមកគេសរសេរដូចថាឈ្មោះ"ក" នៅភូមិត្រពាំងធំហ្នឹង ឃើញឈ្មោះបញ្ជីគេមកពីលើមក នេះគេឱ្យចាប់ឈ្មោះ "ក" ហ្នឹង គេសរសេរឈ្មោះ "ក" ហ្នឹង ជាវង្វង់ក្រចកទឹកប៊ិកក្រហម ឃើញវង្វង់ក្រចកទឹកប៊ិកក្រហមហ្នឹងគេមានកងទ័ពស្រុកទៅនាំយកមកឱ្យស្រុក។ នាំយកមកឱ្យស្រុកៗឱ្យកម្លាំងនាំយកទៅឱ្យអង្គការស្រុកគឺ យាយខុម។ អាហ្នឹងឃើញអ៊ីចឹងដែរហ្នឹង ឃើញការពិតអ៊ីចឹង។

**ស៖** តើលោកអាចជម្រាបបានទេ ថាអ្នកដែលគេចាប់បាននោះ ហើយដែលសម្រាប់នាំទៅស្រុកហ្នឹង<>គេទុកនៅកន្លែងណាដែរ? គេមានមន្ទីរឃុំឃាំងមួយ <ឬកន្លែងពិសេស>សម្រាប់ឃុំអ្នកដែលគេចាប់ខ្លួនបានទេ មុននឹងបញ្ជូនទៅស្រុកហ្នឹង?

**ឆ៖** បាទ តែគេចាប់ហើយ តែវង្វង់ក្រចកទឹកប៊ិកក្រហមហើយ គេយកទៅសម្លាប់ភ្លាមអត់ឱ្យឈប់ ឈប់ម្តប់ អត់ឱ្យស៊ីទឹកផឹកក៏អត់ឱ្យដែរ។ ហើយបើចាប់អាមនុស្ស ដូចថាប្រពន្ធគេទៅធ្វើទ័ពអីអ៎! ប្តីគេទៅធ្វើទ័ព ប្រពន្ធនៅខាងក្រោយអាមនុស្សក្នុងភូមិនុ៎ងឯងទៅរំលោភប្រពន្ធគេៗ ចាប់យកមកដាក់សាលាកែប្រែឱ្យជាប់គុកពីបីខែ ទៅប្រាំមួយខែ អាហ្នឹងគេលែងវិញ។ អាហ្នឹងគេមានកន្លែងយកមកដាក់ សាលាកែប្រែហ្នឹង។ ដល់អាវង្វង់ក្រចកទឹកប៊ិកក្រហមហ្នឹង អត់មានតុលាការណាកាត់ក្តីឱ្យត្រឡប់ក្រោយវិញបានទេ ត្រូវយកឱ្យកងប្រវត្តិសាស្ត្រគេកិនហើយ។

[១១:២៧:៤២]

**ស៖** យើងនឹងនិយាយអំពីប៊ិកខៀវ ប៊ិកក្រហមនេះក្រោយពេលសម្រាក។ ក៏ប៉ុន្តែពាក់ព័ន្ធនឹងអ្នកដែលគេយកទៅអប់រំនេះ តើគេមានបញ្ជូនទៅមន្ទីរអប់រំណាមួយសិនទេ? ហើយអ្នកហ្នឹងមានសិទ្ធិដើរហើរ ដោយសេរីទេ? ឬក៏គេឃុំទុកនៅមួយកន្លែងណាមួយសម្រាប់អប់រំអ្នកដែលគេចាប់បានហ្នឹង?

**ឆ៖** បាទ អ្នកដែលមានប្រវត្តិរូប វង្វង់ទឹកប៊ិកក្រហម វង្វង់ក្រចកទឹកប៊ិកក្រហមហើយ អត់មានយកដាក់សាលាកែប្រែទេ គេបញ្ជូនទៅបាត់ហើយ។ បើចំពោះអ្នកខូចប្រពន្ធកូនគេនៅខាងក្រោយហ្នឹងគេមានកន្លែងសាលាគេកែប្រែ យកមកដាក់ឃុំឃាំង។ ឃុំឃាំងពីបីខែទៅប្រាំមួយខែ គេលែងវិញហើយ អាហ្នឹងគេអត់ធ្វើអីទេ។ ខុសតែអ្នកនយោបាយ ដែលមានបញ្ហាវង្វង់ក្រចកទឹកប៊ិកក្រហមហើយបាត់ខ្លួន ហើយគេបញ្ជូនទៅបាត់ហើយអត់ដែលឃើញត្រឡប់មកវិញទេ។

**ស៖** អ្នកដែលត្រូវបានគេបញ្ជូនទៅអប់រំកែប្រែក្នុងរយៈពេល បីខែ ប្រាំមួយខែហ្នឹង លោកដឹង

ថាគេយកទៅអប់រំនៅកន្លែងណាទេ? កន្លែងដែលពួកគេត្រូវ<បញ្ជូនទៅ>ធ្វើការដូចប្រជាជនធម្មតា ឬក៏ជាកន្លែងមួយដែលថា គេឃុំអ្នកទាំងអស់នោះពេលយប់? លោកធ្លាប់ឮកម្មាភិបាលឬក៏ប៉ូលិស មន្ទីរស្រុកនិយាយ អំពីរឿងហ្នឹងទេ?

[១១:២៩:២៥]

**ឆ៖** បាទឃើញនឹងភ្នែកហ្នឹង។ គេយកមកដាក់នៅជិតមន្ទីរអង្គរកាហ្នឹង មន្ទីរស្រុកហ្នឹង។ ថ្ងៃឡើងគេឲ្យរែកដីឲ្យគ្នាគេហ្នឹង ដល់យប់ចូលមកកន្លែងគេ កន្លែងឃុំឃាំងវិញ អ្នកណាធ្វើការល្អ អត់ដល់បីខែគេឲ្យទៅវិញហើយ។ អ្នកដែលធ្វើការរាងខ្ជិល រាងច្រអូស អត់ -- ចេះតែអង្គុយ ចេះតែឈប់អាហ្នឹងឡើងប្រាំមួយខែ។ បើធ្វើការល្អតែមួយខែកន្លះ -- កន្លះខែអីហ្នឹង ក៏ទៅវិញអស់ទៅ។ ឃើញធូរត្រង់ហ្នឹង។

**សៈ** លោកនិយាយអំពី<កន្លែងដែលលោកធ្វើការ គឺ>អង្គរកាអម្បាញ់មិញនេះ ដូច្នេះខ្ញុំសន្និដ្ឋានថា<>មន្ទីរស្រុកនៅអង្គរកា។ តើមន្ទីរស្រុក និងមន្ទីរគណៈស្រុកហ្នឹងមានចម្ងាយពីគ្នាប៉ុន្មានដែរ មានមន្ទីរពីរផ្សេងគ្នា ឬក៏ជាមន្ទីរតែមួយទេ មន្ទីរស្រុក និងមន្ទីរឬគណៈស្រុក?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ គណៈស្រុក គឺគាត់មានផ្ទះគាត់នៅឆ្ងាយពីមន្ទីរស្រុកហ្នឹង។ ទាំងបីនាក់ហ្នឹងអត់មានមកជាប់នៅកន្លែងស្រុកហ្នឹងទេ មានតែប្រធានមន្ទីរទេនៅជាប់ទាំងយប់ ទាំងថ្ងៃ។ ផ្ទះគាត់នៅឆ្ងាយ ហើយមន្ទីរសាលាកែប្រែហ្នឹង ក៏នៅជាប់មន្ទីរហ្នឹងដែរ។ ហើយមន្ទីរស្រុកហ្នឹងមានតែមួយទេ អត់មានពីរ មានបីទេ។ កន្លែងឃ្លាំងភស្តុភារ សម្ភារៈអីក៏នៅហ្នឹង។ សោម ដន ក៏នៅជាប់មន្ទីរសម្ភារៈភស្តុភារហ្នឹង។

[១១:៣១:១១]

**សៈ** តើមន្ទីរស្រុកហ្នឹង គេហៅថាជាមន្ទីរពាណិជ្ជដែរទេនៅពេលនុ៎ង?

**ឆ៖** បាទ កាលជំនាន់នោះ គេហៅថាមន្ទីរពាណិជ្ជកម្ម។ ទូទៅហើយ គេហៅថាមន្ទីរពាណិជ្ជកម្មហ្នឹង គឺកន្លែងគេចែកចាយសម្ភារៈសព្វមុខទាំងអស់ហ្នឹង ហើយប្រធានមន្ទីរក៏នៅហ្នឹង ចៅហ្វាយស្រុកក៏ចេញចូលហ្នឹងជាប់ដែរ។ ហើយមានតែមួយ អត់មានពីរ អត់មានបីទេ។

**សៈ** <ប្រហែលនេះគឺជា>សំណួរចុងក្រោយ លោកនិយាយអំពីមន្ទីរអប់រំនៅជិតមន្ទីរស្រុកនៅអង្គរកា។ តើមន្ទីរអប់រំកែប្រែនេះស្ថិតនៅចម្ងាយប៉ុន្មានរយម៉ែត្រ ពីរបីរយម៉ែត្រខាងលិចផ្សារអង្គរកាមែនទេ?

**ឆ៖** បាទ មែនហើយ ប្រហែលជា៣០០ម៉ែត្រហ្នឹង។ ហ្នឹងឆ្ងាយពេកផង ៣០០ម៉ែត្រហ្នឹង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដល់ពេលសម្រាកពេលថ្ងៃត្រង់ ហើយមុននឹងសម្រាក អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងសហព្រះរាជអាជ្ញា និងភាគីនៃរឿងក្តីអំពីសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានលើកឡើងកាលពីព្រឹកមិញ ដែលសុំឲ្យអង្គជំនុំជម្រះស្តាប់សារណារបស់ភាគីពាក់ព័ន្ធនឹងការផ្អែកលើមូលដ្ឋាននៃសក្ខីកម្ម ដែលបានមកពីការធ្វើទារុណកម្មមកប្រើប្រាស់ជាមូលដ្ឋានក្នុងការពិភាក្សាដេញដោលនោះ សហព្រះរាជអាជ្ញា និងភាគីពាក់ព័ន្ធនឹងទទួលបានព័ត៌មានលម្អិតពីសំណើនេះ តាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងពេលឆាប់ៗខាងមុខនេះ។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អង្គជំនុំជម្រះអរគុណចំពោះលោក ឯក ហឿន។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ សូមលោកសម្រាកចុះ ហើយអង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មទៀតនៅរសៀលនេះ ចាប់ផ្តើមនៅវេលាម៉ោងមួយកន្លះ សូមលោកជ្រាប។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣២:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោក ឯក ហឿន!

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ យើងចាប់ផ្តើមបន្តកិច្ចដំណើរការសវនាការរបស់យើងតទៅទៀត។ សូមលោករង់ចាំស្តាប់សំណួរ ហើយនិងឆ្លើយតបទៅនឹងសំណួរដែលបន្តិចទៀតអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរចំពោះលោក។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន ហើយជម្រាបសួរជាថ្មីម្តងទៀតលោកប្រធាន លោក លោកស្រីចៅក្រម។ លោកសាក្សីខ្ញុំគិតថា លោកមានពេលបានសម្រាកគ្រប់គ្រាន់ហើយ ខ្ញុំនឹងបន្តសួរលោកតទៅទៀត ហើយខ្ញុំសុំឲ្យលោកធ្វើដូចកាលពីព្រឹកមិញអ៊ីចឹង គឺថាសុំឲ្យលោកឆ្លើយដោយស្មោះត្រង់ <និងច្បាស់ៗ>ទៅនឹងសំណួររបស់ខ្ញុំ ហើយសុំឆ្លើយឲ្យខ្លីៗ។

**សួរដោយ លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** មុនពេលឈប់សម្រាក យើងនិយាយអំពីមន្ទីរអប់រំកែប្រែមួយដែលស្ថិតនៅអង្គរកាប្រហែលជា៣០០ម៉ែត្រពីមន្ទីរស្រុក។ តើលោកដឹងទេថាអ្នកណាជាអ្នកដឹកនាំមន្ទីរអប់រំកែប្រែនោះ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ប្រធានសាលាកែប្រែហ្នឹងឈ្មោះ ម៉េង ប៉ុន្តែមិនដឹងថា ម៉េងហ្នឹងវានៅរស់ ឬក៏ទៅនៅកន្លែងណាអត់បានដឹងទេ។ បែកគ្នាពី៧៨ ខែ៨ រហូតមកទល់ថ្ងៃនេះ អត់ដែលជួបគ្នា។

**ស៖** អម្បាញ់មិញនេះលោកនិយាយថា រស់ ធ្វើការនៅមន្ទីរស្រុក។ គាត់ជាកម្មាភិបាល<>ឈ្លបដែលទទួលបន្ទុកក្នុងការចាប់ចងមនុស្ស។ តើ រស់ នេះធ្វើការញឹកញាប់ជាមួយនឹង ម៉េង ទេ នៅមន្ទីរ<>អប់រំកែប្រែហ្នឹង?

**ឆ៖** បាទ ពេលឡានឲ្យដឹកសម្ភារៈមក គេប្រើឲ្យទៅដឹកសម្ភារៈនៅខេត្ត។ គេប្រើឲ្យទៅដឹកទឹក

ត្រីនៅកំពង់អំពិល អន្លង់ទាន យកមកចែកសហករណ៍។

**ស៖** ចុះពាក់ព័ន្ធនឹងការចាប់ចងមនុស្ស ហើយនិងការអប់រំកែប្រែនៅមន្ទីរ នៅជិតអង្គរកាន់ុង តើរស់ គាត់ទៅជួប ម៉េង ញ៉ឹកញាប់ទេ នៅទីនោះដើម្បីពិភាក្សាគ្នាអំពីបញ្ហាសន្តិសុខនោះ? លោកដឹងរឿងហ្នឹងទេ?

[១៣:៣៦:១០]

**ឆ៖** បាទ ឃើញច្បាស់នឹងភ្នែកហ្នឹងព្រោះតែក្នុងឃុំគេមានមនុស្សខូចរឿងសីលធម៌ស្រីប្រុសអីហ្នឹង មេឃុំគេចាប់យកប្រគល់ឲ្យអង្គការស្រុក។ អង្គការស្រុកឲ្យគេបញ្ជូនទៅដាក់សាលាកែប្រែរបស់លោក ម៉េង ហ្នឹង។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកនិយាយថា ការអប់រំកែប្រែហ្នឹងគឺថាមានរយៈពេលបីទៅប្រាំមួយខែនៅមន្ទីរហ្នឹង។ អ៊ីចឹង តើលោកធ្លាប់ឮអ្នកធ្វើការនៅមន្ទីរស្រុក ឬឈ្លបនិយាយថាអ្នកដែលត្រូវបានអប់រំកែប្រែនៅកន្លែងរបស់ ម៉េង ហ្នឹងត្រូវបានបញ្ជូនទៅកន្លែងផ្សេង ឬក៏ត្រូវបានសម្លាប់ចោល? លោកធ្លាប់ឮខាងឈ្លប ឬក៏កម្មាភិបាលនៅមន្ទីរស្រុកហ្នឹងនិយាយគ្នាអំពីរឿងហ្នឹងទេ?

**ឆ៖** បាទ អត់ពិតទេកន្លែងហ្នឹង។ ខ្ញុំឃើញតែ ខ្លះគេថា តែមួយខែកន្លះហ្នឹងគេយកមកអប់រំមួយម៉ាត់ពីរម៉ាត់។ គេថា “មិត្តឯងល្អ ខំជួយធ្វើការអត់ប៉ាននយប់ មិត្តឯងត្រូវទៅសហករណ៍វិញទៅ”។ គេឲ្យទៅផ្ទះវិញទៅបានមួយខែកន្លះហ្នឹង។ បាទ តែប៉ុណ្ណឹងទេ។ អត់មានសម្លាប់ អត់មានយកទោសពៃរ៍អីទេ ទុកសាលាកែប្រែហ្នឹង។

**ស៖** ចុះលោកផ្ទាល់ បន្ទាប់មកទៀតហ្នឹងលោកធ្លាប់ឃើញអ្នកទោសហ្នឹងឡើងវិញទេ? គេមានបញ្ជូនទៅផ្ទះវិញទេ? ហើយឧទាហរណ៍ដូចជា ក្រោយឆ្នាំ៧៩ <តើលោកដែលឃើញពួកគេទៀតទេ>?

**ឆ៖** បាទ អត់បានឃើញអីទាំងអស់។

**ស៖** តើលោកធ្លាប់ឮគេនិយាយអំពីមន្ទីរ២០៤ ទេ នៅស្រុកត្រាំកក់?

**ឆ៖** មន្ទីរ១០៩ បាទ អត់បានៗដែលឮទេ មន្ទីរហ្នឹងមិនដឹងនៅឯណា។

**ស៖** ខ្ញុំនិយាយម្តងទៀត។ ខ្ញុំនិយាយពីមន្ទីរ២០៤ មិនមែននិយាយពីមន្ទីរ១០៩ទេ លោកស្តាប់ច្រឡំហើយ។ ខ្ញុំចង់ដឹងថា តើលោកស្គាល់មន្ទីរ២០៤ ទេ?

[១៣:៣៩:០៥]

**ឆ៖** បាទ ស្គាល់។ ប្រជាជនដែលបញ្ជូនមកចែកតាមស្រុកតាមឃុំទៅវាសល់ សល់គេបញ្ជូន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យកដាក់គុក២០៤។ គុកហ្នឹងគេធ្វើបាប កន្លែងធ្វើបាបមនុស្ស។ យប់ឡើង ថ្ងៃឡើង គេឲ្យគ្រប់ក្រុមទាំងអស់ទៅយាម ហើយអ្នកយាមហ្នឹងគឺទៅកាប់ដើមឈើធំតូចអីទៅ កាប់រំលំ កាប់ចម្ការ ហើយមួយវេនហ្នឹងកាប់មិនដាច់ មានវេនលើកទី២គេទៅកាប់បន្តទៀត។ លើកទី២ មិនដាច់ លើកទី៣ទៅកាប់បន្តទៀតបានដាច់ ហើយដាច់ទៅគឺវេនហ្នឹងរហូតតាំងពី៧៥ ហ្នឹងមកទល់គ្នាហ្នឹង ៧៩ យួនចូលស្រុកហ្នឹងបានគេរលំរលាយអស់។ ហើយហូបគ្រប់ចុកអី អត់មានអីហូបទេ។ ស្លាប់នោះស្លាប់ មហាស្លាប់។ ២០៤ ហ្នឹងគេធ្វើនៅព្រៃក្តួច ដែលហៅថា "អូរចោទ" នៅផុតទឹកដីពីភូមិស្រែចម្ការប្រជាជន។ គឺកណ្តាលព្រៃភ្នំ ព្រៃហោង ហិនហោង ដាច់ពីភូមិពីស្រុកហើយ។

**ស៖** តើលោកធ្លាប់ឮទេ ថាក្រៅពីស្លាប់ដោយសារការខ្វះអាហារហ្នឹង អ្នក<ដែលគេត្រូវគេឃុំឃាំង>នៅកន្លែងហ្នឹងត្រូវបានគេសម្លាប់ចោល។ លោកធ្លាប់ឮអីចឹងទេ?

**ឆ៖** បាទ អត់ដែលឮទេ គឺស្លាប់ៗអត់មានអ្នកណាកប់អ្នកណាអីទេ វាស្លាប់ចោលៗក្នុងព្រៃហ្នឹង គ្មាននរណាគិតគូទេ។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីរយៈកាលជាក់លាក់គឺពីខែមេសា ទៅដល់ខែឧសភា ឆ្នាំ១៩៧៧ គឺចុងរដូវប្រាំងនៅឆ្នាំ១៩៧៧។ តើលោកចាំទេថានៅរដូវហ្នឹង គឺពេលណាមួយនោះអ្នកបណ្តាស័ក្តិទាហាន<អ្នករដ្ឋការ>ក្នុងរបប លន់ នល់ ហ្នឹងត្រូវបានគេកំណត់គោលដៅ<ម្តងទៀត> ហើយគេស្វែងរកហើយគេប្រមូលយកមកដាក់ម្តុំ។ តើមានអីចឹងទេ?

**ឆ៖** បាទ អត់មានកន្លែងប្រមូលដាក់កន្លែងម្តុំទេ។ ជាការពិត គឺរកឃើញអ្នកមានបណ្តាស័ក្តិហើយ គឺគេបញ្ជូនទៅឲ្យអង្គការស្រុក។ អង្គការស្រុកគេបញ្ជូន -- មានកម្លាំងគេមួយក្រុមនៅការពារកន្លែងហ្នឹង តែគេបញ្ជូនទៅដល់យប់ គេយកទៅដាក់នៅព្រៃទាំងយប់ បញ្ជូនទៅទាំងថ្ងៃគេយកទៅទាំងថ្ងៃហ្នឹង អត់មានកន្លែងឈប់កន្លែងសម្រាកទេ។ គឺអង្គការ ខុម ហ្នឹង។

[១៣:៤២:២១]

**ស៖** អ៊ីចឹងរយៈកាលហ្នឹងគឺជារយៈកាលតឹងតែងមែនទែនពាក់ព័ន្ធទៅនឹងការ<ងារនៅ>មន្ទីរស្រុក។ <តាមខ្ញុំយល់បានត្រឹមត្រូវ> ហេតុអ្វីបានជានៅរយៈកាលហ្នឹងមានការកំណត់អត្តសញ្ញាណនិងមានការចាប់ខ្លួនអ្នកបណ្តាស័ក្តិក្នុងសម័យ លន់ នល់ ក្នុងទ្រង់ទ្រាយធំយ៉ាងហ្នឹងនោះ? តើមានការបញ្ជាពីថ្នាក់លើមកពាក់ព័ន្ធទៅនឹងការងារហ្នឹងទេ?

**ឆ៖** បាទ កន្លែងហ្នឹងអត់បានដឹងទេ ព្រោះគេមានពាក្យស្លោករបស់គេ គេថា "កម្មេចឲ្យអស់

ពួកសក្ដិភូមិ នាយទុន ប្រតិកិរិយា ប្រហារអត់ឲ្យសល់ម្នាក់ កម្ទេចទាំងរបប កម្ទេចទាំងបុគ្គល” គេថា តែប៉ុណ្ណឹង គេធ្វើតាមទិសហ្នឹងទៅ។

**ស៖** តើប្រតិបត្តិការហ្នឹងប្រព្រឹត្តិទៅយ៉ាងម៉េចឲ្យបានប្រាកដទៅ? គឺឃុំជាអ្នកនាំអ្នកដែលគេកំណត់អត្តសញ្ញាណហ្នឹងបានទៅឲ្យស្រុក ឬក៏ល្អបស្រុកទេអ្នកមករកមនុស្សហ្នឹងនៅតាមឃុំនោះ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ គឺឃុំក៏អត់បានដឹងទេ រឿងអស់ហ្នឹងគឺកងទ័ពស្រុកគេដឹងឈ្មោះ ស្រុកបង្ហាញឈ្មោះហើយ កងទ័ពគេៗប្រាប់ឲ្យទៅចាប់ឈ្មោះ “ក”។ ស្រុក កងទ័ពស្រុកគេ គេចាប់ឈ្មោះ “ក” ហ្នឹង ចាប់បញ្ជូនឲ្យយាយ ខុម ហ្នឹងតែម្ដង។

[១៣:៥៤:១២]

**ស៖** លោកនិយាយអំពីបញ្ជីឈ្មោះ គឺមានន័យថាគេចាប់ខ្លួនផ្អែកទៅលើបញ្ជីឈ្មោះ។ អ៊ីចឹងអ្នកណាជាអ្នកធ្វើបញ្ជីអតីតមន្ត្រីរដ្ឋការ និងទាហាន លន់ លន់ នេះ?

**ឆ៖** បាទ កាលជំនាន់ដែលធ្វើបញ្ជីហ្នឹងមានកម្លាំងគេដូចថាប្រធានយុវជនស្រុក គេអ្នកដើរធ្វើបញ្ជី១០០ហ្នឹង។ ដល់ដើរធ្វើបញ្ជី គេស្រាវជ្រាវទៅឃើញអ្នកហ្នឹងថាឈ្មោះ “ក” ហ្នឹងមានបណ្ដាស័ក្តិជំទប់ ឬ/និង មេឃុំ មេភូមិអីហ្នឹង គេធ្វើបញ្ជីរាយទៅរាយការណ៍មកអង្គការស្រុក។ អង្គការស្រុករាយទៅអង្គការខេត្ត។ ហើយមិនដឹងអង្គការខេត្តហ្នឹងរាយទៅណាទៀត បានបញ្ជីហ្នឹងត្រឡប់ចុះទៅក្រោមវិញ។ ដូចថាឈ្មោះ “ក” ហ្នឹង គេសម្រេចថាឲ្យយកទៅសម្លាប់ ហើយគេវង្វង់ក្រចក ទឹកប៊ិកក្រហម។ តែវង្វង់ក្រចកទឹកប៊ិកក្រហមគេផ្ញើមកឲ្យស្រុកហើយ ស្រុកផ្ញើទៅឲ្យកងទ័ពស្រុកហ្នឹង កងទ័ពស្រុកចារឈ្មោះ “ក” ហ្នឹង យកទៅប្រគល់ឲ្យយាយ ខុម។

**ស៖** ឥឡូវនេះ ខ្ញុំសូមអាន<ឲ្យលោកស្ដាប់នូវ>របាយការណ៍មួយ ឬពីរដែល<ត្រូវ>បាន<សរសេរដោយកម្មាភិបាលថ្នាក់ឃុំទៅជំនាន់នោះ>។ ខ្ញុំ<>សុំ<មិន>ឲ្យលោកពិនិត្យមើលឯកសារទាំងអស់ទេ ប្រហែលជាវាស្មុគស្មាញ។ ជាដំបូង ខ្ញុំសូមលើកឧទាហរណ៍គឺឯកសារ E3/2048។ ទំព័រជាភាសាខ្មែរគឺ 00079089, ជាភាសាអង់គ្លេសគឺ 00276562 ទៅដល់ 63, ជាភាសាបារាំងគឺនៅទំព័រទីពីរ ERN 00611659។ នេះជារបាយការណ៍របស់យាយ បឿន ដែលយើងបាននិយាយគ្នាអម្បាញ់មិញនេះពីឃុំជាងទងផ្ញើនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ជូនថ្នាក់ដឹកនាំអង្គការស្រុកត្រាំកក់ដែលបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់៖ “សកម្មភាពខ្មាំងនៅក្នុងមូលដ្ឋានយើងខ្ញុំ ក្រោយពីបានទទួលការណែនាំជាបន្តបន្ទាប់ពីអង្គការក្នុងការប្រុងប្រយ័ត្នខ្មាំង បោសសម្អាតពួកទាហានខ្មាំងដែលមានបណ្ដាស័ក្តិក្នុងនោះ

យើងបានតាមដានពិនិត្យឃើញមានឈ្មោះ ដូចខាងក្រោមនេះ”។ បន្ទាប់មករបាយការណ៍នេះ បានរៀបរាប់ឈ្មោះ និងឋានន្តរសក្តិរបស់អតីតទាហានលន់នល់ពីរនាក់។ នៅក្នុងឯកសារដដែលនេះ E3/2048 ពីរទំព័របន្ទាប់មកទៀតមកគឺជាភាសាខ្មែរ 00079091, ជាភាសាអង់គ្លេស 00276564, ជាភាសាបារាំង 00611661 គឺនៅទំព័រទី៤ គឺជារបាយការណ៍មួយទៀតមកពីឃុំតាភេម ផ្ញើជូនក្នុងរយៈកាល<ដូចគ្នា>គឺថ្ងៃទី២៨ មេសា ឆ្នាំ១៩៧៧ ដែលបានរាយការណ៍ថា ឃុំបាន -- ខ្ញុំសូមដកស្រង់៖ “បន្ទាប់ពីបានពិនិត្យ និងបោសសម្អាតខ្មាំងដែលមានបណ្តាស័ក្តិក្រោយពីបានទទួលមតិណែនាំរបស់បក្ស”។ សូមបញ្ចប់ការដកស្រង់។ <លោកសាក្សី ខ្ញុំ>មានឧទាហរណ៍ជាច្រើនទៀតដែលជារបាយ-ការណ៍របៀបនេះ ដែលធ្វើការនៅ<ចុង>ខែមេសា ឬក៏<ដើមខែ>ឧសភា ឆ្នាំ១៩៧៧ ដែលយើងមាននៅក្នុងសំណុំរឿង។ បើតាមរបាយការណ៍ទាំងនេះ យើងនិយាយអំពីការណែនាំរបស់បក្ស។ តើលោកធ្លាប់ឮទេថា មានការណែនាំពីថ្នាក់ស្រុកបញ្ជូនទៅឲ្យឃុំពាក់ព័ន្ធទៅនឹងការចាប់អ្នកដែលមានបណ្តាស័ក្តិនេះ?

[១៣:៤៨:៥៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមធ្វើការកត់សម្គាល់ទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញារងទៅនឹងឯកសារដែលលោកលើកថា ជាឯកសាររបស់ យាយហឿន។ ហើយក្នុងសវនាការកន្លងទៅនេះ យាយហឿន គាត់បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះហើយថា មិនមែនជាឯកសាររបស់គាត់ទេ គ្រាន់តែថាមានឈ្មោះគាត់ ឈ្មោះហឿន នៅចុះហត្ថលេខា ដែលមានឈ្មោះ ហឿន នៅពីខាងក្រោម។ ហើយហេតុដូច្នេះ ខ្ញុំសូមកុំឲ្យមានការយល់ច្រឡំថា វាជាឯកសាររបស់ យាយហឿន គ្រាន់តែជាឯកសារមួយដែលមានឈ្មោះ យាយហឿន នៅក្នុងឯកសារនោះតែប៉ុណ្ណោះ។ គឺឯកសារ E3/2048 នេះ សូមអរគុណ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ <វាមិនដូច្នេះទេ គឺ>វាពិតជារបាយការណ៍ដែលយើងឃើញថាធ្វើឡើងដោយឈ្មោះ ហឿន នៅឃុំជាងទង។ សាក្សី យាយហឿន គាត់មិនបាននិយាយថាជាឯកសារក្លែង

ក្លាយទេ គ្រាន់តែគាត់ថា<>គាត់មិនបានចុះហត្ថលេខាលើឯកសារនេះ។

[១៣:៥០:២៤]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី បើតាមពិនិត្យមើលឯកសារនេះ គឺថាឃុំបានដឹងអំពីវិធីនៃការកំណត់អត្ត-សញ្ញាណ និងចាប់ខ្លួនអ្នកមានបណ្តាស័ក្តិនៅសម័យ លន់ នល់។ ខ្ញុំចង់ដឹងថាតើឃុំបានទទួលការណែនាំពីថ្នាក់ស្រុកពាក់ព័ន្ធទៅនឹងបញ្ហាហ្នឹងទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ស្រុកទទួលផែនការពីអង្គការខេត្ត អង្គការខេត្តដាក់មកឲ្យស្រុក ស្រុកដាក់ទៅឲ្យឃុំតែប៉ុណ្ណឹង អត់មានបញ្ហាសទេ ពីក្រោមចុះទៅលើ -- ពីក្រោមគេរាយការណ៍ទៅលើ ពីលើឲ្យឈ្មោះមកក្រោមវិញ។

**ស៖** នៅពេលដែលលោកនិយាយអំពីខេត្តហ្នឹង លោកសំដៅទៅលើតំបន់១៧មែនទេ? <ឬក៏ខ្ញុំយល់ថា ពេលលោកនិយាយអំពីខេត្ត គឺលោកសំដៅអំពីភូមិភាគនិរតីវិញ, អ៊ីចឹងមែនទេ?>

**ឆ៖** បាទ ពិតមែនហើយ។

**ស៖** បាទ សូមអរគុណ ខ្ញុំនឹងបន្តទៅមុខទៀត។ ពាក់ព័ន្ធទៅនឹងអ្នកជម្លៀសមកពីទីក្រុងភ្នំពេញ <និងមកពីកន្លែងផ្សេង> ដែលទៅដល់ស្រុកត្រាំកក់ តើជាទូទៅនៅតាមឃុំ លោកដឹងថាទេវិន័យហ្នឹងគឺថាមាន<ភាព>តឹងតែងមែនចំពោះអ្នកជម្លៀសហ្នឹង? ជាពិសេសគឺចំពោះអ្នកអតីតមន្ត្រីរដ្ឋការ ហើយនិងទាហាន លន់ នល់ ហ្នឹងគឺថាគេអនុវត្តវិន័យតឹងតែងចំពោះអ្នកទាំងអស់ហ្នឹង ជាងអ្នកមូលដ្ឋាន <មែនទេ>?

**ឆ៖** បាទ អត់ទេ។ គ្រាន់តែហៅថា អ្នកថ្មីក៏គេកាន់ជើងដែរ ហៅថាប្រជាជន១៧ក៏គេកាន់ជើងដែរ គេអត់ឲ្យថាថ្មី ថាចាស់ ថា១៧ទេ ប្រជាជនគឺមានសិទ្ធិស្មើគ្នា គេថាអ៊ីចឹង។ គោរពសិទ្ធិគ្នាទៅវិញទៅមក គេថាប៉ុណ្ណឹង។

[១៣:៥២:០៤]

**ស៖** ខ្ញុំមិនសូវយល់ចម្លើយរបស់លោកទេ លោកថាមានសិទ្ធិស្មើគ្នានោះ។ <តើសិទ្ធិអ្វីខ្លះដែលប្រជាជនមានប្រចាំថ្ងៃនៅក្នុងរបបខ្មែរក្រហមនោះ? ឧទាហរណ៍> តើអ្នកថ្មី និងអ្នកចាស់ហ្នឹងមានសិទ្ធិដើរហើរដោយសេរីដូចគ្នាទេ?

**ឆ៖** បាទ សូមជម្រាប អ្នកថ្មីក៏ដូចអ្នកចាស់ អ្នកចាស់ក៏អត់មានសិទ្ធិដើរហើរ ដឹងតែព្រលឹមឡើងរែកអម្រែកបង្គីទៅរែកដី។ អ្នកថ្មីក៏ទៅរែកដី អ្នកចាស់ក៏ទៅរែកដី រែកស្មើគ្នា ដល់ពេលដល់ម៉ោងមកហូបបាយដូចគ្នា ដល់ពេលចេញទៅរែកទៀតគឺទៅដំណាលគ្នាទៀត អត់មានមើលងាយមើលថោកគ្នាទេ។ តែអាគេអ្នកចម្រាញ់ គេមានផ្សេងទៀត គេចេះតែធ្វើការស៊ើបអង្កេត ប៉ុន្តែប្រជាជនស្រឡាញ់គ្នាគោរពស្រឡាញ់ជិតស្និទ្ធដូចគ្នា។

**ស៖** តាមពិតទៅ វាគឺថា ខ្ញុំគិតថាមិនមានកាតព្វកិច្ច និងមិនមានសិទ្ធិដូចគ្នាទេ។ អ៊ីចឹងមានន័យថាមិនមែនមានសិទ្ធិដូចគ្នា គឺមានកាតព្វកិច្ចដូចគ្នា។ អ៊ីចឹងទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៣:៥៤:៣៤]

**លោក គង់ សំអុន៖**

ខ្ញុំសូមជំទាស់ចំពោះការធ្វើសក្ខីកម្មរបស់សហព្រះរាជអាជ្ញារង ដែលការលើកឡើងនេះមិនត្រឹមត្រូវទេ ហើយដែលសហព្រះរាជអាជ្ញាមិនគួរធ្វើសេចក្តីសន្និដ្ឋានប្រឆាំងទៅនឹងសាក្សីដោយខ្លួនឯងដូច្នេះទេ។ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសួរសំណួរហ្នឹង គឺផ្អែកទៅលើសចម្លើយដែលខ្ញុំទទួលបានមុនហ្នឹង។ ខ្ញុំយល់ថា<វា>មិនមែនជាសិទ្ធិស្មើគ្នាទេ<ដែល>គេត្រូវរស់នៅ<ជាមួយគ្នា> ហើយមានគេតាមដានដូចគ្នា។ អ៊ីចឹងវាមានន័យថា យើងអាចយល់ហើយថា វាជាកាតព្វកិច្ចទេ មិនមែនជាសិទ្ធិទេ ត្រង់ចំណុចនេះនោះ។ អ៊ីចឹងលោកប្រធាន ខ្ញុំអាចសួរសំណួរនេះបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មានមូលដ្ឋានត្រឹមត្រូវ លោកសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិអំមិញទេ។ សហព្រះរាជអាជ្ញារងអាចកែប្រែសំណួររបស់លោក ឬក៏សួរសំណួរបន្តទៀត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើប្រជាជនធម្មតានៅក្នុងស្រុកត្រាំកក់ នៅក្នុងរបបខ្មែរក្រហម មានសិទ្ធិនិយាយស្ដីដោយសេរីទេ? ពួកគាត់មានសិទ្ធិរិះគន់របបខ្មែរក្រហម រិះគន់របបអាហារ ឬក៏មានសិទ្ធិប្រឆាំងទៅនឹងបញ្ជាដែលដាក់ចេញពីខាងឃុំទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ កន្លែងខ្ញុំគឺធ្វើគរ ធ្វើថ្នល់ ហូបបបរមានតែទឹក ក៏អត់ហ៊ានលាន់មាត់ថា បបរសុទ្ធតែទឹកដែរ។ សម្លមានតែទឹក ក៏អត់មានហ៊ានលាន់មាត់ថា សម្លមានតែទឹកទេ តែហ៊ានគេថាទំនាស់សហករណ៍។ តែទំនាស់សហករណ៍ គេយកទៅព្រៃទាំងថ្ងៃហ្នឹង អត់មានចាំយប់ទាន់ទេ។ អាហ្នឹងពាក្យហ្នឹងពាក្យទំនាស់សហករណ៍។

[១៣:៥៦:៤៩]

**ស៖** យាយហឿន បានឆ្លើយនៅក្នុងកំណត់ហេតុ<នៃការស្ដាប់ចម្លើយរបស់គាត់ គឺ> E319/12.3.2 នៅចម្លើយទី១២០ ខ្ញុំនឹងដកស្រង់ចម្លើយរបស់គាត់ជាភាសាអង់គ្លេស៖ “ខ្ញុំយល់ថា ប្រជាជនថ្មីមិនល្អ ជាខ្មាំង មិនសូវមានតម្លៃដូចប្រជាជនចាស់។ ដូច្នេះ គេពុំអនុញ្ញាតឲ្យរៀបការជាមួយប្រជាជនចាស់នោះទេ”។ សូមបញ្ចប់ការដកស្រង់។ តើ<លោកស្ដាប់ឮទេ> នៅក្នុងរយៈកាលក្រោយពីការជម្លៀសប្រជាជនចេញពីទីក្រុង និងរយៈកាលក្រោយៗមកទៀតនោះថា លោកធ្លាប់ឮទេថា បក្សមានការសង្ស័យចំពោះអ្នក១៧មេសា ហើយដោយគិតថា ពួកអ្នកទាំងអស់ហ្នឹងសុទ្ធតែជាខ្មាំង ដូចដែលយាយហឿន គាត់បានឆ្លើយអ៊ីចឹង?

**ឆ៖** បាទ ខ្ញុំឃើញនឹងភ្នែក ច្បាស់នឹងភ្នែកហ្នឹង គឺប្រជាជនដែលនៅដីរំដោះ ប្រជាជនមូលដ្ឋានហ្នឹងក៏គេតាមដានរកចាប់ចងដាក់ខ្នោះ មានយកទៅសម្លាប់ដែរ ហើយប្រជាជនថ្មីក៏គេតាមដានរកចាប់ចងដាក់គុក ដាក់ច្រវាក់អ៊ីចឹងដែរ។ មានសិទ្ធិ គេដើរពិនិត្យទាំងអស់ ទាំងថ្មី ទាំងចាស់ ប្រជាជនចាស់ហ្នឹងហើយស្លាប់ច្រើនជាងគេ។ ច្រើន ឃើញបងប្អូនចេញពីភ្នំពេញទៅ ទៅសំណេះសំណាល ទៅល្អកល្អិនជាមួយ អាហ្នឹងហើយគេថានិន្នការនយោបាយពាក់ព័ន្ធ គេយកទៅតែទាំងអស់ហ្នឹងទៀត។ គ្រាន់ថាអ្នកចាស់ ក៏ដូចអ្នកថ្មី គ្រប់ថ្នាក់ដូចគ្នា។

**ស៖** តើនៅក្នុងស្រុកត្រាំកក់ នៅពេលណាមួយនោះ គេមានធ្វើការបែងចែកប្រជាជនទៅតាមប្រភេទទេ គឺមានន័យថាគេរៀបចំជាប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម គឺមានអ្នកដែលជាប់ពាក់ព័ន្ធទៅនឹងអ្នកមូលដ្ឋាន ហើយនិងប្រជាជនបញ្ញើ ដែលមានន័យថាជាអ្នក១៧មេសា តើលោកធ្លាប់ឮអំពីការ

បែងចែកប្រជាជនជាប្រភេទៗអ៊ីចឹងទេ?

**ឆ៖** បាទ កាលនុ៎ង ខ្ញុំជម្រាបដែលគេថាខ្ញុំនិន្នាការនយោបាយហ្នឹង គេបែងចែកនៅឆ្នាំ៧៣ ខែ៣ គេបែងចែកវណ្ណៈមនុស្សហើយ មានបីប្រភេទ៖ វណ្ណៈកសិករ កសិករកណ្ដាល កសិករក្រោម ពលករ។ វណ្ណៈនេះគឺវណ្ណៈល្អ។ អាវណ្ណៈកសិករលើ អានាយទុន អនុធនហ្នឹង អត់ល្អទេ គឺត្រូវតែកង់ប្រវត្តិសាស្ត្រកិនហើយ គេនិយាយអ៊ីចឹង។ ហើយកង់ប្រវត្តិសាស្ត្រកិនហ្នឹង តាំងពីម៉ែពីឪខ្ញុំហ្នឹង ក៏ត្រូវកង់ប្រវត្តិសាស្ត្រកិនដែរ។ អត់ថាចាស់ អត់ថាថ្មីទេ ឲ្យតែបែងចែកទៅត្រូវកម្រិតវណ្ណភាពអ្នកមាន។ អ្នកមានគ្រាន់តែមានម៉ាស៊ីនស្រូវតូចមួយហ្នឹងក៏គេចាប់យកទៅសម្លាប់ដែរ គ្រាន់តែមាន ផ្ទះហ្នឹងមានដើមដូងស្លុយស្លុសច្រើនហ្នឹង ក៏គេចាប់យកទៅសម្លាប់ដែរ។ គ្រាន់តែមានស្រូវហូបសល់គ្រប់គ្រាន់ក៏គេយកទៅសម្លាប់ដែរ មិនចាប់តែអ្នកមានបណ្ដាស័ក្តិទេ។ ភូមិមួយៗស្ងាត់សូន្យ អត់មានមនុស្សទេ មានតែឆ្កែព្រុស។ សូមជម្រាបអ៊ីចឹង។

[១៤:០០:៤៩]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីពាក្យដែលលោកប្រើ ក៏ដូចជាខុម ដែលបានប្រើជាញឹកញាប់ដែលថាអ្នកដែលប្រឆាំងនឹងកង់ប្រវត្តិសាស្ត្រនឹងត្រូវកម្ទេចចោល។ ដូច្នេះខ្ញុំនឹងព្យាយាមកំណត់<ជាមួយលោក>ថាតើអ្នកណាខ្លះជាអ្នកប្រឆាំងនឹងរបបខ្មែរក្រហម ហើយតើពួកគាត់មានជោគវាសនាយ៉ាងណាខ្លះ។ អម្បាញ់មិញនេះ លោកនិយាយ<ហើយ>ថា ប្រជាជនមិនអាចរិះគន់របបអាហារទេ បើមិនអ៊ីចឹងទេគេចាត់ទុកថាប្រឆាំងសហករណ៍។ តើលោកអាចរៀបរាប់អំពីបទល្មើសផ្សេងៗដែលធ្វើឲ្យគេចោទម្នាក់ មនុស្សម្នាក់ហ្នឹង ឬក៏អ្នកណាហ្នឹង ថាជាប្រឆាំងនឹងសហករណ៍ឬក៏ប្រឆាំងនឹងរបបហ្នឹងទេ? លោកអាចរៀបរាប់ទេ ថាមានកំហុសអ្វីខ្លះដែលធ្វើឲ្យខ្មែរក្រហមគេគិតថាអ្នកហ្នឹងជាអ្នកប្រឆាំង<នឹងរបបគេ>បែបនេះ?

**ឆ៖** បាទ ខ្ញុំជម្រាបប្រសាសន៍ មានយាយមួយ ឆ្នាំ៧៣ ត្រូវជីដូនមួយជាមួយ តាម៉ុក។ ហើយតាម៉ុក គាត់នៅក្នុងព្រៃមន្ទីរ១៦០ ដល់ពេលនោះ យាយខុម ដឹងថាយាយសៀកហ្នឹងមនុស្សកំណាញ់មានរទេះសេះ យាយខុមទៅខ្ចីរទេះសេះ ហើយដល់ខ្ចីយាយសៀកបាន យាយសៀកថា កំណត់មួយខែយកឲ្យអញវិញ។ ដល់មួយខែ យាយខុម អត់យកមកឲ្យ យាយសៀក ទៅយកដល់ផ្ទះ យករទេះសេះគាត់មកវិញ។ ដល់យករទេះសេះមកវិញគាត់ឲ្យ អារស់ ដែលប្រជាជនកាប់ចោលឆ្នាំ៧៩ហ្នឹង មកយកចង យាយសៀក យកទៅសម្លាប់ ដល់ចងទៅបណ្ដើរទៅតាមផ្លូវឡាន តាម៉ុក ចេញពី១៦០ ហ្នឹង។ ចង

មុខហើយៗ ដល់តាម៉ុក ចេញពីព្រៃមក [សួរថា៖ “យី! អ្នែងចងមុខអាណា?” “អាខ្មាំង!” “ចុះអ្នែងទៅចាប់ខ្មាំងម៉េចបានបើអ្នែងដើរទទេ” “ខ្មាំងជំនាន់សហករណ៍” វាថាអ៊ីចឹង។ ថា៖ “ខ្មាំងជំនាន់សហករណ៍! មើល៍ អ្នែងស្រាយមុខមើលអាណា?” ដល់ស្រាយមុខមកជីដូនមួយ តាម៉ុក។ “យី! ចុះអ្នែងទៅចាប់មីសៀកមកធ្វើអី? អ្នែងដឹងថាមនុស្សហ្នឹងកំណាញ់ទេ អ្នែងទៅធ្វើអ្វីវា?” ថាអ៊ីចឹង។ “អ៊ីចឹង មីសៀកឡើងឡានមកជាមួយអញ។ អាណាហ៊ានមកចាប់ មីសៀក ទៀតប្រាប់អញ។ មីសៀក ជាមនុស្សកំណាញ់ ហើយចាប់វាចងមុខយកទៅសម្លាប់ហ្នឹងមកជួបអញ បើអត់ជួប អ្នែងយកគេសម្លាប់បាត់ហើយ”។] ហ្នឹងរឿងហ្នឹងប៉ុណ្ណឹងទេ អាហ្នឹងរឿងខ្ចីរទេះសេះ ហើយគាត់ទៅយកមកវិញ ថាគាត់ទំនាស់សហករណ៍មួយ។ អាហ្នឹងរឿងទំនាស់សហករណ៍រហូតដល់គេយកទៅសម្លាប់។

[១៤:០៣:៣៣]

**ស៖** សូមអរគុណលោក។ ខ្ញុំនឹងនិយាយអំពីពេលវេលាដែលពាក់ព័ន្ធ<ខ្លាំងក្នុងអង្គសវនាការនេះគឺនៅ>ចន្លោះឆ្នាំ៧៥ ដល់ ៧៩ ព្រោះឧទាហរណ៍ដែលលោកផ្តល់ឲ្យវាហាក់ដូចជាឧទាហរណ៍ពិសេសមួយអំពីបងប្អូនជីដូនមួយ<របស់តាម៉ុក>។ ដូច្នេះ ខ្ញុំចង់និយាយពីមនុស្សទូទៅវិញ។ ប្រហែលជាអ្វីដែល យាយបឿន និយាយនៅក្នុងកិច្ចសម្ភាសន៍ គឺ E319/12.3.2។ គាត់បាននិយាយដូចតទៅនេះនូវសំណួរចម្លើយ៩១ និង <១៤៧>។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស សំណួរ-ចម្លើយ<៩១>៖ “ថ្នាក់<បានណែនាំថា អ្នកណាខ្លះ>ជាខ្មាំង<>ហើយ<ខ្ញុំយកការណែនាំទាំងនោះទៅប្រាប់ភូមិ>វិញ។ <គេនិយាយថា ឲ្យ>យើងស្វែងរក<>អ្នកណា<ខ្លះ>ជាខ្មាំង។” ចម្លើយទី<១៤៧>៖ “អ្នកដែលបំផ្លាញសម្ភារៈ<ផ្សេងៗ ឬក៏ដើរបំផុសបំផុលដោយនិយាយ>ប៉ះពាល់ដល់អង្គការ<> ឬក៏ប្រឆាំងជាមួយអង្គការ ឬក៏ប្រើប្រាស់ល្បិច<អីផ្សេងៗ> ត្រូវចាត់ទុកថាជាបទល្មើសធ្ងន់។” សូមបញ្ចប់ការដកស្រង់។ តើចម្លើយរបស់ យាយបឿន ឆ្លើយតបទៅនឹងអ្វីដែលលោកបានសង្កេតឃើញពាក់ព័ន្ធទៅនឹងនិយមន័យនៃការប្រឆាំងរបបចន្លោះពីឆ្នាំ៧៥ ដល់ ៧៩ ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទមិនជាជំទាស់ខ្លាំងទេ ប៉ុន្តែយល់ឃើញថា យាយបឿន

គាត់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះហើយ ហើយសក្ខីកម្មរបស់គាត់នៅចំពោះអង្គជំនុំជម្រះនេះ វាមានលក្ខណៈល្អប្រសើរ ហើយមានការពន្យល់ច្បាស់លាស់ជាង។ ដូច្នេះ ខ្ញុំបាទយល់ឃើញថា តំណាងសហព្រះរាជអាជ្ញាគួរលើកសក្ខីកម្មដែល យាយហឿន បានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះមកប្រើប្រាស់ ជាជាងការដកស្រង់នូវសំណេរ កំណត់ហេតុស្តាប់ចម្លើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងរយៈពេលមុននោះ ដែលពុំមានការផ្ទៀងផ្ទាត់នៅក្នុងអង្គជំនុំជម្រះនេះ។ បាទ សូមអរគុណ។

[១៤:០៦:២៥]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី អ៊ីចឹងខ្ញុំនឹងលើកឧទាហរណ៍មួយដើម្បីឱ្យមានភាពច្បាស់លាស់ចំពោះលោក គឺថា<យាយហឿន>បាននិយាយនៅក្នុងសវនាការថា "ការលួចចានឆ្នាំង<>របស់សហករណ៍ គឺជាបទ<ល្មើសធ្ងន់។>" គាត់ក៏បាននិយាយ នៅថ្ងៃចន្ទមុន> គឺប្រហែលជាម៉ោង ០៣:៣០ នៅពេលរសៀល ហើយក៏បាននិយាយផងដែរថា "អ្នកដែលបំផ្លាញ ឬក៏ធ្វើឱ្យខូចខាតដល់ឧបករណ៍ ឬក៏អ្នកដែលជំរុញឱ្យអ្នកដទៃទៀតប្រឆាំង ឬក៏ប្រើល្បិច ចាត់ទុកថាជាបទល្មើស គឺជាបទល្មើលធ្ងន់"។ តើលោកយល់ស្របជាមួយនឹងចម្លើយដែលយាយហឿន ផ្តល់នេះដែរឬទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ ការពិតណាស់ រឿងហ្នឹងវាជាក់ស្តែងអ៊ីចឹងមែន។ អាហ្នឹងក៏ធ្វើទំនាស់ឱ្យសហករណ៍ដែរ។

**ស៖** ខ្ញុំនឹងលើកឡើងនូវភាពខុសគ្នារវាងបទល្មើសស្រាល និងបទល្មើសធ្ងន់នៅពេលបន្តិចទៀតនេះ ប៉ុន្តែខ្ញុំបានសួរខ្លួនខ្ញុំ ហើយយើងតែងតែឮមនុស្សជាច្រើននិយាយអំពីឃុំនាំយកប្រជាជនដែលត្រូវបានចាប់នៅថ្នាក់ស្រុក។ ដូច្នេះ <តើ>ឃុំគឺមាន<កន្លែង>ឃុំខ្លួនប្រជាជនជាបណ្តោះអាសន្ន មុនពេលដែលបញ្ជូនទៅថ្នាក់ស្រុក។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ឃុំអត់មានទាទីចាប់គេដាក់ឃុំឃាំងក្នុងមន្ទីរឃុំ ក្នុងឃុំទេ។ គេមានបញ្ហាអ្វីចោទឡើង គេរាយការណ៍មកស្រុក ស្រុកគេឱ្យកងស្រុកគេទៅចាប់យកមកប្រគល់ដាក់ ដូចថានៅមានទោសកម្រិតស្រាល គេយកមកដាក់សាលាកែប្រែហ្នឹង បើទោសកម្រិតធ្ងន់ ស្រុកយកទៅប្រគល់ឱ្យអង្គការឃុំហ្នឹង។ ហ្នឹងមានពីរផ្លូវហ្នឹងទេ កម្រិតធ្ងន់ ហើយនិងកម្រិតស្រាល។

[១៤:០៨:៥៤]

**ស៖** បាទ អ៊ីចឹងតើមានពេលខ្លះខាងស្រុកស្នើសុំដោយល្អបឃុំ ឲ្យចាប់ប្រជាជនដោយខ្លួនឯង ហើយបន្ទាប់មក នាំយក<មនុស្ស>ដែលចាប់ខ្លួននេះយកដល់ថ្នាក់ស្រុកដែរឬទេ? ការពិតទទួលស្គាល់ថា វាជាសេចក្ដីសម្រេចរបស់ថ្នាក់ស្រុក ប៉ុន្តែថ្នាក់ឃុំ គឺជាអ្នកអនុវត្ត។ តើមានករណីនេះដែរឬទេ?

**ឆ៖** បាទ កាលនោះពិតមែនអ៊ីចឹងហើយ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងប្រើប្រាស់ឯកសារ ហើយខ្ញុំគិតថា ប្រហែលជាលោកមានឯកសារមួយចំនួននៅក្បែរលោកហើយ ហើយប្រហែលជាមានអ្នកអាចជួយលោកដើម្បីពិនិត្យមើលទៅលើឯកសារ។ ដូច្នេះ ខ្ញុំចង់ឲ្យលោកមើលឯកសារ គឺE3/4120។ តើមានអ្នកណានៅក្បែរលោកដែលអាចជួយលោករកឯកសារហ្នឹងបានទេ លោកសាក្សី?

**លោក ឯក ហឿន៖**

មាន។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកនៃអង្គការគាំពារសាក្សីនិងអ្នកជំនាញ អង្គភាពសាក្សីនិងអ្នកជំនាញជួយសម្របសម្រួលស្វែងរកឯកសារតាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញាជូនសាក្សី។

**លោក ម៉ម រិទ្ធា៖**

បាទ លោកប្រធាន ឃើញនៅក្នុង *ខនថេន* វាហើយ ឥឡូវកំពុងតែដកយកមក។

**លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

ទំព័រដែលលោកត្រូវបង្ហាញគឺ 00270983 គឺនៅទំព័រខាងឆ្វេង ព្រោះថាវាមានពីរទំព័រ គឺ 00270983, បារាំង <00623344>, និងភាសាអង់គ្លេសគឺ 00322175។ តើវាអាចដែរឬទេដែលថា យើង-- ដូច្នេះ លោកប្រធាន ខ្ញុំសុំអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់។ សុំលោកប្រធានអនុញ្ញាត។ <នេះជាឯកសារមានសំណៅជាភាសាខ្មែរ។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១៤:១១:៥៤]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** ឥឡូវនេះ ខ្ញុំនឹងសង្ខេបទៅលើឯកសារនេះ <ហើយខ្ញុំនឹងអានកថាខណ្ឌមួយ>។ ដូច្នេះ របាយការណ៍នេះគឺផ្ញើជូនដោយ ឃុន មកពីឃុំស្រែនោង ហើយឯកសារនេះបានរៀបរាប់ពីការចាប់ខ្លួន ហើយបញ្ជូន<>ប៉ូលិស<ទៅសួរចម្លើយ>ប្រជាជនថ្មី <ដោយ>ប្រជាជនថ្មីនេះបានដេញទាចូលវាលស្រែជាបន្តបន្ទាប់<បីដងមកហើយ។> ខ្ញុំសូមដកស្រង់នូវកថាខណ្ឌដែលបញ្ជាក់ដូចតទៅនេះ៖ "សូមបញ្ជាក់មកបក្ស នៅថ្ងៃទី០៤ ខែមករា ៧៧ គឺមានប្រជាជនថ្មី<មួយចំនួន>ដែលប្រឆាំងនឹងអង្គការ ប្រឆាំងនឹងបក្ស។ ហេតុនេះ ខ្ញុំនឹងចាប់បញ្ជូនជាបន្តបន្ទាប់<ទៅកាន់បក្ស>"។ សុំបញ្ចប់ការដកស្រង់។ នៅក្នុងឯកសារនេះ គឺថា គេប្រើពាក្យ "ចាប់បញ្ជូនទៅនគរបាលជាបន្តបន្ទាប់ដើម្បីស៊ើបសួរ។" ដូច្នេះ តើគេបញ្ជូនទៅណាឲ្យច្បាស់លាស់? ថាតើបញ្ជូនទៅប៉ូលិសស្រុក ឬក៏ប៉ូលិសមួយណាដែរ? <អគារនៅត្រង់ណា?>ខ្ញុំចង់ដឹងថា តើគេបញ្ជូនមនុស្សទាំងអស់នេះទៅទីណា<ឲ្យពិតប្រាកដ>ដើម្បីសាកសួរ?

តើលោកឮសួរសំណួរដែរឬទេ? តើលោកត្រូវការពេលវេលាបន្ថែមទៀតទេ?

**លោក ម៉ម រិទ្ធា៖**

ពូមានស្តាប់បានសំណួរលោកព្រះរាជអាជ្ញាសួរទេពូ?

**លោក ឯក ហឿន៖**

អត់។

**លោក ម៉ម រិទ្ធា៖**

អ៊ីចឹងឲ្យគាត់សួរម្តងទៀត។

**លោក ឯក ហឿន៖**

បាទ សុំមានប្រសាសន៍ម្តងទៀត អត់ច្បាស់។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកសាក្សីនៅក្នុងឯកសារនេះ គឺ ឃុន បាននិយាយថា៖ "យើងចាប់បញ្ជូនប្រជាជនថ្មីទៅនគរបាលដើម្បីពិនិត្យសួរចម្លើយ"។ ដូច្នេះ លោកអាចពន្យល់បានដែរឬទេថាតើនគរបាលហ្នឹង ក្នុងករណីហ្នឹងគឺជាមន្ទីរសន្តិសុខនៅកម្រិតស្រុក ឬមួយក៏យ៉ាងណា? តើគាត់មានន័យយ៉ាងម៉េច នៅពេលដែលគាត់និយាយថា "ចាប់បញ្ជូនទៅ<>នគរបាល"<>នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

[១៤:១៥:១០]

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទសូមជំទាស់ហ្នឹងការសួរនេះ ដោយសារក្នុងឯកសារពុំមានពាក្យនគរបាលទេ គឺមានពាក្យបន្តបន្ទាប់។ អ៊ីចឹងការលើកដកស្រង់ពីឯកសារនេះ គឺពុំត្រឹមត្រូវទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

មិនអីទេ ប្រហែលជាដោយសារបញ្ហាបកប្រែ ព្រោះថាភាសាបារាំង និងភាសាអង់គ្លេសគឺមានពាក្យថា “ចាប់បញ្ជូនទៅដាក់នរគបាលដើម្បី<សាកសួរ>”។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរសំណួរឡើងវិញ។ នៅពេលដែលឃុំចាប់ប្រជាជនណាម្នាក់ ដូច្នេះចង់ដឹងថាតើអ្នកដែលគេចាប់ខ្លួនបានហ្នឹងត្រូវបានបញ្ជូនទៅអ្នកណា? ថាតើគេបញ្ជូនទៅឈ្លបស្រុក ឬក៏បញ្ជូនទៅមន្ទីរពិសេសណាមួយ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ រឿងហ្នឹងវាមិន -- រឿងហ្នឹងវាជាការពិតណាស់ គឺចាប់ហើយ គេអត់មានបញ្ជូនមកឱ្យអង្គការស្រុកជំនុំជម្រះរកខុសត្រូវទេ តែគេចាប់ហើយគេបញ្ជូនទៅរណ្ដៅព្រៃហើយ អត់មានជំនុំជម្រះរកខុសរកត្រូវទេ គេសម្រេចថាចាប់ទៅហើយនោះ អត់ដែលឃើញត្រឡប់មកវិញទេ។

**ស៖** ខ្ញុំមានសំណួរមួយទៀតពាក់ព័ន្ធទៅនឹងឯកសារនេះផងដែរ។ លោកចាំដែរឬទេ<>ឃុនមកពីឃុំស្រែរនោងនេះ តើគាត់មានតួនាទីអ្វីដែរ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ តាឃុន នៅឃុំស្រែរនោងគឺគាត់ប្រធានឃុំៗស្រែរនោងហ្នឹង។

[១៤:១៧:២២]

**ស៖** តើលោកដឹងដែរឬទេថាមាន<ពេលណាមួយ>គាត់ត្រូវបានគេបោសសម្អាតដែរឬទេ?

**ឆ៖** ហ្នឹងនៅឃុំឆ្ងាយពីមន្ទីរស្រុក អត់បានដឹងទេ ស្គាល់តែតាឃុន ចំណាំឃើញមកប្រជុំនៅមន្ទីរស្រុកហ្នឹង ដឹងស្គាល់តែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំនឹងពិភាក្សាអំពីចម្លើយដែលលោកផ្ដល់ឱ្យសហចៅក្រមស៊ើបអង្កេត <E319.1.32> សំណួរ-ចម្លើយ១៧, ១៨, ១៩ ហើយខ្ញុំនឹងអានទៅលើអ្វីដែលគេបានសួរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោក គឺសំណួរទី១៧៖ “តើមេឃុំមានសិទ្ធិអំណាចក្នុងការសម្រិតសម្រាំង និងចាប់ខ្លួនប្រជាជនដែរឬទេ?” ហើយលោកឆ្លើយថា “មេឃុំមិនមានសិទ្ធិដើរចាប់មនុស្សទេ គឺមានតែកងស្រុកប៉ុណ្ណោះទើបគេចាប់មនុស្សទាំងយប់ទាំងថ្ងៃ”។ ហើយសំណួរបន្ទាប់ គឺសំណួរ១៨៖ “តើថ្នាក់ឃុំមានតួនាទីក្នុងការផ្ដល់ព័ត៌មានផ្សេងៗទៅដល់ថ្នាក់ស្រុកដែរឬទេ? ឆ្លើយ៖ បាទ គេផ្ដល់ព័ត៌មានទៅដល់ថ្នាក់ស្រុក ដូចជាអ្នកណាប្រព្រឹត្តខុសសីលធម៌ជាដើម ប៉ុន្តែពុំមានសិទ្ធិចាប់ខ្លួនមនុស្សនោះទេ។ សំណួរទី១៩៖ តើថ្នាក់ឃុំ និងថ្នាក់ស្រុកមានទំនាក់ទំនងគ្នាដូចម្ដេច? ឆ្លើយ៖ គេរាយការណ៍ដោយមានបញ្ជីឈ្មោះរបស់មនុស្ស។ បើឈ្មោះណាមានគូសរង្វង់ប៊ិកពណ៌ក្រហម ឈ្មោះនោះនឹងត្រូវថ្នាក់ស្រុកទៅយកមកដោយខ្លួនឯង។ បើឈ្មោះណាគូសរង្វង់ដោយប៊ិកពណ៌ខៀវ នោះថ្នាក់ឃុំជាអ្នកយកមនុស្សទៅឲ្យថ្នាក់ស្រុក”។ សូមបញ្ចប់ការដកស្រង់។

[១៤:១៩:៣៥]

ដូច្នេះពាក់ព័ន្ធទៅនឹងអ្វីដែលលោកទើបតែបានឆ្លើយ ដែលថាប្រជាជនត្រូវបានចាប់ដោយថ្នាក់ឃុំ គឺត្រូវបានគេបញ្ជូនទៅព្រៃ។ ប៉ុន្តែនៅត្រង់ចំណុចនេះ លោកនិយាយថា អ្នកដែលគូសដោយប៊ិកពណ៌ខៀវត្រូវថ្នាក់ឃុំជាអ្នកចាប់<> ហើយ<បញ្ជូន>ទៅឲ្យថ្នាក់ស្រុក។ តើលោកអាចបញ្ជាក់បានទេ ថាតើប្រជាជនដែលត្រូវបានគូសរង្វង់ដោយប៊ិកពណ៌ខៀវហ្នឹងត្រូវបានគេបញ្ជូនទៅស្រុកដោយថ្នាក់ឃុំដែរឬទេ?

**ឆ៖** បាទ ការពិតណាស់ រង្វង់ទឹកប៊ិកក្រចកពណ៌ខៀវ គឺឃុំបញ្ជូនមកឲ្យអង្គការស្រុក។ អង្គការស្រុកឲ្យកម្លាំងកងទ័ពស្រុកនាំទៅឲ្យផ្ទះ មិត្តម៉េង ដែលលោក ម៉េង ដែលកាន់កាប់សាលាកែប្រែហ្នឹងយកទៅទុកដាក់នៅហ្នឹង ជាកន្លែងគេអប់រំនៅហ្នឹង។ កន្លែងហ្នឹងអត់មានធ្វើបាបមនុស្ស អត់មានវាយសួរចម្លើយសួរអីទេ វាទោសកំហុសគ្រាន់តែទំនាស់អារឿងប្រពន្ធកូនក្រមុំគេហ្នឹងប៉ុណ្ណឹងឯង គេអត់មានយកទោសពៃរ៍អីធ្ងន់ទេ។

**ស៖** ដូច្នេះ អ្វីដែលខ្ញុំចង់បន្តពិភាក្សាទៀត គឺនៅពេលដែលប្រជាជន មាន គឺថាអ្នកដែលមានឈ្មោះគូសដោយរង្វង់ពណ៌ខៀវ និងអ្នកដែលមានឈ្មោះរង្វង់គូសដោយប៊ិកក្រហម តើអ្នកណាជាអ្នកធ្វើ? ថាតើថ្នាក់ឃុំជាអ្នកគូស ឬក៏ថ្នាក់ស្រុក <ឬក៏ថ្នាក់តំបន់>ជាអ្នកគូសទៅលើឈ្មោះនោះ?

**ឆ៖** បាទ អាហ្នឹង ឃុំស៊ើបអង្កេតទៅឃើញថា ឈ្មោះ “ក” ហ្នឹងវាជានិន្នាការនយោបាយដូចថា សេ.អ៊ី.អា យួន-សូវៀត -- អ៎! កា.ហ្សេ.បេ យួន-សូវៀត, សេ.អ៊ី.អា គិញអាមេរិក។ អាហ្នឹងឃុំគេ

រាយការណ៍មកឲ្យស្រុកហើយ។ គេរាយការណ៍មកហ្នឹង គេរង្វង់ក្រចកទឹកប៊ិកក្រហមហើយ។ ហើយដល់ស្រុកឃើញរង្វង់ទឹកប៊ិកក្រហម គឺបញ្ជូនអាទឹកប៊ិកក្រហមហ្នឹងទៅឲ្យឃុំ ទៅឲ្យឃុំដឹងថា ថ្ងៃល្ងាចគេឲ្យកងទ័ពស្រុកទៅយកមិត្ត “ក” ដែលរង្វង់ទឹកប៊ិកក្រហមហ្នឹងហើយ។ អាហ្នឹងកងទ័ពស្រុកជាអ្នកដើរយកទេ ប៉ុន្តែឃុំរាយការណ៍មកឲ្យស្រុក ស្រុកឲ្យកងទ័ពស្រុកទៅដើរចាប់។ ចាប់ទៅអត់មានបញ្ជូនទៅណាទៀតទេ រណ្ដៅព្រៃហើយ។ តែប៉ុណ្ណឹង រឿងអត់មានរកខុស រកត្រូវ រកយុត្តិធម៌ទេ។

[១៤:២២:៣៧]

**ស៖** សូមអរគុណលោក អ៊ីចឹងមានការផ្ទុយគ្នាបន្តិចដែលខ្ញុំចង់ពិភាក្សាជាមួយលោក។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ<ចុងក្រោយរបស់លោក គឺឯកសារ>E319/8.2.4 នៅសំណួរ-ចម្លើយ២៣ និង២៤ ដែលខ្ញុំនឹងអាន<ជូនលោក> គឺលោកនិយាយដូចតទៅនេះភាសាអង់គ្លេស។ ការពិតលោកនិយាយជាភាសាខ្មែរ ប៉ុន្តែគេបកប្រែជាភាសាអង់គ្លេស។ “ថ្នាក់ខេត្ត ថ្នាក់តំបន់ ដាក់ផែនការទៅឲ្យស្រុក ហើយស្រុកដាក់បន្តទៅឲ្យឃុំ។ សំណួរ២៤៖ តើលោកអាចពន្យល់ប្រាប់បានទេ តើបទបញ្ជាណាមួយដែលទាក់ទងទៅនឹងការចាប់ខ្លួន ឬក៏សម្រេច ឲ្យ<សម្លាប់>នរណាម្នាក់គឺត្រូវចេញបញ្ជាពីថ្នាក់ខេត្ត ឬតំបន់ដែរឬទេ?” ហើយលោកឆ្លើយទៅនឹងសំណួរ<២៤នោះ>ថា “បាទ ត្រឹមត្រូវហើយ”។ ឧទាហរណ៍ ខេត្តបញ្ជូនរបាយការណ៍ដែលមានចំណារទឹកប៊ិកក្រហមឲ្យចាប់អ្នកណាម្នាក់ទៅស្រុក។ នោះស្រុក នឹងត្រូវបញ្ជូនរបាយការណ៍នោះបន្តទៅឃុំទៀត។ បន្ទាប់មកឃុំ បានចាប់ខ្លួនមនុស្សទាំងនោះទៅតាមចំណារទឹកប៊ិកក្រហម។ ហើយចុងក្រោយ មនុស្សដែលត្រូវបានចាប់ខ្លួននោះនឹងត្រូវបញ្ជូនទៅឲ្យ យាយខុម”។ សូមបញ្ចប់ការដកស្រង់។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីរបស់លោក លោកបានបន្ថែមកម្រិតបន្តិចទៀត ដែលលោកនិយាយថា តាមពិតទៅគឺ តំបន់ជាអ្នកសម្រេច។ ដូច្នេះ តើអ្នកណាជាអ្នកសម្រេច<ចុងក្រោយគេ> តើថ្នាក់តំបន់ ឬក៏ថ្នាក់ស្រុក? ហើយអ្នកណា គឺជាអ្នកគូសចំណារប៊ិកពណ៌ក្រហមនោះ?

**ឆ៖** បាទ ទី១គឺឃុំគេតាមដាន ដូចថាមនុស្សហ្នឹងចូល កា.ហ្សេ.បេ ឬចូល សេ.អ៊ី.អា ឃុំតាមដានឃើញហើយ គេដាក់ឈ្មោះ “ក” ហ្នឹង រង្វង់ក្រចកទឹកប៊ិកមកឲ្យស្រុកហើយ។ ដល់ស្រុកទទួលរង្វង់ទឹកប៊ិកក្រហមហ្នឹងហើយ ស្រុកផ្ញើឡើងទៅឲ្យខេត្តហើយ។ ដល់ផ្ញើទៅឲ្យខេត្តមិនយូរ ប៉ុន្មានគេផ្ញើអាឈ្មោះ “ក” ហ្នឹងរង្វង់ទឹកប៊ិកក្រហមមកឲ្យស្រុកវិញហើយ។ ដល់មកឲ្យស្រុក ស្រុកមានវិធានការឲ្យកងទ័ពស្រុកគេទៅចាប់ហើយ។ ចាប់ហើយអត់មានជំនុំជម្រះទេ ស្រុកគេយកទៅបាត់ហើយ អត់

ត្រឡប់ក្រោយវិញទេ។ អាហ្នឹងរឿងហ្នឹងវាតែប៉ុណ្ណឹងវាចប់ហើយ។

[១៤:២៥:២៩]

**ស៖** បាទ សូមអរគុណ។ តើគេសម្លាប់ប្រជាជននៅព្រៃណា? តើវាមាន<ព្រៃពិសេសណាមួយដើម្បីសម្លាប់មនុស្សដែរ ឬទេ>?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ កន្លែងដែលគេបញ្ជូនទៅផ្ទះអង្គការ ខុម ហ្នឹង គឺនៅចម្ងាយ ២០០ម៉ែត្រពីជង្រុកក្បាលខ្មោចក្រាំងតាចាន់ គេហៅថា "ព្រៃខ្មោចកូនក្មេង"។ ព្រៃខ្មោចកូនក្មេងនេះនៅខាងចិញ្ចើមផ្លូវខាងលិច ផ្លូវថ្នល់នៃព្រៃ ហើយចិញ្ចើមផ្លូវខាងកើតគឺជង្រុកក្រាំងតាចាន់ ហើយសុទ្ធតែភូមិករផ្ទះសម្បែងស្រែចម្ការប្រជាជន ខាងណោះគឺព្រៃឡង់។ ព្រៃឡង់ហ្នឹងមុនដំបូងគេយកកូនក្មេងដែលអុច កញ្ច្រើលយកទៅកប់ទៅព្រៃខ្មោចហ្នឹង ដល់ហើយគេឲ្យឈ្មោះ "ព្រៃខ្មោចកូនក្មេង"។ ដល់ឈ្មោះព្រៃខ្មោចកូនក្មេងអ៊ីចឹង គេចាប់ពួកនិន្នាការនយោបាយខ្មែរក្រហមហ្នឹង យកទៅសម្លាប់ព្រៃខ្មោចកូនក្មេងហ្នឹង សម្លាប់ប៉ុន្មានទិសក៏យកទៅព្រៃខ្មោចកូនក្មេងហ្នឹងដែរ សម្លាប់ពេញព្រៃខ្មោចកូនក្មេងហ្នឹង។ ដល់តែក្រោយឆ្នាំ២០០០ បានគេធ្វើជង្រុកដាក់នៅក្រាំងតាចាន់ហ្នឹង គេប្រមូលខ្មោច – ក្បាលខ្មោចចេញពីព្រៃយកទៅដាក់ជង្រុកនៅក្រាំងតាចាន់ហ្នឹង។

**ស៖** <>លោកអាចប្រាប់ខ្ញុំបានទេ ថាតើ<លោកដឹងថា មនុស្សដែលគេសន្មតថាជា>អ្នកប្រឆាំង<ផ្នែកនយោបាយហ្នឹង> ត្រូវបានគេសួរចម្លើយដែរឬទេ មុនពេលសម្លាប់?

**ឆ៖** បាទ កន្លែងហ្នឹងអត់មានកន្លែងសួរចម្លើយទេ។ បើបានលូកដៃចាប់ហើយ គឺទៅបាត់ហើយ អត់មានយកមកដាក់តុលាការរកខុសរកត្រូវទេ តែចាប់ហើយៗទៅហើយ។ អាចាស់ដូចថ្មី ថ្មីដូចចាស់ ដូចគ្នាទាំងអស់។

[១៤:២៧:៤៨]

**ស៖** នៅចំពោះមុខអង្គ -- សហចៅក្រមស៊ើបអង្កេត លោកនិយាយថា បញ្ជីដែលឈ្មោះគេចារចំណារក្រហមនិងចំណារខៀវ ដែលគេបញ្ជូនមកលោក។ គឺសំណួរចម្លើយទី២៦ នៅក្នុង <កំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោក> E319/8.2.4 លោកបាននិយាយថា លោកបានឃើញ ឬក៏លោកបានដឹងអំពីរបាយការណ៍គឺធ្វើឡើងដោយថ្នាក់<តំបន់> ហើយលោកដាក់របាយការណ៍ហ្នឹងចោលទៅក្នុងកន្ត្រក<នៅមន្ទីរពាណិជ្ជកម្មស្រុកត្រាំកក់>។ ដូច្នេះ តើលោកអាច<>រៀបរាប់បានទេថា លោកឃើញរបាយការណ៍ដែលមានឈ្មោះមនុស្សចារប៊ិកខៀវ ប៊ិកក្រហមហ្នឹង តើលោកឃើញដោយរបៀប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណា?

**ឆ៖** បាទ គឺរបាយការណ៍ពីឃុំពីស្រុកពីអីផ្សេងៗមកពីអង្គភាព មន្ទីរផ្សេងៗក្នុងការគ្រប់គ្រងរបស់ស្រុកហ្នឹង គេតែគេមើលហើយគេដាក់ក្នុងធុងសំរាមហើយ។ ហើយអ្នកដក់គេតែងតែទៅយកក្រដាសក្នុងធុងសំរាមមកដក់ហើយ។ ហើយដក់ហើយ គេចេះតែលួចលាមើលហើយ លាមើលចេះតែឃើញហើយ។ អាហ្នឹងជាការពិតណាស់ ពីឃុំវាយមកឲ្យស្រុកហ្នឹង ហើយស្រុកត្រូវវាយការណ៍ឡើងទៅលើទៀត។ អាហ្នឹងការពិតអ៊ីចឹង។ រឿងចាប់ចងវាសម្រេចពីខេត្ត ខេត្តសម្រេចឲ្យស្រុក កងទ័ពស្រុកសម្រេចឲ្យកងទ័ពស្រុកដើរយកមនុស្ស។

[១៤:២៩:៣០]

**ស៖** <នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោក> លោកបាននិយាយអំពីប្រធានស្រុក១០៥ គឺមាន ខុម, តាជឹម, <តាគិត>, តាចាយ ហើយចុងក្រោយលោកនិយាយអំពី តាសានហើយលោកនិយាយអំពីលោកគ្រូ អ៊្វិច។ តើនៅពេលដែលអ្នកដែលបន្តតំណែងស្រុក១០៥ហ្នឹងថា ថាតើមេឃុំមានសិទ្ធិមិនស្តាប់ ឬក៏មិនគោរពទៅបង្គាប់របស់ថ្នាក់ស្រុកដែរឬទេ?

**ឆ៖** អត់ទេ អត់ហ៊ានទំនាស់គេ។ ផែនការអីទទួលយកទាំងអស់។ តាអ៊្វិច ហ្នឹងចូលឆ្នាំ៧៧ ខែ៣ទៅហើយ ចូលកាន់ការស្រុក។ តាចាយ, តាជឹម, តាសោម ដល់គេចេញអស់ហើយ បានគ្រូអ៊្វិច ហ្នឹងឡើងមកធ្វើមន្ទីរស្រុក ប្រធានស្រុកជាមួយ យាយហឿន ហ្នឹង។ តាអ៊្វិច គាត់ប្រធាន។

**ស៖** តើវាជាការត្រឹមត្រូវដែរឬទេដែលថ្នាក់តំបន់ និងថ្នាក់ស្រុក ថ្នាក់ស្រុកត្រូវតែគោរពបង្គាប់បញ្ហាទាក់ទងទៅនឹងគោលនយោបាយដែលដាក់ចេញពីតំបន់១៣ ដែរឬទេ?

**ឆ៖** បាទ គេធ្វើតែអ៊ីចឹង ឃើញតែអ៊ីចឹងៗបើគេត្រឹមត្រូវរបស់គេ បានគេធ្វើ។ ខ្ញុំនៅខាងក្រោមគឺជាគ្រាន់តែឮតែគេថា អត់បានធ្វើអីដូចបានឃើញ។ ឃើញតែគេផែនការ តែតំបន់ឲ្យសំបុត្រទៅហ្នឹងស្រុកមើលហើយក៏ចាត់ចែងភ្លាមៗអត់ឲ្យនៅទំនេរទេ។

**ស៖** តើលោកធ្លាប់មានឱកាសចូលរួម<ប្រជុំ>នៅក្នុងកម្រិតស្រុកនិងកម្រិតតំបន់ដែរឬទេ? ឬក៏តើលោកធ្លាប់ចូលរួមនៅក្នុងមហាសន្និបាតដែរឬទេ? ថាតើលោកធ្លាប់បានចូលរួមទេ?

**ឆ៖** បាទ សុំជម្រាប អត់ដែលបានចូលរួមទេ ជាប្រជាជន គេប្រជុំតែអ្នកមន្ត្រី អ្នករាជការគេអ្នកមានបណ្តាស័ក្តិទេ ពីព្រោះប្រជាជន បើគេប្រជុំរួមក្នុងមន្ទីរគឺយើងទៅប្រជុំគ្នាទាំងអស់គ្នា គេនិយាយចំហ អត់មាននិយាយអីទេ និយាយតែពីរឿងការងារចំពោះមុខហ្នឹង។ សូមជម្រាបប៉ុណ្ណឹង។

[១៤:៣២:៣៧]

**ស៖** ឥឡូវយើងនិយាយអំពីបទល្មើសធ្ងន់និងបទល្មើសស្រាល។ ថាតើថ្នាក់ស្រុក និងថ្នាក់ឃុំ ហ្នឹងអាចសម្រេចបាន<ដោយរបៀបណាដែល>ថា អំពើណាមួយ ឬក៏បទល្មើសណាមួយជាបទល្មើស ធ្ងន់ ឬក៏ជាបទល្មើសស្រាលនោះ។ តើលោកដឹងដែរឬទេថា តើគេមានលក្ខណៈវិនិច្ឆ័យអ្វីក្នុងការកំណត់ ថាតើបទល្មើសណាមួយជាបទល្មើសស្រាល បទល្មើសណាមួយជាបទល្មើសធ្ងន់?

**ឆ៖** បាទ បទល្មើសស្រាលដូចថា ក្នុងសហករណ៍ហ្នឹងមានចានមានឆ្នាំង យកចានយកឆ្នាំង របស់ដាក់ទឹក ហ្នឹងវាទំនាស់ស្រាលដែរហ្នឹង ប៉ុន្តែគេយកទៅសម្លាប់ដូចគ្នាហ្នឹង។ ឯទំនាស់ខ្លាំងគឺ កា.ហ្សេ.បេ និង សេ.អ៊ី.អា អាហ្នឹងទំនាស់ធ្ងន់ គេចាប់អត់មានសិទ្ធិសួរថាអ្នកឯងធ្វើអីៗខុស អត់ទេ ចាប់តែម្តង ទៅបាត់ហើយ។ អត់មានសម្រេចពីខេត្ត អត់មានសម្រេចពីណាទេ ស្រុកចាប់កន្លែងគាត់ ហ្នឹងតែម្តង។

**ស៖** ចុះការបដិសេធមិនធ្វើការជាបទល្មើសស្រាល ឬក៏បទល្មើសធ្ងន់? តើលោកអាចប្រកែក មិនធ្វើការប៉ុន្មានដងទើបអាចចាត់ទុកថា ការប្រកែកមិនធ្វើការនេះជាបទល្មើសធ្ងន់?

**ឆ៖** បាទ រឿងការងារ ធ្វើសិប្បកម្មក៏ការងារ ទំនាស់សហករណ៍វាអត់ទៅច្រូត អត់ទៅរែកដី ក៏ ស្រាល គេអត់យកទោសពៃរ៍អីទេ។ គេថា ជំងឺគ្រុនទទ្បាយ អាហ្នឹងគេថា គេលាបពណ៌ថា មនុស្ស ខ្ជិល។ មនុស្សខ្ជិលហ្នឹងគេហៅថាមនុស្សជំងឺគ្រុនទទ្បាយ អត់មានពេទ្យមកណាមើលទេ មានតែយកដូង អំបិល គេនិយាយតែប៉ុណ្ណឹង។

[១៤:៣៥:០៣]

**ស៖** ប្រជាជនដែលត្រូវបានគេចោទថាខ្ជិល ឬក៏ធ្វើពុត<ឈឺ>ហ្នឹងត្រូវបានគេដកហូតរបបម្ហូប អាហារដែរឬទេ?

**ឆ៖** ថាម៉េច? ស្តាប់អត់បានទេ សូមមានប្រសាសន៍ម្តងទៀត។

**ស៖** អត់បញ្ហាទេ លោកសាក្សី។ ខ្ញុំចង់និយាយពីប្រជាជនដែលមិន<បំពេញភារកិច្ច>ការ <ងារ>ដែលគេចោទថាជាមនុស្សខ្ជិលច្រអូស ឬក៏ប្រជាជនដែលគេចោទថាធ្វើពុតជាឈឺមិនធ្វើការ នោះ។ តើមនុស្សទាំងអស់ មនុស្សបែបហ្នឹងត្រូវបានគេដកហូត ឬក៏គេបង្អត់អាហារដែរឬទេ?

**ឆ៖** បាទ មនុស្សដែលលក្ខណៈពុតត្បុតខ្ជិលអត់ទៅធ្វើការហ្នឹងច្រើនតែពួកបងប្អូនអង្គការស្រុក អង្គការឃុំទេ។ គេឲ្យធ្វើមេក្រុមមេអីចឹងទៅ ដាក់ផែនការឲ្យគេហើយ ថា៖ “ឯងនាំគ្នាទៅធ្វើទៅ ខ្ញុំឈឺ

ពោះអី ចុកពោះអី ហើយក៏ខ្យល់ចាប់អ៊ីចឹង" ប្រាប់គេអ៊ីចឹង ហើយខ្ញុំថាខ្លួនដាក់ការងារឲ្យគេហើយ អត់ទៅធ្វើ នៅដេកអេះពោះ ថាតែប៉ុណ្ណឹងគេយំសោកបោកខ្លួនប្រាប់បងប្អូនគេ។

[១៤:៣៦:៥៥]

**ស៖** ពាក់ព័ន្ធទៅនឹងប្រជាជនមូលដ្ឋាន <ឬប្រជាជនសាមញ្ញ> តើពួកគេមិនប៉ាននិយាយថាពួកគេឈឺអ៊ីចឹងមែនទេ? ពួកគេមិនដែលប៉ានប្រាប់ថាគេឈឺអ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់ៗប្រាប់ទេ ប៉ុនបើថាឈឺមែន កូនចៅគេទៅសុំប្រធានរោងបាយ គេថាម៉ែខ្ញុំឈឺអ៊ីចេះ ឈឺអ៊ីចុះ សុំបាយយកឲ្យគាត់ហូប គាត់មកមិនដល់។ អ៊ីចឹងគេឲ្យបបរមួយចាន យកមកឲ្យម៉ែហូបនៅផ្ទះទៅ គេថាឈឺមែន គេទទួលស្គាល់ឈឺ អត់ដែលថាឈឺពុតខ្ជិលអត់ធ្វើការនោះទេ។

**ស៖** ខ្ញុំនឹងដកស្រង់នូវឃ្លាមួយ ឯកសារ <E319/12.3.2> សំណួរចម្លើយទី១៤៨ គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ យាយហឿន ដែលគេនិយាយអំពីសកម្មភាពពីរទាក់ទងទៅនឹងការលួចអាហារ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស "អ្នកដែលលួចដោយសារឃ្លានជាបទល្មើសស្រាល។ ទី២ លួចញឹកញាប់ និងមានកម្រិតខ្ពស់ជាងទី១ នោះថ្នាក់ក្រោមនឹងរាយការណ៍មកដល់ខ្ញុំ។ ចំពោះចំណុចទី២ មានអ្នកដែលប្រព្រឹត្តនឹងត្រូវគេចាប់ខ្លួន ហើយមានអ្នកខ្លះឃើញត្រឡប់មកវិញ ហើយខ្លះក៏មិនឃើញត្រឡប់មកវិញទេ"។ សូមបញ្ចប់ការដកស្រង់។

តើលោកយល់ស្របជាមួយ យាយហឿន ដែរឬទេ នៅពេលគាត់និយាយថាអ្នកដែលលួចដោយសារឃ្លាន គឺជាបទល្មើសស្រាល ប៉ុន្តែអ្នកដែលលួចញឹកញាប់នឹងក្លាយទៅជាបទល្មើសធ្ងន់។ តើលោកយល់ស្របជាមួយ យាយហឿន ដែរឬទេ?

**ឆ៖** បាទ អត់ស្របទេ ព្រោះគាត់នៅស្រុក១០៥ហ្នឹង គឺអត់មានយកទោសពៃរ៍អីទេ អាលួចទៅលួចដំឡូងមីគេដាំ លួចដុតស៊ីនៅចម្ការហ្នឹង លួចតាមចិត្តក៏អត់មានអត់ថាអីទេ គ្នាឯង អាគ្នាមូលដ្ឋានទៅស៊ីទៅកាយយកមកស៊ីនៅផ្ទះហ្នឹងក៏គេអត់រករឿងដែរ។ អត់ដែលមានទោសពៃរ៍អីផងហ្នឹង គេអត់ដែលថាទោសអ៊ីចេះទោសអ៊ីចុះទេ ឃើញតែគេយកមកស៊ីគ្រប់តែគ្នា ដំឡូងរួម។

[១៤:៣៩:៥៨]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាដល់ពេលវេលាល្អហើយប្រសិនបើយើងអាចឈប់សម្រាក។ តើលោកប្រធានថាយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក ឯក ហឿន ឥឡូវដល់ពេលសម្រាកហើយ យើងសម្រាកចាប់ពីឥឡូវនេះទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ នៅពេលដែលម៉ោងបីលោកមកកាន់កន្លែងផ្តល់សក្ខីកម្ម ដើម្បីបន្តការផ្តល់សក្ខីកម្មតទៅទៀត ណ៎ាលោក ឯក ហឿន!

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោក ឯក ហឿន?

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

យើងបន្តដំណើរការនីតិវិធីសវនាការតទៅទៀត លោក ឯក ហឿន?

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ឬក៏និងសហមេធាវីនាំមុខតំណាង

ដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសតការតាំងសំណួរដេញដោលចំពោះសាក្សី ឯក ហឿន បន្ត។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងតាំងសំណួរទៅកាន់សាក្សីប្រហែលជា <៣៥ ទៅ ៤០នាទី> ទៀតទេ។ ហើយសហការីរបស់ខ្ញុំ <ទី ស្រ៊ុនណា> គឺថា នឹងសួររយៈពេល <២០នាទីចុងក្រោយ>។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី លោកប្រហែលជាអស់កម្លាំងហើយ ដូច្នេះខ្ញុំសូមឲ្យលោកផ្ដោតការយកចិត្តទុកដាក់ដើម្បីយើងពិភាក្សាទៅលើប្រធានបទសំខាន់ៗ គឺពាក់ព័ន្ធទៅជោគវាសនានៃប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ហើយនិងជោគវាសនារបស់<វៀតណាម ឬ>ខ្មែរកម្ពុជាក្រោមដែលមក<ពីកម្ពុជាក្រោម> ហើយខ្ញុំនឹងអានសម្រង់ចេញពីចម្លើយរបស់លោកដែលបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E319.1.32 គឺសំណួរចម្លើយ ៣៣ និង៣៤។

[១៥:០៣:៣៥]

"សំណួរ៣៣៖ តើមានខ្មែរក្រោម – គឺខ្មែរដែល<មកពីដែនដីខ្មែរក្រោម ដែលស្ថិតនៅ>វៀត-ណាម<ភាគខាងត្បូង>សព្វថ្ងៃដែលរស់នៅក្នុងតំបន់របស់លោកចន្លោះពីឆ្នាំ១៩៧៦ដល់៧៨ ដែរឬទេ? <តើលោកដឹងថា មានអ្វីកើតឡើងចំពោះពួកគេដែរទេ?> ហើយលោកបានឆ្លើយនៅត្រង់ចម្លើយ ៣៣ ថា៖ អត់មានខ្មែរក្រោមទេ អត់មានខ្មែរក្រោមដែលរស់នៅក្នុងតំបន់របស់ខ្ញុំទេ គឺមានតែប្រជាជនវៀតណាម។ នៅពេលនោះវៀតណាមដែលបានកើតនៅក្នុងទឹកដីកម្ពុជាទាំងអស់ ត្រូវបានគេចោទថាជាយួន។ ហើយវៀតណាមដែលមកពីទឹកដីកម្ពុជាក្រោម ដូចជាម្ដាយរបស់ខ្ញុំនៅក្នុងភូមិត្រពាំងជ្រៃ ជាដើម ឧទាហរណ៍ គឺត្រូវសម្លាប់ចោលទាំងអស់។ សំណួរ៣៤<សួរដោយអ្នកស៊ើបអង្កេត៖ យើង>គិតថា យើងទាំង<ពីរនាក់ចង់សំដៅទៅខ្មែរក្រោមដូចគ្នា។ តើគេចាត់ចំណាត់ថ្នាក់មនុស្សយ៉ាងម៉េច ដើម្បីធ្វើយុត្តិកម្មសម្លាប់?> ហើយចម្លើយរបស់លោក<ក្នុងសំណួរ៣៤នោះ>គឺថា វៀតណាមដែលមាន<ប្រពន្ធ>ខ្មែរក៏ត្រូវគេសម្លាប់។ ហើយអ្នកដែលយកប្រពន្ធវៀតណាមក៏ត្រូវគេសម្លាប់ផងដែរ គឺសម្លាប់ទាំងភូមិតែម្ដង"។ បញ្ចប់ការដកស្រង់។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលោកនូវអ្វីដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនៅក្នុងចម្លើយទាំងពីររបស់លោក។ ដំបូងលោកឆ្លើយថា វៀត-ណាមដែលកើតនៅក្នុងប្រទេសកម្ពុជាត្រូវបានចោទប្រកាន់ថាជាយួននៅក្នុងរបបកម្ពុជាប្រជាធិបតេ-យ្យ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថាពាក្យ "យួន"<>ត្រូវបានគេប្រើសម្រាប់ជាការ

មាក់ងាយ សម្រាប់ជាការប្រមាថបែបនេះ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ចំពោះយួនដែលកើតកំណើតនៅក្នុងទឹកដីកម្ពុជា គឺនៅមាន នៅឃុំត្រពាំងធំចុងខាងត្បូង ហើយនៅស្ថិតក្នុងឃុំត្រពាំងជ្រៃ។ យួននោះនៅស្ថិតនៅក្នុងភូមិត្រពាំងកំប្រែ នៅជាប់ក្នុងភូមិត្រពាំងកោះ មានប្រាំមួយប្រាំពីរគ្រួសារហ្នឹង។ អាខ្លះប្រពន្ធ ប្ដីខ្មែរ អាខ្លះប្ដីខ្មែរប្រពន្ធយួន គឺមានទាំងអស់។ គ្រួសារហ្នឹងគេៗនាំទៅព្រៃ ផែនការ យាយខុម ឲ្យនាំទៅព្រៃ។ ហើយអាឥសី កែម ប្រពន្ធយួន គេថា “កុំបាច់ទៅអី កែម ឯង។ យី! អញចង់ទៅរៀនសូត្រជាមួយគេឲ្យហើយ អញខ្ជិលទៅក្រោយអ្នក! គេរុញខ្នងឲ្យមកវិញក៏មិនមក។ អ៊ីចឹងទៅៗអ៊ីចឹង។ ទៅជាមួយប្រពន្ធទៅ”។ ដល់ព្រៃអត់ឃើញត្រឡប់មកវិញទេ ចប់ត្រឹមហ្នឹងហើយ។ អាហ្នឹងរឿងយួនហ្នឹង។ គេអត់ជំនុំជម្រះ អត់សួរអីទេ គេយកសម្លាប់តែម្ដង។

[១៥:០៧:១៨]

**ស៖** ខ្ញុំយល់មិនច្បាស់ទេ តើលោកកំពុងនិយាយសំដៅអ្នកណា? គឺអ្នកណាដែលលោក -- លោកកំពុងនិយាយសំដៅអ្នកដែលលោកស្គាល់ ឬសំដៅទៅលើសមាជិកក្រុមគ្រួសាររបស់លោក?

**ឆ៖** បាទ និយាយសំដៅប្រជាជនក្នុងមួយភូមិនៅក្នុងភូមិត្រពាំងកោះ គេហៅថា ភូមិត្រពាំងកំប្រែហ្នឹង។ ភូមិម្ដុំយួនហ្នឹងគេហៅត្រពាំងកំប្រែ អាភូមិហ្នឹងសុទ្ធតែភូមិយួនទាំងអស់ ប្ដីខ្មែរ-ប្រពន្ធ ប្ដីយួន-ប្រពន្ធខ្មែរហ្នឹង វានៅក្នុងកម្ពុជាវាពាក់ព័ន្ធគ្នាអ៊ីចឹង។ ដល់តែផែនការ យាយខុម គេបោសសម្អាតយួន គេយកយួនមួយភូមិហ្នឹងទៅសម្លាប់អស់ទៅ។

**ស៖** តើមានការចាប់ខ្លួនប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាដែរឬទេ ឬក៏ប្រជាជនវៀតណាម ឬក៏ខ្មែរដែលមកពីកម្ពុជាក្រោយពី ខុម បានចេញពីស្រុកត្រាកក់នៅក្នុងឆ្នាំ១៩៧៦? តើការចាប់ខ្លួន និងការសម្លាប់បន្តពីនោះមកទៀតទេ ក្រោយពេល ខុម ចេញពីស្រុកត្រាំកក់ទៅ?

[១៥:០៨:៤១]

**ឆ៖** បាទ យាយខុម ចេញទៅ, ចេញ យាយខុម ចេញ៧៦ ខែ៣ គាត់ចេញបាត់ពីស្រុកហើយទៅខេត្តកោះកុងហើយ។ ហើយ៧៦ ខែ៣ហ្នឹង មានផែនការបោសសម្អាតយួនក្នុងប្រទេសកម្ពុជាទាំងមូល ដូចស្រុក១០៥អ៊ីចឹង។ ផែនការ តាចាយ មិនដឹងគាត់ទទួលពី មិនដឹងទទួលពីថ្នាក់ណាទេ។ គាត់ប្រជុំសម្រេចឲ្យឈ្មោះ ឡួន ហៅ ម៉ូញ ហ្នឹងដើរចាប់បងប្អូនវៀតណាមដែលនៅស្រុក១០៥ហ្នឹង គឺចាប់ៗប្រមូលទាំងអស់។ ទៅលើកទី១ ថាឲ្យមេឃុំប្រមូលជនជាតិយួនដាក់ម្ដុំ គេយកឡានមកដឹក។ ដល់

បានបីថ្ងៃ ឡូន យកឡានអាយ៉ាម៉ុង អាឡានវែងហ្នឹងទៅដឹក។ ដឹកហ្នឹងដឹកទី១ ឃុំលាយបូរ, ទី២ ឃុំពពេល, ទី៣ ឃុំតាភេម, ទី៤ ឃុំគុស, ទី៥ ឃុំអង្គតាសោម, ទី៦ ឃុំញ៉ែងញ៉ង, ឃុំសំរោងអាហ្នឹងម្ចាស់ការហើយ ម្ចាស់ការខ្លួនឯងតាមឃុំហើយ។ មានតែយកពីប៉ុន្មានឃុំខាងក្រោមៗ ដែលដាច់ស្រយាលពីព្រៃហ្នឹង គេឲ្យឈ្មោះ ឡូន ហៅ ម៉ូញ ហ្នឹងទៅដល់ដឹកហើយ ប្អូនថ្លៃ តាម៉ុក ផ្ទាល់ហើយហ្នឹង។ បាទ តែប៉ុណ្ណឹងទេ រឿងហ្នឹង គេយកទៅសម្លាប់ចោលក្នុងព្រៃ។

**ស៖** បាទ មិនជាថ្វីទេ ខ្ញុំព្យាយាមសួរតាមលំដាប់លំដោយ។ ទី១ តើមានអំឡុងពេលណាមួយដែលគេបានចាប់ផ្តើមដោះដូរប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាជាមួយនឹងខ្មែរមកពីកម្ពុជាក្រោម។ តើមានការដោះដូរប្រជាជនបែបនេះដែរទេ?

**ឆ៖** បាទ ជម្រាបប្រសាសន៍ មានៗពិតណាស់។ កាលពីឆ្នាំ៧២ ពេលជំនាន់ លន់ នល់ គេកាន់អំណាច ប្រជាជនម្តុំកោះអណ្តែត១០៦, ១០៧ គឺរត់ចូលទៅស្រុកយួន ទៅនៅស្រុកយួន។ ដល់ពេលរំដោះទូទាំងប្រទេស តាម៉ុក យកយួននៅក្នុងទឹកដីប្រទេសកម្ពុជាហ្នឹង ទៅដូរយកខ្មែរនៅស្រុកយួន។ ដល់តែដូរបានយួនមក អាយួនហ្នឹងវាទំនាស់សហករណ៍ វាចេះតែលួចចប លួចកាំបិត លួចពូថៅក្នុងសហករណ៍ បោះដាក់ទឹក។ បោះឆ្នាំង បោះចាន បោះដាក់ទឹក។ អ៊ីចឹង តាម៉ុក លែងដូរហើយ។ ពិបាកគ្រប់គ្រងណាស់ពួកអស់ហ្នឹង លែងដូរ។ កើតបាន តាចាយ -- ឲ្យផែនការ តាចាយ ដើរចាប់ប្រមូលយកទៅបាត់ៗទៅ។ អាហ្នឹងរឿងហ្នឹងដែលដូរ។ ដូរហ្នឹងយកមកនៅអត់សុខទេ។ យប់ឡើង ដើរលួចចប លួចនង្គ័ល លួចរនាស់ បោះដាក់ទឹកអស់ហើយ រកអីធ្វើការអត់មានទេ។ អ៊ីចឹង តាម៉ុក លែងដូរហើយ។

[១៥:១២:០៥]

**ស៖** តើមានប្រជាជនខ្មែរក្រោម ឬប្រជាជនវៀតណាម ដែលគេនាំ -- គេបញ្ជូនពីប្រទេសវៀតណាមមកដែរឬទេ នៅពេលដែលកងទ័ពកម្ពុជាប្រជាធិបតេយ្យ ចូលទៅក្នុងទឹកដីវៀតណាម?

**ឆ៖** បាទ គឺដូរហ្នឹង គឺខ្មែរវាភៀសខ្លួនឆ្នាំ៧២ រត់ទៅស្រុកយួនហ្នឹង។ ដល់រំដោះទូទាំងប្រទេស តាម៉ុក យកៗយួននៅកម្ពុជា ទៅដូរខ្មែរនៅស្រុកយួនហ្នឹង យកមក។ អាខ្មែរហ្នឹងមកដល់ លួចពេក គេ -- តាម៉ុក លែងដូរទៅ។ ទុកៗឲ្យ តាចាយ ដើរចាប់ ដើរយកទៅព្រៃអស់ទៅ។

**ស៖** បាទ មិនអីទេ។ លោកបានឆ្លើយថា នៅត្រង់ចម្លើយ៦២នៃ<កំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោក> ឯកសារ E319.1.32 ថា "ក្រោយមកមិនមានការដោះដូរ<ជាមួយវៀតណាម>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទេ ប៉ុន្តែមានការសម្លាប់ប្រជាជនវៀតណាមនៅក្នុងប្រទេសកម្ពុជា"។ បញ្ចប់ការដកស្រង់។ តើលោកអាចប្រាប់បានទេ តើកម្មវិធីដោះៗដូរប្រជាជនហ្នឹង ចប់នៅពេលណា ហើយការកាប់សម្លាប់ប្រជាជនវៀតណាមហ្នឹង ចាប់ផ្តើមនៅពេលណា?

[១៥:១៣:៤១]

**ឆ៖** បាទ ចាប់ពី៧៦ឡើងទៅ គឺមានផែនការ ៗដោះដូរខ្មែរដែលរត់ទៅស្រុកយួន ដូរយកខ្មែរពីស្រុកយួន មកដូរយួននៅស្រុកខ្មែរ ទៅស្រុកយួន។ ដល់តែដូរទៅវាគ្រប់គ្រងអត់បាន លែងដូរ។ អ៊ីចឹងដល់តែឈប់ដូរ ពួកកម្ពុជាក្រោមអត់មានមករស់នៅក្នុងស្រុកត្រាំកក់ទេ អត់មានទេ មានតែជនជាតិយួនកំណើតនៅស្រុកខ្មែរហ្នឹងហ្នង។ ហើយ ប៉ុល ពត ក៏សម្លាប់ជនជាតិយួន។ ចំពោះ លន់ នល់ ក៏សម្លាប់ជនជាតិយួនដែរ ប្រមូលយកដាក់ក្នុងតាកែវក្រុងហ្នឹង ប្រមូលយួនហ្នឹងរាប់ម៉ឺនរាប់សែន យកដាក់ក្នុងសាលា។ សាលារៀនហ្នឹងគេហៅថា "សាលាដៃប្រាំ"។ សាលាហ្នឹងគំនូររូបចម្លាក់គេធ្វើដៃប្រាំម្ខាង គេហៅថាសាលាដៃប្រាំហ្នឹង យកទៅដាក់ក្នុងហ្នឹងហើយ ឲ្យទាហាននាំគ្នាទៅព័ទ្ធបាញ់ ៗឮសូរកក្រើកដី ដូចគេច្បាំងគ្នា គ្រាប់តូចគ្រាប់ធំ ចុះមនុស្សរាប់សែន សុទ្ធតែយួន បាញ់សម្លាប់ទាំងអស់។ ចុះខ្មែរក្រហម ក៏សម្លាប់ លន់ នល់ ក៏សម្លាប់។ លន់ នល់ សម្លាប់បានច្រើនណាស់ ខ្មែរក្រហមសម្លាប់បានតិចទេ។

**ស៖** ឥឡូវ សុំផ្តោតតែបញ្ហានៅក្នុងរបប ប៉ុល ពត <បានហើយ ពីព្រោះនេះជា>អ្វីដែលត្រូវឆ្លើយនៅចំពោះមុខតុលាការនេះ។ ខ្ញុំសុំការបញ្ជាក់ទាក់ទងទៅនឹងប្រជាជនខ្មែរដែលមកពីកម្ពុជាក្រោមដែលបានរស់នៅកម្ពុជាក្រោមជាយូរយារមកហើយ ហើយ<ប្រហែល>អាចនិយាយជាភាសាខ្មែរនៅតាមផ្ទះសម្លេងរបស់គេផង។ ហើយយោងទៅតាមខ្មែរក្រហម តើគេចាត់ទុកប្រជាជនទាំងនោះជា <ប្រជាពលរដ្ឋ>ខ្មែរ <ឬក៏គេចាត់ទុកអ្នកទាំងនោះនៅក្នុងក្រុមជាជនជាតិវៀតណាម?>

**ឆ៖** បាទ សូមជម្រាប ប្រជាជនកម្ពុជាក្រោមអត់មានមករស់នៅតាកែវទេ។ គ្រប់ស្រុកទាំងប្រាំហ្នឹងអត់មានកម្ពុជាមកទេ មានតែជនជាតិវៀតណាមស្ថិតនៅក្នុងកម្ពុជា កំណើតនៅកម្ពុជាហ្នឹង។

[១៥:១៦:៣៨]

**ស៖** បាទ យើងនឹងពិនិត្យមើលឯកសារមួយចំនួនទៀត នៅត្រង់សំណួរចម្លើយ៣៤ <ដែលខ្ញុំបានដកស្រង់មុនហ្នឹងបន្តិច>ថា ស្ត្រីវៀតណាមដែលរៀបការជាមួយប្តីខ្មែរក៏ត្រូវបានសម្លាប់ចោលក៏ដូចគ្នា <ហើយដូចគ្នាដែរ បុរសខ្មែររៀបការជាមួយស្ត្រីវៀតណាម។> -- ចុះចំពោះកូនៗអ្នកដែលមានរៀបការខ្មែរ<កើតចេញពីប្តីប្រពន្ធ>ជាមួយវៀតណាម វៀតណាមការជាមួយខ្មែរ តើកូនៗអ្នកទាំង

នោះមានជោគវាសនាដូចឪពុកម្ដាយរបស់គេដែរឬទេ?

**ឆ៖** បាទ ហ្នឹងវាជាការធម្មតាៗ ខ្មែរយកប្រពន្ធយួន យួនយកប្ដីខ្មែរ គឺជារឿងធម្មតាដូចតែខ្មែរនៅកម្ពុជាអ៊ីចឹងដែរ គេអត់មានយកទោសពៃរ៍អីទេ ដល់មកជំនាន់ខ្មែរក្រហមនេះគេបែងចែកវណ្ណៈ ដល់បែងចែកវណ្ណៈ គេថាវណ្ណៈផ្សេងមកយកប្ដីខ្មែរវា *(ឮមិនច្បាស់)* បរកង់ប្រវត្តិសាស្ត្រកិនអ៊ីចឹងហ្មង។ លន់នល់ ក៏កិន ខ្មែរក្រហមក៏បរកង់ប្រវត្តិសាស្ត្រកិន កិនដូចគ្នា។ អ៊ីចឹង យួននៅកម្ពុជាអស់រលីង អត់មាននៅសល់នៅក្នុងតាកែវ។

**ស៖** សំណួរខ្ញុំគឺសួរជាក់លាក់ទៅនឹងកូនៗអ្នកដែលការបញ្ច្រាស់គ្នានេះ គឺប្រពន្ធប្ដីខ្មែរវៀតណាមនេះ តើជោគវាសនារបស់ក្មេងៗទាំងនោះ កូនៗទាំងនោះ ដូចឪពុកម្ដាយរបស់គេដែរទេ?

**ឆ៖** អត់យល់ទេ សុំអត់ដឹង ស្ដាប់ន័យអត់បាន។

**ស៖** ខ្ញុំព្យាយាមតាំងសំណួរឲ្យបានងាយស្រួលជាងនេះ។ ឧទាហរណ៍<ងាយៗ>ថា<ឪពុកវៀតណាមកើតនៅស្រុកខ្មែរ ហើយ>ម្ដាយ<ជាខ្មែរ។ ពួកគេ>មានកូនប្អូន<នាក់> ហើយលោកបានឆ្លើយថាយ៉ាងដូច្នេះ លោកថាស្ត្រីដែលរៀបការជាមួយប្ដីខ្មែរត្រូវសម្លាប់ចោល ហើយស្ត្រីខ្មែររៀបការជាមួយប្ដីវៀតណាមក៏ត្រូវសម្លាប់ចោល។ តើកូនៗនេះ អ្នកដែលមានកូនកាត់អ៊ីចឹង តើជោគវាសនារបស់អ្នកនោះយ៉ាងម៉េចដែរ? តើអង្គការយកអ្នកនោះទៅសម្លាប់ចោល ឬក៏អង្គការយកទាំងនោះទៅដាក់នៅទីកន្លែងណាមួយផ្សេង?

**ឆ៖** បាទ អត់មានចោលទេ អត់មានយកទៅដាក់កន្លែងណា គេយកទៅទាំងគ្រួៗ ទាំងសម្បុកៗ យកទៅព្រៃទាំងអស់ហ្នឹង អាផ្ទៃពោះ កូនក្នុងពោះក៏គេនាំទៅ បីទទឹងក៏គេនាំទៅ មានអ្នកណានៅសល់!

[១៥:១៩:៥៨]

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា ខ្មែរក្រហមហ្នឹងគេៗចាត់ថ្នាក់ហ្នឹងដោយរបៀបម៉េច? នៅទីនេះ គឺថាយើងកំពុងតែនិយាយអំពីក្មេងៗទេ។ តើការ -- តើខ្មែរក្រហមហ្នឹងគេពន្យល់មូល-ហេតុថាដូចម្ដេចដែរ?

**ឆ៖** អត់ដែលដឹងគេពន្យល់ម៉េចទេ អត់បានដឹង អត់បានឮផង។

**ស៖** មិនអីទេ លោកបាននិយាយថានៅក្នុងឆ្នាំ១៩៧៦ គឺថាការសម្លាប់បំបាត់ជាតិសាសន៍ទាំងមូលនេះគឺត្រូវបានចាប់ផ្ដើមឡើងដោយមានទិសសម្លាប់ជនជាតិវៀតណាមទាំងអស់ដែលរស់នៅស្រុកត្រាំកក់ <លោកលើកឡើងនៅ>ត្រង់ចម្លើយ<៣៦>នៃ<កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោក

ក្នុង>ឯកសារ <E319.1.32>។ តើការធ្វើបែបនេះវាមានបន្តមកដល់ក្នុងឆ្នាំ១៩៧៧ ដែរទេ?

**ឆ៖** អត់មានបន្តចូលដល់ឆ្នាំ៧៧ទេ គឺអស់មានការធ្វើបាបរាស្ត្រតទៅទៀតហើយ ចប់ត្រឹមហ្នឹងហើយ។ គ្រូអ៊ួច ដើរធ្វើចៅហ្វាយស្រុក គឺចប់អត់ចាប់ចង អត់មានយកទោសយកពៃរ៍អីទេ គឺប្រជាជនសុខសាន្តទាំងអស់គ្នាហ្នឹង។ យាយអ៊ួច ហើយ យាយហឿន ហ្នឹងក៏ -- គ្រូអ៊ួចហ្នឹង អត់ដែលមានការកាប់សម្លាប់អីតទៅទៀតទេ ចប់ហើយ។ សម្លាប់ប្រជាជនហើយអស់ វៀតណាមក៏មិនឲ្យមានសល់អី មានអីត្រូវសម្លាប់ទៀត។ ចប់ត្រឹមហ្នឹងទៅ។

[១៥:២២:០២]

**ស៖** ខ្ញុំសូមរំឭកថា យាយហឿន បាននិយាយថា គាត់ត្រូវបានគេចាត់តាំងឲ្យទៅជាអនុប្រធានស្រុកនៅក្នុងខែតុលា ១៩៧៨ មិនមែនឆ្នាំ១៩៧៧ទេ។ ទាក់ទងទៅនឹងការបរិច្ឆេទនេះ ដើម្បីជួយរំឭកដល់ការចងចាំរបស់លោក ខ្ញុំសូមដកស្រង់ចម្លើយរបស់សាក្សីដែល<បានមកផ្តល់សក្ខីកម្មនៅទី>នេះ។ គឺសាក្សីម្នាក់ឈ្មោះ ជាំង ស្រីមុំ ឯកសារ E3/5832 សាក្សីរូបនេះរស់នៅក្នុងឃុំញ៉ែងញ៉ង នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានឆ្លើយដូចតទៅ នៅត្រង់ចម្លើយលេខ១៤<ក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់> ដែលគាត់ឆ្លើយថា សូមដកស្រង់៖ “មកដល់<ចុង>ឆ្នាំ១៩៧៦ មេឃុំបាននិយាយថាប្រជាជនវៀតណាមត្រូវបញ្ជូនត្រឡប់ទៅប្រទេសរបស់ពួកគេវិញ។ ខ្មែរខ្លះក៏ត្រូវបានកុហក ហើយថាខ្លួនឯងខ្មែរសោះថាខ្លួនជាវៀតណាម។ <សូម្បីក៏ជនជាតិខ្មែរខ្លះ បានកុហកថាខ្លួនជាជនជាតិវៀតណាម ដោយសារតែរងទម្ងន់ស្ថានភាពលំបាកពេក។>ប្រជាជនទាំងអស់នេះក៏ត្រូវបានគេយកទៅសម្លាប់ចោល ហើយនៅក្នុងដំណាក់កាលដំបូងក្នុងឆ្នាំ១៩៧៦ ប្រជាជនវៀតណាមត្រូវបានបញ្ជូនទៅប្រទេសរបស់គេ<មែន> ប៉ុន្តែនៅដំណាក់កាលទី២ ពួកគេទាំងអស់ត្រូវបាននាំខ្លួនយកទៅសម្លាប់ចោលទាំងអស់។” បញ្ចប់ការដកស្រង់។

លោកនៅចាំបានទេ នៅក្នុងការប្រកាសមួយពីថ្នាក់ស្រុកទៅមេឃុំ មកដល់<ចុង>ឆ្នាំ១៩៧៦ ពាក់ព័ន្ធទៅនឹងប្រជាជនវៀតណាមដែលដូចដែលសាក្សីឈ្មោះ ជាំង ស្រីមុំ នេះគាត់បាននិយាយនេះ លោកនៅចាំទេ?

**ឆ៖** បាទ អត់ដែលបានឮទេ ប៉ុន្តែរឿងហ្នឹងវាជាការពិតណាស់ហើយ អត់ខុសទេ អត់ដែលឮអ្នកស្រីហ្នឹងនិយាយទេ។ ប៉ុន្តែក្នុងអង្គការស្រុកគឺធ្វើជាក់ស្តែងអ៊ីចឹងមែនហ្នឹង។ ថាឲ្យទៅស្រុកមែន ប៉ុនអត់យកទៅស្រុកទេ យកទៅព្រៃ។

[១៥:២៤:៤៤]

**ស៖** ពីមុននេះ លោកនិយាយអំពីគោលនយោបាយជាតិ ជាគោលនយោបាយថ្នាក់ជាតិ <សម្រេច>កម្ចាត់ប្រជាជនវៀតណាម។ តើការបញ្ជានេះបញ្ជាមកពីណាដែរ? គឺការបញ្ជាឲ្យបង្ក្រាប វត្តមានរបស់ប្រជាជនកម្ពុជា -- ប្រជាជនវៀតណាមនោះ? តើលោកមានបានដឹងពិតប្រាកដទេថា ការបញ្ជានេះមកពីណាដែរ មកពីមជ្ឈិម មកពីបក្ស មកពីភូមិភាគនិរតី មកពី<តំបន់> ឬក៏យ៉ាងណា?

**ឆ៖** បាទ ត្រង់ហ្នឹងអត់បានជ្រួតជ្រាប អត់បានដឹងទេ ព្រោះថា ផែនការអីស្រុកទទួលតែពីខេត្ត ហ្នឹង រឿងពីមជ្ឈិមពីអីអត់បានដឹងទេ ឃើញគាត់មកពីខេត្ត ខេត្តមកឲ្យស្រុក ស្រុកចេះតែឲ្យឃុំ តែ ប៉ុណ្ណឹងដឹង អាហ្នឹងឃើញទាក់ទងគ្នាជាប់។ រឿងមជ្ឈិមដែលមក អត់ដែលមកទេ អត់ដែលមានសំបុត្រ មកទេ។ មជ្ឈិមមកគេមកតែត្រឹមខេត្តហ្នឹង ខេត្តគេម៉េចឲ្យសំបុត្រមជ្ឈិមមកស្រុក។ អ៊ីចឹងដឹងតែប៉ុណ្ណឹង ទេ អត់ដឹងវែងឆ្ងាយទេ។

**ស៖** បាទ ល្អហើយ។ ខ្ញុំសូមអានចម្លើយរបស់លោកម្តងទៀតគឺឯកសារ E319.1.32 ត្រង់ សំណួរចម្លើយ៣៧ <និងត្រង់សំណួរចម្លើយ៤៦។> លោកបានធ្វើការញែកពីគ្នារវាងឃុំដែល<មាន សិទ្ធិចាប់ និង>សម្លាប់ប្រជាជនវៀតណាម<ដោយខ្លួនឯង និងឃុំដែលថ្នាក់ស្រុកជាអ្នកចាត់ចែងវិញ> ។ នេះគឺជាអ្វីដែលលោកបានឆ្លើយនៅត្រង់ចម្លើយលេខ៣៧៖ “នៅក្នុងឃុំខ្ពបត្របែក ឃុំត្រពាំងធំខាង ជើង ឃុំត្រពាំងធំត្បូង ឃុំសំរោង ឃុំគុស និងឃុំ ញ៉ែងញ៉ង។ ឃុំទាំងអស់នោះ គឺមេឃុំម្ចាស់ការខ្លួនឯង មានន័យថាមេឃុំជាអ្នកចាប់យួនទៅសម្លាប់ដោយខ្លួនឯងដោយមានផែនការមកពីថ្នាក់ស្រុក។ តាចាយ ជាអ្នកអនុវត្តបញ្ជាឲ្យសម្លាប់យួនដោយ តាចាយ ទទួលបញ្ជាពីតំបន់”។ ហើយចម្លើយ៤២ -- គឺត្រង់ កន្លែង៤៦ គឺបានឆ្លើយដូចតទៅគឺថា៖ “<គេមិនចាំបាច់ទៅស្រង់ស្រង់ប្រវត្តិរូបអីទេ ពីព្រោះគេស្គាល់ ច្បាស់ហើយថា នរណាជាជនជាតិវៀតណាម។ ដូចខ្ញុំបានលើកឡើងពីដើមគឺថា មានឃុំខ្លះនោះ>មេឃុំ ខ្លួនឯងផ្ទាល់ហ្នឹងគឺជាអ្នកចាប់ប្រជាជនវៀតណាមហ្នឹង យកទៅសម្លាប់ដោយខ្លួនឯង។ ចំណែកឯឃុំ មួយចំនួនផ្សេងទៀត គឺអង្គការជាអ្នកមកចាប់ជនជាតិវៀតណាមទាំងនោះយកទៅសម្លាប់ចោល”។ បញ្ចប់ការដកស្រង់។ លោកនិយាយថា វាមិនចាំបាច់គេស្រង់ប្រវត្តិរូបទេ ព្រោះគេដឹងថាអ្នកណាជា ប្រជាជនវៀតណាមហើយ។ ប៉ុន្តែនៅក្នុងឃុំនីមួយៗ តើគេមានរៀបចំបញ្ជីឈ្មោះប្រជាជនវៀតណាម ឬក៏ប្រជាជនមកពីកម្ពុជាក្រោមដែលរស់នៅក្នុងឃុំទាំងនេះដែរឬទេ? គេមានរៀបចំជាបញ្ជីដែរទេ?

[១៥:២៨:២០]

**ឆ៖** បាទ ឲ្យតែគេ -- ជនជាតិវៀតណាមនោះ គេនិយាយវៀតណាមតែម្តងនៅក្នុងទឹកដីកម្ពុជា និយាយតែជនជាតិវៀតណាម បើនិយាយខ្មែរគេអត់ចាប់ទេ។ គេចាប់តែអ្នកណាដែលចេះនិយាយភាសាគ្នាទៅវិញទៅមកហ្នឹង ភាសាយួនហ្នឹង អាហ្នឹងឃុំខ្ពបត្របែក ទី១, ទី២ ត្រពាំងធំខាងជើង, ទី៣ ត្រពាំងធំខាងត្បូង, ទី៤ ឃុំគុសមួយចំហៀង, ទី៥ ឃុំសំរោង, ទី៦ ឃុំញ៉ែងញ៉ង។ អាហ្នឹងគេម្ចាស់ការនៅជាប់ជើងភ្នំ គេឲ្យម្ចាស់ការវាងខ្លួន។ ហើយដល់ឃុំសំរោង ប្រធានឃុំនោះឈ្មោះ តាខែម គេថា ឲ្យតាខែម ហ្នឹងម្ចាស់ការ។ ដល់ តាខែម គាត់អត់ធ្វើដឹងធ្វើញ យកគេទៅសម្លាប់ គាត់អត់ធ្វើ។ អ៊ីចឹង គេទៅពិនិត្យឃើញថា តាខែម អត់គោរពផែនការចាត់តាំងពីបក្ស។ អ៊ីចឹងគេយក តាខែម ទៅឲ្យកាប់ចម្ការដាំសៀងជាមួយ តាចាយ ទៅ។ អាហ្នឹងចប់ត្រឹមហ្នឹងទៅ។

**ស៖** ដូច្នេះ ប្រជាជនវៀតណាមនៅក្នុងឃុំដែលលោក ដែលបានលើកឡើងនោះ គឺត្រូវបានសម្លាប់ចោលនៅជើងភ្នំ ឬក៏នៅលើភ្នំដំរីរមៀល។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ អត់ត្រឹមត្រូវទេ។ ភ្នំដំរីរមៀលហ្នឹងខ្ពស់ណាស់ គឺគេសម្លាប់នៅជើងភ្នំ ដីវាបជិតវាលស្រែ នៅឯព្រៃខ្មោចកូនក្មេងហ្នឹង គេយកទៅសម្លាប់មូលតែម្តុំហ្នឹង។

**ស៖** ទាក់ទងទៅនឹងប្រជាជនវៀតណាមដែល<មិន>រស់នៅក្នុងឃុំទាំងនោះ ហើយដែលមានស្វ័យភាព <ឬមានការពារពីការកាប់សម្លាប់។ លោកបានឆ្លើយនៅក្នុងសំណួរ៥៤ ក្នុង>ឯកសារ E319.1.32 <ក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោក>លោកបានឆ្លើយដូចតទៅនេះ គឺអ្វីដែលលោកបានឆ្លើយ សូមដកស្រង់៖ "<ម្នាក់ឈ្មោះ ឡូន ហៅមួយ ជា>ប្អូនថ្លៃប្រុស តាម៉ុក គឺជាអ្នកដើរចាប់ជនជាតិវៀតណាម។ <ឡូន បានចាប់ចងប្រជាជននៅក្នុងឃុំអង្គតាសោម> ឃុំពពេល លាយបូរ ឃុំស្រែរនោង<។ ខ្ញុំមិនដឹងថា>ប្រជាជនវៀតណាម<ប៉ុន្មាននាក់>ដែលរស់នៅក្នុងស្រុកត្រាំកក់<ទាំងមូលនោះទេ> ប៉ុន្តែខ្ញុំដឹង<តែ>ចំនួន<វៀតណាម>នៅក្នុងឃុំ<បួន> ពីព្រោះ<ឡូន ប្រាប់ថា គេ>បានបញ្ជូនឡាន<ទៅដឹក>គ្រួសារវៀតណាមចំនួន៩០០០គ្រួសារ<ដែលរស់នៅក្នុងឃុំទាំងបួននោះ> ហើយរបប លន់ នល់ ក៏បានសម្លាប់ប្រជាជនវៀតណាម<ដែរ ហើយ>អ្នកដែលរស់ <គឺអ្នកដែល>នៅក្រៅស្រុកនេះ<ប៉ុណ្ណោះ។ រហូតដល់>របបខ្មែរក្រហម <ក៏ត្រូវយកទៅសម្លាប់ម្តងទៀត>"។ នៅពេលដែលលោកនិយាយថា ឡូន គឺជាអ្នកដើរចាប់ខ្លួនប្រជាជនវៀតណាមទាំងនោះ ហើយសម្លាប់ពួកនេះទាំងនោះចោល តើគាត់ដើរចាប់ខ្លួនតែម្នាក់ឯងទេ ឬក៏មានឈ្លបជួយដើរចាប់ខ្លួនជាមួយគាត់ ឬក៏មាន<សមាជិក>ស្រុកមកជួយដល់ ឡូន នេះដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៣២:០៦]

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ចំពោះ ឡួន មាននាទីតែយកឡានទៅដឹក។ ចៅហ្វាយស្រុក សរសេរសំបុត្រស្នាមទៅឲ្យឃុំ ឃុំប្រមូលជនជាតិវៀតណាមទុកម្តុំ មួយកន្លែង។ ឡួន កំណត់ថាបីថ្ងៃ គេទៅយក ឲ្យប្រមូលឲ្យមូល។ ឡួន បីថ្ងៃយកឡានទៅដឹក ដឹកថាទៅស្រុក ប៉ុន្តែអត់ស្រុកទេ ទៅឡើងភ្នំ។

**ស៖** <លោកថា> ឡួន <ជាប្អូនថ្លៃតាម៉ុក។ នៅពេលដែលគាត់>នាំយកប្រជាជនវៀតណាម ទាំងអស់នោះទៅទីកន្លែងដែលគេសម្លាប់មនុស្ស<> តើគាត់ធ្វើបែបនេះក្រោមបញ្ជារបស់ តាម៉ុក ឬក៏យ៉ាងណា?

**ឆ៖** បាទ អត់មានទទួលបញ្ជាពី តាម៉ុក អត់មានទទួលបញ្ជាពីតំបន់ទេ ទទួលបញ្ជាពី តាចាយ។ តាចាយ សរសេរសំបុត្រគ្រប់ឃុំទាំងអស់ ឲ្យរៀបចំប្រមូលជនជាតិយួនឲ្យដាក់មួយកន្លែង ទុកម្តុំ។ ដល់គ្រប់បីថ្ងៃ ឲ្យឡាន តាឡួន ចូលទៅដឹកដល់កន្លែង គឺឃុំពពេល ឃុំលាយបូរ ឃុំស្រែរនោង ឃុំអង្គតាសោម ឃុំគុសមួយចំហៀង អាហ្នឹង ឡួន ដើរដឹកហើយ។ ក្រៅពីឃុំហ្នឹងគេម្ចាស់ការ នៅជាប់ជើងភ្នំហ្នឹង។

**ស៖** តើ ឡួន ហ្នឹងគឺគាត់ទទួលខុសត្រូវនៅឃុំជាងទង ឬក៏ឃុំផ្សេងទៀតដែរ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ឡួន គាត់នៅក្នុងមន្ទីរស្រុកដែរ ហើយ តាចាយ ក៏នៅធ្វើការក្នុងមន្ទីរហ្នឹង គាត់ជាសមាជិកទៀត។ គាត់ចាត់តាំង ឡួន ហ្នឹងជាអ្នកយកឡានទៅដើរដឹកជនជាតិយួនហ្នឹង អត់មាននៅធ្វើការក្នុងឃុំទេ នៅក្នុងមន្ទីរស្រុក។

**ស៖** ខ្ញុំយល់អ្វីដែលលោកបាននិយាយ គឺថា ឡួន បានដើរប្រមូលប្រជាជនវៀតណាមនៅក្នុងឃុំជាងទង។ <ប៉ុន្តែ តើ ឡួន ជាអ្នកដើររកចាប់ជនជាតិវៀតណាមនៅឃុំជាងទង ឬក៏ឃុំហ្នឹងមានស្វ័យភាពចាប់ចង ហើយ>សម្លាប់<ជនជាតិវៀតណាម>ទាំងនោះដោយខ្លួនឯង?

**ឆ៖** បាទ អត់ដឹងដែរត្រង់ហ្នឹង ខ្ញុំដឹងថាតាចាយ ឲ្យឡួន យកឡានទៅដឹក មិនដឹងតាចាយហ្នឹងទទួលផែនការពីណា អត់បានដឹងទេ។ ហើយ ឡួន ហ្នឹងឃើញយកឡានទៅដឹកមែន ឡានអាយ៉ាម៉ុងវែង អាកង់ប្រាំបីដណ្តប់ហ្នឹង។

[១៥:៣៥:៣៧]

**ស៖** បាទ សូមអរគុណ ខ្ញុំជិតបញ្ចប់ហើយ។ លោកសាក្សី ខ្ញុំសូមឲ្យលោកមើលបញ្ជី<បី ដែល

លោកមាននៅបាត់ដំបង> គឺឯកសារ E3/4083។ ខ្ញុំនឹងឲ្យឯកសារERN តាមក្រោយ ឯកសារទី<២> គឺ E3/2615 ហើយឯកសារទី៣ គឺE3/2281។ ខ្ញុំនឹងឲ្យបុគ្គលិក<នៅអង្គភាពគាំពារជនរងគ្រោះ> ជួយ<លោក ជួយរកមើលឯកសារ។ ក្នុងខណៈពេលដែលយើងកំពុងរង់ចាំ ខ្ញុំសូមជម្រាបថា បញ្ជីទាំងនេះត្រូវបានធ្វើឡើងដោយឃុំ នៅក្នុងស្រុកត្រាំកក់ ហើយគេបានកំណត់អត្តសញ្ញាណគ្រួសារខ្មែរក្រោមនៅក្នុងឃុំនោះ ហើយគេបានបង្ហាញ>បុណ្យស័ក្តិ<សមាជិកគ្រួសារនីមួយៗមានក្នុងអំឡុងពេលរបប លន់ នល់។> បញ្ជីទាំងបីនេះ<មានកាលបរិច្ឆេទដូចគ្នា។ ខ្ញុំ>សូមចាប់ពីបញ្ជីទី១ មិនដឹងថាលោកមានឯកសារនៅមុខ<ហើយ ឬនៅ>ទេគឺ<>ឯកសារE3/4083 ខ្មែរគឺ00068033 បាទហើយរំលងទំព័រនេះទៅមើលត្រង់ទំព័រ 00068035, ជាអង់គ្លេស 00323966 ដល់68 និង 00323970 ដល់ 72 ហើយចុងក្រោយ ERN ជាភាសាបារាំង 00778870 ដល់ 71 និង 00778873 ដល់ 74។ លោកសាក្សីឥឡូវនេះលោកមានបញ្ជីឈ្មោះនៅចំពោះមុខលោកឬទេ?

**ឆ៖** ដឹងបញ្ជីស្អីផង អត់ដឹងផង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

លោកប្រធាននៅក្នុងពេលនេះ ខ្ញុំសូមការអនុញ្ញាតបង្ហាញទំព័រពាក់ព័ន្ធនៅលើអេក្រង់កុំព្យូទ័រ សូមការអនុញ្ញាត។

[១៥:៣៩:១១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** លោកសាក្សី ខ្ញុំសូមរៀបរាប់នូវខ្លឹមសារនៃឯកសារនេះជូនលោក <ហើយមើលថា វាជាឯកសារហ្នឹងដូចគ្នា ឬអត់។ បើសិនលោកឃើញឯកសារនោះនៅលើ អេក្រង់> គឺជាបញ្ជីមកពីឃុំស្រែរនោង <ធ្វើនៅថ្ងៃទី២៧>នៅខែមេសា ១៩៧៧ ហើយនៅលើបញ្ជីនេះ មានសមាជិកគ្រួសារខ្មែរក្រោម៣៧គ្រួសារ ត្រូវបានគេកំណត់ថាជា<អតីត>ទាហាននៅក្នុងរបប លន់ នល់។ ហើយនៅក្នុងបញ្ជីនេះក៏បញ្ជាក់អំពីឋានន្តរសក្តិរបស់ទាហានទាំងនោះផងដែរ។ បើលោកមិនមានបញ្ជីនៅចំពោះលោកទេ <លោកអាចមើលវាបានអេក្រង់>កុំព្យូទ័រ<>។ តើលោកមានបញ្ជីនេះនៅចំពោះមុខលោកទេ? <ខ្ញុំដឹងថា វាដូចជាពិបាកបន្តិច។>

**លោក ឯក ហឿន៖**

**ឆ៖** បញ្ជីហ្នឹងជាបញ្ជីស្អី? បើអត់ដែលមានផង។ បាទ អត់ដែលមានបញ្ជីអីនៅហ្នឹងដែផង អត់ដែលដឹងទេ។ មិនដឹងជាស្អី ព្រោះខ្ញុំអត់ចេះមើលផង។ ខ្ញុំអត់ដឹងរឿងមានបញ្ជី អត់បញ្ជីហ្នឹងផងហ្នឹង។

**ស៖** បាទ <ក្នុងគោលបំណងដើម្បីបំពេញគ្នា លើឯកសារដទៃពីរទៀត ជា>ឯកសារ<ដូចគ្នា>ដែលឃុំគុសបានរៀបចំឡើងនៅ<ថ្ងៃទី២៩> ខែមេសា ១៩៧៦ គឺឯកសារ E3/2615 និងឯកសារ<ចុងក្រោយ>មួយទៀតរៀបចំឡើងដោយឃុំត្រពាំងធំជើង <មានលេខ E3/2281> ដែលកំណត់គ្រួសារខ្មែរក្រោមចំនួន៧៣គ្រួសារ នៅ<ថ្ងៃទី៤ ខែឧសភា>ក្នុងឆ្នាំ១៩៧៧។ តើលោកដែលធ្លាប់បានឃើញបញ្ជីបែបនេះទេ<>? ហើយលោកថា <លោកមិនដែលបានឃើញបញ្ជីទាំងអស់នេះទេ ហើយលោកក៏ថា មិនមានខ្មែរក្រោមនៅស្រុកត្រាំកក់នោះទេ ប៉ុន្តែនៅត្រង់នេះ បានបញ្ជាក់ថា ខាងឃុំបានធ្វើ>បញ្ជី<ខ្មែរក្រោម។> តើលោក<ចង់កែប្រែអ្វីដែលលោកបាននិយាយពីមុន ឬ>នៅរក្សាចម្លើយរបស់លោកដដែលដែរឬទេថា តាមដែលលោកដឹង មិនមានខ្មែរក្រោមរស់នៅក្នុងស្រុកត្រាំកក់នោះ?

**ឆ៖** បាទ ភ្លេចអស់ហើយ អត់មានចាំពាក្យអស់ហ្នឹងទេ ដឹងពី -- និយាយពីអង្កាល់ អត់ដែលនិយាយ ហើយភ្លេចការចងចាំទាំងអស់ មកពីខ្ញុំឈឺធ្ងន់ពេក ទើបវាភ្លេចបាត់អស់ទៅ។

[១៥:៤២:១៤]

**ស៖** ខ្ញុំមិនបាននិយាយថាដូច្នេះទេ ក៏ប៉ុន្តែមានឯកសារបង្ហាញថា ថ្នាក់ឃុំគេអ្នករៀបចំបញ្ជីគ្រួសារខ្មែរក្រោម។ តើលោកអះអាងថាលោកមិនដែលឃើញបញ្ជីនេះទេ? ហើយតើលោកនៅតែអះអាងថា លោកមិនដែលឃើញមានគ្រួសារខ្មែរក្រោមទេ<>នៅក្នុងស្រុកត្រាំកក់ក្នុងរបបខ្មែរក្រហម?

**ឆ៖** បាទ បញ្ហាហ្នឹង អត់ដែលទាំងអស់។ អត់ដែលដឹង អត់ដែលឮគេនិយាយផង អត់ដែលគេធ្វើបញ្ជីធ្វើអី គេមកប្រាប់យើងឲ្យដឹងឲ្យឮ អត់ដែលដឹងទេ។ ប្រជាជនឯណាដែលប្រាប់អីចឹង១ឲ្យដឹង។

**ស៖** លោកសាក្សី ខ្ញុំសូមអរគុណចំពោះពេលវេលារបស់លោក ដែលលោកបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ហើយជូនតួនាទីនេះ ទៅដល់ខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក វ៉េន ពៅ៖**

សូមគោរពលោកប្រធាន ក្នុងនាមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំអនុញ្ញាតពីលោកប្រធាន អនុញ្ញាតឲ្យលោកស្រី ទី ស្រ៊ីនណា ដើម្បីសួរសំណួរដល់សាក្សីរូបនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ អនុញ្ញាត។ សូមអញ្ជើញលោកស្រីមេធាវី!

[១៥:៤៣:៤៦]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ជាដំបូងនាងខ្ញុំសូមគោរពលោកប្រធាន លោកៗចៅក្រម និងអង្គសវនាការទាំងមូល។ និងសូមជម្រាបសួរលោកសាក្សី នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានសំណួរមួយចំនួន និងធ្វើការតាំងជូនទៅលោក។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ជម្រាបសួរលោក អ៊ុល ហឿន លោកឮៗខ្ញុំសួរដែរឬទេ? សួរស្តី លោក អ៊ុល ហឿន?

**លោក ឯក ហឿន៖**

**ឆ៖** បាទ

**ស៖** មុននឹងខ្ញុំធ្វើការតាំងសំណួរ នាងខ្ញុំសូមធ្វើការបញ្ជាក់ចំណុចមួយចំនួន ដែលកាលពីព្រឹកមិញ សហព្រះរាជអាជ្ញាគាត់បានសួរទៅលោក ហើយនិងលោកបានធ្វើការឆ្លើយមួយចំនួនធំ។ លោកបានលើកឡើងថា នៅពេលដែលប្រជាជនជម្លៀសពីទីក្រុងភ្នំពេញទៅវត្តចំប៉ាលើក លោកបានលើកឡើងថា មេភូមិ និងមេឃុំទាំងអស់ គឺត្រូវបានគេចាត់ឲ្យត្រៀមក្នុងការទទួលប្រជាជនថ្មី។ សំណួររបស់ខ្ញុំចង់សួរថា តើនរណាជាអ្នកចាត់ឲ្យមេភូមិ ឬក៏មេឃុំក្នុងការទទួលប្រជាជនថ្មីនោះ? តើលោកចាំបានដែរឬទេ?

**ឆ៖** *(ឮមិនច្បាស់)* មើលអក្សរអត់រួច ឲ្យចូលមកធ្វើដែរ។

**ស៖** អត់ទោសលោក ឯក ហឿន តើលោកស្តាប់សំណួរខ្ញុំបានដែរឬទេ? បើសិនជាស្តាប់មិនបាន ខ្ញុំនឹងធ្វើការតាំងសំណួរសាជាថ្មី។

**ឆ៖** បាទ ស្តាប់បានហើយ ប៉ុន្តែចង់និយាយ គាត់មានប្រសាសន៍ថែមទៀតទៅ ខ្ញុំឈប់ទៅ។ បាទ

ផែនការរៀបចំឲ្យប្រជាជនដែលជម្លៀសពីជុំទិសមកនៅចំប៉ាលើកហ្នឹង គឺមានផែនការចេញពីស្រុក។ ស្រុកប្រាប់ថា ឲ្យមេភូមិទាំង១៥ភូមិធ្វើបញ្ជី១០០ជាមួយថ្មីហ្នឹង ត្រូវចែកប៉ុន្មានអីប៉ុន្មានក្នុងមួយភូមិៗហ្នឹង។ ធ្វើគ្នាចែកដាច់សព្វគ្រប់អស់ហើយ ហើយឲ្យគេ មេឃុំហ្នឹងរៀបចំបាយកញ្ចប់គ្រប់ៗផ្ទះទាំងអស់ សុំប្រជាជន។ យកទៅទទួលបាយគេគ្រប់មួយអាទិត្យ ទទួលបាយកញ្ចប់។ ហើយធ្វើបញ្ជីបានបែងចែកហើយមួយឃុំៗបានប៉ុន្មាន មេឃុំហ្នឹងចប់បែងចែកហើយ គេនាំឃុំហ្នឹងឲ្យទៅទទួលមនុស្សហ្នឹងនាំចេញមកភូមិមកស្រុករបស់ឃុំហ្នឹងវិញ។ ហ្នឹងរឿងហ្នឹងវាសម្រេចមេស្រុក ហើយប្រធានមន្ទីរ ឈ្មោះ សោម ដន ទៅចាត់ចែងក្នុងហ្នឹង ទៅចាត់ចែងក្នុងចំណោមប្រជាជនដែលគេប្រមូលមកទុកចំប៉ាលើកហ្នឹង សោម ដន ហើយ ដែក ស៊ីម ហ្នឹងគេធ្វើបញ្ជីពីរនាក់ហ្នឹងបែងចែកជាមួយឃុំ។ អាហ្នឹងសូមជម្រាបខ្លីប៉ុណ្ណឹងទេ។

[១៥:៤៧:២០]

**ស៖** សូមអរគុណ នាងខ្ញុំសុំបន្តសំណួររបស់នាងខ្ញុំទៀត។ នាងខ្ញុំសុំសួរថា តើក្រោយពីការចាត់ចែងឲ្យទទួលប្រជាជន តើគេមានចាត់ចែងឲ្យធ្វើអ្វី គេមានចាត់ចែងឲ្យមេភូមិ មេឃុំធ្វើអ្វីផ្សេងទៀតទៅលើប្រជាជនថ្មីទាំងនោះដែរឬទេ?

**ឆ៖** បាទ គេប្រាប់ឲ្យធ្វើរោងចាស់ ឲ្យនៅរកជម្រកឲ្យគេនៅ ហើយចែកស្រូវចែកអង្ករឲ្យគេហូប គេហូបនៅតាមក្រុម ចែកជាក្រុមជាពួកជាមួយគ្នាហ្នឹង។ ចែកចាត់ចែងគ្រប់ការងារគ្រប់ចំណុចទាំងអស់ហ្នឹង។

**ស៖** សូមអរគុណ ខ្ញុំសុំធ្វើការបន្តសំណួរនាងខ្ញុំទៀត។ លោកបានលើកឡើងថា មានការផ្ដល់ផ្ទះសម្បែងឲ្យប្រជាជន។ តើផ្ទះសម្បែងដែលគេផ្ដល់ឲ្យប្រជាជននៅក្នុងអំឡុងពេលហ្នឹងយ៉ាងម៉េចដែរលោក? មានភិនភាគយ៉ាងដូចម្ដេច? តើការ -- ផ្ទះសម្បែងហ្នឹងអាចទទួលយកបានដែរឬទេ ឬមួយក៏គ្រាន់តែជាការសាងសង់ជាខ្ទម ឬក៏ជារោងៗដែលធ្វើអំពីយកឈើប្រក់ដើម្បីធ្វើជារោងអីអ៊ីចឹង តើហ្នឹងគឺខាងភូមិឃុំហ្នឹងគេជាអ្នករៀបចំទុកជាស្រេចដើម្បីឲ្យប្រជាជនទៅដល់នៅតែម្ដង ឬមួយក៏តម្រូវឲ្យប្រជាជនទៅដល់គាត់ធ្វើខ្លួនឯងថែមទៀត ឬក៏ម៉េច? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ឥឡូវហ្នឹងបញ្ហាហ្នឹងអត់ពិបាកទេ ពីព្រោះប្រជាជនដែលទៅនៅភូមិឃុំជាមួយប្រជាជនហ្នឹង គឺដូចថាក្នុងដីរំដោះគេហ្នឹង គេជម្លៀស គេឲ្យពួកដែលនៅក្នុងដីរំដោះហ្នឹងចេញទៅធ្វើការស្រុកក្រៅ ហើយផ្ទះគេនៅទំនេរអត់មានមនុស្ស គឺចេញអស់ពាក់កណ្ដាលហើយ

នៅមួយៗទេ ហើយដល់ប្រជាជនថ្មីទៅ គេឲ្យទៅនៅតាមផ្ទះចាស់ៗហ្នឹង ចាស់ៗដែលមានសល់ទំនេរ អត់មានមនុស្សនៅ ផ្ទះណាក៏មនុស្សនៅៗដែរ។ គេឲ្យទៅនៅតាមផ្ទះចាស់ៗហ្នឹង មានផ្ទះធំអ៊ីចឹងនៅពីរគ្រួសារទៅ ផ្ទះតូចនៅមួយគ្រួសារអ៊ីចឹងទៅ ។រួចអ្នកណាចេញទៅធ្វើការក្រៅក្នុងជួរបង ប៉ុល ពត ហ្នឹងគេចាត់តាំងឲ្យទៅធ្វើការងារក្រៅស្រុកអស់ទៅ អាហ្នឹងបានផ្ទះចាស់ៗហ្នឹងនៅហើយ។

**ស៖** សូមអរគុណលោក ចុះរបបអាហារដែលផ្ដល់ឲ្យពួកគាត់យ៉ាងម៉េចដែរ?

[១៥:៤៩:៥៤]

**ឆ៖** បាទ ហ្នឹងខ្ញុំជម្រាបប្រសាសន៍កាលខាងដើមហើយថា ចិន ៧៥ រំដោះទូទាំងប្រទេស គឺចិនបើកអង្ករ បើកសម្ភារៈសព្វមុខទាំងអស់មកផ្ដល់ឲ្យប្រជាជនដែលគេជម្លៀសចេញពីទីក្រុង។ គឺខ្ញុំ គុកលន់ហើយដាល់អង្ករ តែឯងហ្នឹង ម្នាក់ហ្នឹង អង្ករឡានតូចហ្នឹង អាទែរគេហ្នឹង៣០បាវ លើកម្នាក់ឯង លីម្នាក់ឯងទម្លាក់។ អាហ្នឹង *(ឮមិនច្បាស់)* យកអង្ករហ្នឹងចែកតាមមកហៀរហូរ ដឹងថាប្រជាជនចាស់ក៏ច្រើន អាប្រជាជនថ្មីក៏ច្រើន នៅឃុំលាយបូរងាប់រលីងអ្នកថ្មី អត់អីហូប ចិនឲ្យមកអង្ករស្រូវសាលីហ្នឹងគ្រាប់ធំជាងគ្រាប់ពោត ហើយហូបហើយនៅតែអាចម៍ៗឆ្កែមិនមែន អាចម៍មនុស្សមិនមែន ប៉ុន្តែអាឆ្កែអត់ស៊ីអាចម៍ហ្នឹង មនុស្សឃុំលាយបូរមនុស្សថ្មីហ្នឹងរាប់រយ ងាប់អស់៥០០ ងាប់អស់រលីង ស៊ីបាយស្រូវសាលី។ អាចម៍ឆ្កែ ឆ្កែអត់ស៊ីអាចម៍ហ្នឹងទេ។

**ស៖** សូមអរគុណលោកដោយសារតែពេលវេលារបស់នាងខ្ញុំនៅមានខិតខ្លី អ៊ីចឹងខ្ញុំសុំឲ្យលោកជួយឆ្លើយខ្លីៗ។ ខ្ញុំសូមបញ្ជាក់បន្ថែមទៀតថា តើចិនដែលផ្ដល់អង្ករឲ្យហ្នឹង គេផ្ដល់អង្ករឲ្យប្រជាជននៅក្នុងសហករណ៍ទាំងមូលហ្នឹង តើគេផ្ដល់ឲ្យជារៀងរហូតចាប់តាំងពីរំដោះបាន រហូតដល់ចប់របបខ្មែរក្រហម ឬមួយក៏ទើបមានតែម្ដងហ្នឹងទេ?

**ឆ៖** បាទ សូមជម្រាប គេផ្ដល់រយៈមួយឆ្នាំ ពី៧៥ថ្ងៃរំដោះហ្នឹងរហូតដល់៧៦ គេផ្ដល់ដល់ពាក់កណ្ដាលឆ្នាំទៀត។ មួយឆ្នាំកន្លះគេផ្ដល់ឲ្យ ខ្លាចយើងរកអីឲ្យប្រជាជនថ្មី-ចាស់ហ្នឹងហូបមិនបាន គេផ្ដល់ឲ្យដល់មួយឆ្នាំកន្លះ។ ខ្ញុំលីអង្ករស្គមខ្លួនមួយឆ្នាំកន្លះហ្នឹង។ គេយកផ្ដល់ឲ្យអ្នកជម្លៀស នៅអាអ្នកប្រជាជនចាស់ទាំងអស់ហ្នឹងហូបទាំងអស់គ្នាហ្នឹង។

[១៥:៥១:៥៣]

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរបន្តទៀតទាក់ទងនឹងលោកលើកឡើងអំពីកង់ប្រវត្តិសាស្ត្រកិនឲ្យហ្នត់ ត្រូវកម្ទេច។ អ៊ីចឹងខ្ញុំចង់សួរក្នុងៗពាក្យនេះមានន័យដូចម្ដេចដែរលោក?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំឮតែលេខាស្រុក ដូចយាយខុម ហ្នឹងគាត់ឲ្យតែធ្វើមីទិ្ទង គាត់និយាយថា "ពួកសក្តិ-ភូមិនាយទុន ប្រតិកិរិយាប្រហារអត់ឲ្យសល់ម្នាក់។ ពួកអានេះគឺត្រូវកង់ប្រវត្តិសាស្ត្រកិនកម្ទេចហើយ។ ត្រូវបោសសម្អាតឲ្យអស់ កម្ទេចទាំងរបបកម្ទេចទាំងបុគ្គល"។ គេថាតែអ៊ីចឹង គេធ្វើមីទិ្ទង។ ហើយខ្ញុំស្មានថាគេថាហ្នឹងថាសំដៅប្រជាជនមន្ត្រីអ្នករាជការជំនាន់សម្តេច សីហនុ មិនដឹង គេថានៅក្បែរៗផ្ទះឯង --

**សៈ** អត់ទោសលោក ខ្ញុំសូមធ្វើការបន្តសំណួរមួយទៀត។ ចង់សួរថាតើពាក្យដែល "កង់ប្រវត្តិសាស្ត្រ"ហ្នឹង តើ យាយខុម ហ្នឹងគាត់បង្កើតពាក្យហ្នឹងដោយខ្លួនឯង ឬមួយក៏ពាក្យហ្នឹងចេញមកពីខាងណាផ្សេង ចេញមកពីប្រភពណាផ្សេង?

**ឆ៖** អត់បានដឹងទេ ព្រោះថាឲ្យតែឃើញធ្វើមីទិ្ទង គាត់និយាយតែអ៊ីចឹង មិនដឹងគាត់ទទួលផែនការពីណា? អត់ដឹង។

**សៈ** សូមអរគុណ។ ហើយខ្ញុំសូមបញ្ជាក់ទៅលើចំណុចមួយទៀត ដែលលោកបានលើកឡើងអំពី តាម៉ុក។ លោកលើកឡើងថា បានធ្វើ មកធ្វើមីទិ្ទងចំនួនបីដង ហើយទាក់ទងជាមួយនឹងមីទិ្ទងដែលលើកអំពីការជីកប្រឡាយ។ អ៊ីចឹងខ្ញុំចង់សួរថានៅក្នុងសហករណ៍ត្រាំកក់ហ្នឹង គេមានតម្រូវឲ្យប្រជាជនទៅធ្វើការជីកប្រឡាយអ៊ីចឹងមែនទេលោក?

**ឆ៖** គាត់ចប់នៅហ្នឹង?

**សៈ** ចាស?

**ឆ៖** ចប់ ខ្ញុំឆ្លើយ។

**សៈ** សូមឆ្លើយលោក សូមឆ្លើយ!

[១៥:៥៣:៥៦]

**ឆ៖** បាទ ប្រជាជនក្នុងស្រុកត្រាំកក់ទាំងមូល គឺទាំងស្រីទាំងប្រុសរួមគ្នាទប់ទំនប់ជីកប្រឡាយជីកទាំងយប់ជីកទាំងថ្ងៃ។ ថ្ងៃណាក៏បុណ្យៗ បុណ្យហើយគេដោតទង់ក្រហម គេថាទង់ក្រហមនេះគឺមានទាំងខាងមុខ មានទាំងសមរភូមិខាងក្រោយ។ ខាងមុខបង្ហូរឈាមដោយយកទង់ទៅរងគ្រាប់ ខាងក្រោយគឺបង្ហូរឈាមដូចគ្នា។ ទង់ក្រហមនេះគឺទង់ប្រយុទ្ធ លើកដីធ្វើទំនប់ធ្វើប្រឡាយទាំងយប់ទាំងថ្ងៃទាំងអស់គ្នា។ យប់ទល់ម៉ោងប្រាំបួន ហើយយប់ហ្នឹងទល់ម៉ោងប្រាំបួនបានហូបបាយហើយ ហូបបាយរួម ហើយម៉ោងប្រាំបួនត្រូវលើកៗបានតែមួយម៉ោងទេ ដល់ម៉ោងមកដេកវិញមក។ ថ្ងៃធ្វើទល់ម៉ោងដប់

មួយកន្លះ បានមកហូបបាយ។ មកហូបបាយហើយ អត់បានសម្រាកទេ មកដល់ហូបបាយអ្នកខ្លះអត់បានហូប ដល់ម៉ោងមួយទៀតបានៗហូប។ អាហ្នឹងកាលជំនាន់ប៉ុល ពត ហ្នឹង ពិបាកវេទនាមហាពិបាកហើយ។ អត់ហ៊ានលាន់មាត់ទេ តែមាត់ទំនាស់សហករណ៍។ បាទ សូមចប់ត្រឹមហ្នឹង។

**ប្រធានអង្គជំនុំ៖**

បើកៗក្បាលមីក្រូ!

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** សូមអរគុណ ខ្ញុំសូមសួរបន្តទៀត។ ខ្ញុំចង់សួរថាការជីកប្រឡាយនេះគឺគេតម្រូវឲ្យតែប្រជាជនថ្មី ឬប្រជាជន១៧មេសា ទៅជីក ឬក៏មានលក្ខខណ្ឌផ្សេងពីនេះ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ អត់មានប្រជាជនថ្មី អត់មានចាស់ ទាំងចិន ទាំងយួន ទាំងចាម ទាំងជ្វា ឲ្យតែមានជាមនុស្ស លោកសង្ឃជីកទាំងអស់គ្នា។ ហើយលោកសង្ឃយូរៗលែងមាន លោកផ្សឹកធ្វើប្រឡាយតែទាំងអស់គ្នាអ៊ីចឹងទៅ។ អត់ថាខ្មែរ ថាចិន ថាចាម ថាយួន ថាជ្វាអីទេ ធ្វើទាំងអស់។ ទំនប់ខ្ទបត្របែកហ្នឹងធ្វើអ៊ីចឹង។

[១៥:៥៥:៥០]

**ស៖** សូមអរគុណ ខ្ញុំសូមធ្វើការបន្តសំណួរទៀត។ ទាក់ទងទៅនឹងការជីកប្រឡាយនេះ ឆ្លងតាមការសង្កេតរបស់លោក ខ្ញុំចង់សួរលោកថា តើកន្លងមកមានដែលមានការធ្វើទារុណកម្មទៅលើប្រជាជនដែលគាត់មានការបាក់កម្លាំងនៅក្នុងការជីកប្រឡាយ ឬមួយក៏ការសែងរបស់គាត់មិនទៅមុខសែងដី រែកដីអីរបស់គាត់ហ្នឹងមិនទៅមុខ។ សួរថាតើដែលមានការធ្វើទារុណកម្មទៅលើប្រជាជនទាំងនោះដែរឬអត់ នៅក្នុងអំឡុងពេលនោះ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ជំនាន់ហ្នឹងអត់ទាន់មានធ្វើបាបទេ អ្នកជីកធ្វើទំនប់ លើកប្រឡាយហ្នឹង អត់មានធ្វើបាបប្រជាជនទេ។ ប្រជាជនលើកដី អាខ្លះ ធ្លាក់ក្រសាល់ក្តិត បិទលែងជិតនៅទល់ខោនៅហ្នឹងក៏អត់ គេអត់ថាអីដែរ។ ហើយអ្នកដែលធ្លាក់ក្រសាល់គូទហ្នឹងក៏អត់ហ៊ានលាន់មាត់ទេ ធ្លាក់រហូតទាល់ស្លាប់។ រែកទៅវាធ្លាក់ក្រសាល់គូទ ហើយហូបអត់គ្រប់គ្រាន់ បបររាវៗ។ មានតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ខ្ញុំសូមធ្វើការបញ្ជាក់ទៅលើចំណុចមួយទៀតពាក់ព័ន្ធជាមួយនឹង លោក

បានលើកឡើងអំពីប្រជាជនទាំងមូលដ្ឋាន ទាំងប្រជាជនថ្មី គឺមានសិទ្ធិស្មើគ្នា និងត្រូវគោរពគ្នាទៅវិញទៅមក។ នៅក្នុងចំណុចមួយនោះលោកបានលើកឡើងថា ចំពោះអ្នកដែលចម្រាញ់ គឺគេចេះតែដើរចម្រាញ់ស៊ើបអង្កេតទៅ អ្នកដែលមានសិទ្ធិស្មើគ្នាគឺគេមិនប្រកាន់គ្នាទៅវិញទៅមកទេ។ អ៊ីចឹង ខ្ញុំចង់សួរលោក ថាតើអ្នកដែលដើរចម្រាញ់ហ្នឹងគាត់ចុះស៊ើបអង្កេតជារៀងរាល់ថ្ងៃ ឬក៏យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ អាហ្នឹងខ្ញុំឃើញហ្នឹងភ្នែកហើយ ដូចថាប្រជាជនថ្មីទៅនៅផ្ទះខ្ញុំអ៊ីចឹង។ ហើយតែយប់ឡើងគេចុះទៅលបស្តាប់ក្រោមផ្ទះហើយ។ តែយើងនិយាយទៅវាចូលរឿងគេ ប៉ះពាល់នយោបាយគេម្តង ពីរដង បីដង គេចាប់ហើយ។ គេចាប់ហើយអត់មានដាក់តុលាការទេទៅហើយ។ អាហ្នឹងសូមជម្រាបអ៊ីចឹង។

[១៥:៥៨:០៥]

**ស៖** ឆ្លងតាមបទពិសោធន៍របស់លោក ខ្ញុំចង់សួរលោកថា តើអ្នកណាជាអ្នកកំណត់ឲ្យមានអ្នកដើរចម្រាញ់ដូច្នេះ? តើគាត់មកពីខាង -- អ្នកដែលដើរចម្រាញ់ហ្នឹងគាត់មកពីខាងណាដែរ? ថ្នាក់ណាជាអ្នកបញ្ជូនគាត់មក ឬមួយក៏គាត់ធ្វើការងារជាអ្នកដើរចម្រាញ់ស៊ើបអង្កេតហ្នឹង ដោយស្ម័គ្រចិត្តដោយខ្លួនឯង?

**ឆ៖** បាទ អាហ្នឹងខ្ញុំជម្រាបត្រង់ហើយនេះ! អត់លាក់ទេ ព្រោះខ្ញុំជាអ្នករងគ្រោះ ខ្ញុំឃើញ ខ្ញុំអត់លាក់បាំងទេ។ គឺកងស្រុកហ្នឹងតែម្តង គេចែកកម្លាំង តែយប់ឡើង គេចែកកម្លាំងគេដើរដេកក្រោមគ្រែក្រោមផ្ទះគេហ្នឹង។ ស្តាប់សូរ យប់ឡើងគេនិយាយអីៗ វាដឹងទាំងអស់។ តែដឹងហើយ គឺគេរាយការណ៍ឲ្យស្រុក ស្រុកសម្រេចឲ្យចាប់ គឺចាប់ហើយ។

**ស៖** សូមអរគុណ ខ្ញុំសូមធ្វើការបន្តសំណួរទៀតទាក់ទងនឹងលោកលើកអំពី សេ.អ៊ី.អា និង កា.ហ្សេ.បេ។ ខ្ញុំចង់សួរថានៅក្នុងស្រុកត្រាំកក់ទាំងមូលហ្នឹងអ្នកដែលមាននិន្នាការសេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងត្រូវបានគេចាប់ តើការចាប់ហ្នឹងមានទំហំ ឬក៏កម្រិតប៉ុនណាដែរ ដូចថាចំនួននៃការចាប់ហ្នឹងវាមានច្រើនកម្រិតណាលោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** បាទ ឮគេថា កា.ហ្សេ.បេ ហ្នឹងគឺគេថា គិញយួន គិញសូវៀត។ ហើយគេថា សេ.អ៊ី.អា ហ្នឹង គឺគិញអាមេរិកាំង។ ហើយតែគេចាប់ហើយអត់មានយកមកឲ្យស្រុក យកទៅណាទេ គឺគេយកឲ្យអង្គការ ខុម តែម្តង។ លោកយាយ ខុម យកទៅបង្រៀនឯណាទៅ។

**ស៖** ចាស អ៊ីចឹង សូមអរគុណលោក។ ខ្ញុំសូមបន្តសមណ្ឌួរទៀត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

ឲ្យមានការឃ្លាតបន្តិច បន្ទាប់ពីសាក្សីឆ្លើយចប់ ព្រោះបើកាលណាអ៊ីចឹងបកប្រែអត់ទាន់ទេ។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ខ្ញុំសូមសួរបញ្ជាក់ទៀតថា តើការចាប់ សេ.អ៊ី.អា និង កា.ហ្សេ.បេ នេះគឺគេចាប់ជាលក្ខណៈចំហ ឬមួយក៏ការចាប់ហ្នឹងគេធ្វើឡើងដោយលួចលាក់?

**លោក ឯក ហឿន៖**

**ឆ៖** បាទ គេចាប់អត់ចំហទេ យប់ឡើងគេដើរចាប់បាត់ៗទៅ យើងអត់បានដឹងដែរហ្នឹង ព្រឹកឡើងបាត់មនុស្សអស់ហើយ។ ហ្នឹងតែប៉ុណ្ណឹង។

[១៦:០០:១៧]

**ស៖** តើប្រជាជនដែលរស់នៅក្នុងសហករណ៍ទាំងអស់មូលហ្នឹងដឹងអំពីការចាប់នេះទាំងអស់គ្នាដែរ ឬក៏ដោយបុគ្គលណាដែលដឹងក៏ដឹងទៅ អ្នកណាដែលមិនដឹងគឺមិនដឹង ឬមួយក៏យ៉ាងម៉េចដែរ? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេអំពីស្ថានភាពមួយនេះ?

**ឆ៖** បាទ ពេលដែលគេចាប់ ដល់បាត់ព្រឹកឡើង ក្នុងក្រុមយើងហ្នឹងបាត់មនុស្ស។ ដល់បាត់មនុស្ស ខ្សឹបសួរគ្នាថាគេចាប់ហើយ គេចាប់ទៅបាត់ហើយ។ អ៊ីចឹងយើងដឹងខ្សឹបៗគ្នាហ្នឹង ដល់តែថ្ងៃក្រោយទៅបាត់គេក្នុងក្រុមនោះ ខ្សឹបសួរគ្នាគេទៅណា? គេថាគេនាំទៅបាត់ហើយ។ អាហ្នឹងយើងដឹងតាមលាក់បាំង លាក់សម្ងាត់ អត់មានដែលនិយាយពេញទំហឹងទេ ខ្សឹបខ្សៀវសួរគ្នាទៅណាមកណា ដល់សួរទៅដឹង។

**ស៖** សូមអរគុណ។ លោកខ្ញុំសូមសួរថាតើកត្តានៃការបាត់ខ្លួននេះ វាជាកត្តាមួយដែលនាំឲ្យមានការបំភ័យដល់ស្មារតីប្រជាជននៅក្នុងស្រុកត្រាំកក់ទាំងមូលដែរទេ ឆ្លងតាមការសង្កេតរបស់លោក?

**ឆ៖** ប្រជាជនមិនថាមេឃុំ មិនថាចៅហ្វាយស្រុក មិនថាមេភូមិទេ យប់ឡើងខ្សឹបខ្សៀវគ្នា ថាខ្លាចត្រជាក់ខ្លួនអស់ហើយ បើគេចាប់ដល់ថ្នាក់ហ្នឹង យើងធ្វើម៉េច ស៊ីបាយលែងចូល ផឹកទឹកលែងផឹក យើងភ័យខ្លាចទាំងអស់គ្នា ត្រជាក់ខ្លួនទាំងអស់គ្នា គេចាប់នោះចាប់ពេកទៅ។ អាហ្នឹងរឿងហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំសូមធ្វើការបន្តសំណួរទៀត ទាក់ទងទៅនឹងការបោសសម្អាតខ្មាំងជួរបក្ស

វិញ។ តើនៅក្នុងអំឡុងពេលនុ៎ង មានការបោសសម្អាតខ្មាំងជួរបក្សទេ ក្រៅពីការចាប់ក្រុម សេ.អ៊ី.អា, កា.ហ្សេ.បេ នោះ?

**ឆ៖** បាទ មានដូចតែគ្នាក្នុងក្រុមបក្សកុម្មុយនីស្តហ្នឹង មានច្រើន ប៉ុន្តែគេចាប់ គេៗអត់ដែលឲ្យយើងដឹងទេ គេថាឲ្យទៅរៀនសាលានេះសាលានោះ ហើយបុគ្គលហ្នឹងក៏ទៅរៀនតាមគេ តែគេទៅភ្ជង់កាំភ្លើងសាលាហ្នឹង គេទៅចាប់នៅសាលាហ្នឹង យើងអត់បានដឹងទេ។ ប៉ុន្តែគេខ្សឹបខ្សៀវដឹងតែទាំងអស់ហ្នឹង។

[១៦:០២:១៩]

**ស៖** សូមអរគុណ។ សូមសួរបន្តទៀតទាក់ទងទៅនឹងលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំវិញ។ ខ្ញុំចង់សួរលោកថាតើនៅក្នុងស្រុកត្រាំកក់ហ្នឹងមានការរៀបអាពាហ៍ពិពាហ៍ដែរឬទេ នៅក្នុងអំឡុងពេលដែលលោកនៅស្រុកត្រាំកក់នោះ?

**ឆ៖** បាទ មានរៀបចំអាពាហ៍ពិពាហ៍ទៅ វាអត់ត្រូវជាគូភរិយាគេ។ ដល់តែអ៊ីចឹងទៅគេសុខចិត្តអត់យកគ្នា ដល់តែអត់យកគ្នា អាប្រុសសុទ្ធតែដុំស្រែង ហើយអត់ -- មីស្រីនោះវារូបគេស្អាត ហើយដល់អ៊ីចឹងមីស្រីអត់យក យកមីស្រីនោះយកទៅដាក់នៅជិតកន្លែងវិមានសពខ្មោចយុទ្ធជនដែលស្លាប់រាប់ម៉ឺនរាប់សែនហ្នឹង យកទៅដាក់ឲ្យខ្លាច ឲ្យព្រមយកប្តី។ ដល់តែហើយ អាប្តីទៅក៏មីហ្នឹងខ្លាចរយះរយាយអស់ អត់យករហូតហ្នឹង វាខុសគូស្វាមីភរិយាគេ គេអត់ទទួល សុទ្ធតែក្រមរស្រែង គេអត់យករហូត។

**ស៖** ខ្ញុំសូមអរគុណ សូមសួរលោកបន្តទៀត។ ថាតើករណីនៃការដែលមិនមានការស្ម័គ្រចិត្តក្នុងការរៀបការនេះ កើតមានច្រើន -- មានច្រើនករណីដែរឬទេ នៅក្នុងសហករណ៍ត្រាំកក់នោះ?

**ឆ៖** បាទ គ្រប់តែសហករណ៍ហ្នឹង គ្រប់សហករណ៍ទាំងអស់។ រៀបចំអ៊ីចឹងដូចគ្នា ហើយមានទំនាស់អត់យល់ព្រម អត់ព្រមទទួលយកដូចគ្នា។ ទំនាស់ហ្នឹងវាច្រើនជាងអាឯកភាពគ្នាទទួលយកហ្នឹង។

**ស៖** អ៊ីចឹងមានការធ្វើទារុណកម្មទៅលើអ្នកដែលមិនឯកភាពយកគ្រួសារ តាមការកំណត់របស់អង្គការដែរឬទេ?

**ឆ៖** បាទ គេអត់ធ្វើទារុណកម្មទេ។ ដូចខ្ញុំនិយាយថា យកទៅដាក់ក្បែរវិមានកប់ខ្មោចឲ្យខ្លាចដល់ឲ្យខ្លាចទៅ ក្រែងលោគេហៅប្តីហ្នឹងឲ្យទៅនៅជាមួយគ្នា ដេកជាមួយគ្នា។ ដល់អ៊ីចឹងអាប្តីទៅប្រពន្ធខ្លាចរយះរយាយ អត់ចូលចុះទេ។ អត់យកដូចគ្នា កន្លែងណាក៏អ៊ីចឹងដែរ គ្រប់ឃុំទាំងអស់។

**ស៖** សូមអរគុណ ហើយខ្ញុំសូមបន្តសំណួរពាក់ព័ន្ធជាមួយនឹងព្រះពុទ្ធសាសនាវិញ។ នៅក្នុង

សហករណ៍ត្រាំកក់ហ្នឹង គេមានអនុញ្ញាតឲ្យប្រជាជនគោរពទៅលើសាសនាដែរឬទេលោកជំនាន់នុ៎ង?

[១៦:០៤:២៧]

**ឆ៖** បាទ ក្នុងជំនាន់ហ្នឹងឮសួរផង ប្លែកនុ៎ងគឺ តាជឹម គាត់អនុស្រុក ថាគណៈ -- តាខៀវ សំផន, តានួន ជា, តាប៉ុល ពត ហ្នឹងគេប្រជុំជាមួយ ហ៊ូ នឹម -- អ៊ំ! ហ៊ូ យន់ ហើយ ហ៊ូ យន់ ហ្នឹងជាអ្នកកែទម្រង់ភូមិឃុំ សហករណ៍។ ដល់អ៊ីចឹងគេប្រជុំថា “ឥឡូវយើងត្រូវបំបាត់សាសនា បំបាត់អំពើចាយលុយ បំបាត់អំពើអ្វូមអាមធ្វើមាត់អូចៗហ្នឹង បំបាត់បីបួនចំណុចហ្នឹង”។ ហើយ ហ៊ូ យន់, ហ៊ូ នឹម គាត់ថាឥឡូវយើងធ្វើអីចេះតែធ្វើទៅ អាធ្វើអាបំបាត់សាសនា អាបំបាត់អំពើអ្វូមអាម អាបំបាត់អំពើចាយលុយចាយកាក់អីហ្នឹង កុំអាលៗបំបាត់ យើងធ្វើអីចេះតែធ្វើទៅ ហើយយើងចេះតែលុបបំបាត់បន្តិចៗទៅ។ ដល់អ៊ីចឹង ប៉ុល ពត គេអត់សុខចិត្ត គេៗថា ហ៊ូ យន់ ហ្នឹងក្បត់ គេចាប់ ហ៊ូ យន់ ទាំងថ្ងៃទៅសម្លាប់បាត់ទៅ។ ដល់សម្លាប់បាត់ ក្រោយមកបានឮសួរបងថ្លៃខ្ញុំប្រាប់ថា ដល់ទៅចាប់ ហ៊ូ យន់ ទៅសម្លាប់ទៅ ពួកហ្នឹងស្ដាយក្រោយ បើធ្វើតាម ហ៊ូ នឹម អត់ខុសទេ យើងអត់ចាញ់គេទេ យើងឈ្នះហើយ ប៉ុន្ដែលុបបំបាត់សាសនា អាហ្នឹងហើយបានចាញ់។ តាជឹម ដើរត្អូញត្អែរស្ដាយ។

**ស៖** សូមអរគុណ ខ្ញុំសូមសួរលោកថាតើនៅក្នុង -- មុននឹងបន្ដិចលោកលើកៗឡើងអំពីការដឹកប្រឡាយហ្នឹងគឺមានការប្រើព្រះសង្ឃដែរ។ អ៊ីចឹង ពេលដែលគេប្រើព្រះសង្ឃឲ្យជីកប្រឡាយហ្នឹង គេប្រើទាំងស្បង់ចីពរ ឬមួយក៏គេឲ្យគាត់ ផ្សឹកគាត់សិន ឬក៏ម៉េច? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរទេ?

[១៦:០៦:០៨]

**ឆ៖** អត់ប្រើទាំងស្បង់ចីពរទេ។ ព្រះសង្ឃ គឺលោកស្ពាយតែហង្សៈមួយជាប់នឹងខ្លួននឹង ហើយរែកៗមួយក្រុមលោកសង្ឃហ្នឹង ដូចថា ៥០ម៉ែត្រហ្នឹង មានលោកសង្ឃឲ្យរែកត្រឹម៥០ម៉ែត្រ អត់ឲ្យមានប្រឡូកប្រឡាក់ជាមួយស្រីៗទេ សុទ្ធតែលោកសង្ឃទាំងអស់ ប៉ុន្ដែលោកសង្ឃអត់ពាក់ម្លូក អត់ពាក់ស្បង់ចីពរទេ ពាក់តែហង្សៈហ្នឹង។

**ស៖** ចុះលោកមានដែលដឹងទេថាតើព្រះសង្ឃចំនួនប៉ុន្មានដែលត្រូវគេផ្សឹកនៅក្នុងសហករណ៍ត្រាំកក់ទាំងមូល?

**ឆ៖** បាទ អត់ដឹងទេ ផ្សឹកម្ដងមួយ ម្ដងពីរ យូរៗអស់ទៅ បាត់អស់ទៅ។

**ស៖** បីសំណួរចុងក្រោយទៀត សូមអនុញ្ញាតលោកប្រធាន សូមសួរបីសំណួរទៀត ដោយសារ

ពេលវេលាដល់ហើយសូមអរគុណ។ ខ្ញុំសូមសួរលោកថាតើនៅក្នុងករណីដែលមានប្រជាជនស្លាប់ តើមានការជូនដំណឹងទៅសាច់ញាតិ ឬបងប្អូនរបស់ពួកគេដែរឬទេ ដើម្បីឱ្យពួកគេធ្វើ ប្រារព្ធធ្វើពិធីបុណ្យទានដល់អ្នកដែលស្លាប់នោះ? មានការជូនដំណឹងដល់សាច់ញាតិដែរឬទេជំនាន់ហ្នឹង?

**ឆ៖** បាទ សូមមានប្រសាសន៍ ជំនាន់ហ្នឹងបើថាទ័ពទៅច្បាំង ហើយទ័ពហ្នឹងស្លាប់ គេដឹងឪពុកម្ដាយ គេផ្ញើដំណឹងមកឱ្យឪពុកម្ដាយ អាហ្នឹងគេធ្វើបានតែប៉ុណ្ណឹងទេ ហើយចំពោះលុយកាក់បុណ្យទានអីអត់ឱ្យមានធ្វើអីទាំងអស់ គឺគ្រាន់តែឱ្យដំណឹងទេ។

[១៦:០៧:៣៦]

**ស៖** សូមអរគុណ ខ្ញុំសូមសួរពាក់ព័ន្ធជាមួយនឹងព្រៃខ្មោចកូនក្មេង។ ខ្ញុំឮលោកលើកពីខាងដើមមកថាមានក្មេងជាច្រើនក៏ត្រូវស្លាប់ដោយសារជំងឺកញ្ជ្រឹល និងមួយចំនួនទៀតគឺត្រូវគេ -- មានមនុស្សមួយចំនួនត្រូវគេបញ្ជូនយកទៅសម្លាប់នៅទីនោះ។ ឆ្លងតាមការសង្កេតរបស់លោក ខ្ញុំចង់សួរលោកថាតើអ្នកដែលគេយកទៅសម្លាប់នៅព្រៃខ្មោចក្មេងហ្នឹង គេភាគច្រើន គេចាប់ផ្ដើម -- ព្រៃខ្មោចក្មេងហ្នឹងចាប់ផ្ដើមមានការសម្លាប់ហ្នឹងនៅចាប់ពីឆ្នាំណាមកដែរលោក?

**ឆ៖** បាទ ខ្ញុំនិយាយពីរចំណុចអាកន្លែងហ្នឹង។ មុនឆ្នាំ៧០ កូនចៅប្រជាជនកើតអុត កើតកញ្ជ្រឹល គេយកទៅកប់ព្រៃខ្មោចកូនក្មេងហ្នឹង ព្រៃហ្នឹងព្រៃឡង់ នៅជាប់ផ្លូវព្រៃពីខាងលិច។ ចិញ្ចើមផ្លូវខាងកើត គឺភូមិៗប្រជាជនហៅថាក្រាំងតាចាន់ នៅជាប់នៅលិចកើតគ្នាប្រហែល៥០ម៉ែត្រទេ ខាងលិចផ្លូវ ខាងកើតផ្លូវ ផ្លូវកណ្ដាលគឺផ្លូវខ្សែបន្ទាត់មេព្រៃ។ ហើយកូនក្មេងគេយកកប់ហ្នឹង កប់នៅព្រៃឡង់ទេដល់ហើយគេកប់កូនក្មេង គេហៅថា "ព្រៃខ្មោចកូនក្មេង" អាហ្នឹងអ៊ីចឹងកើតអុត កើតកញ្ជ្រឹលយកទៅកប់គេខ្មោចកូនក្មេង។ ហើយដល់ជំនាន់ ប៉ុល ពត, គេ ប៉ុល ពត យកមនុស្សទៅសម្លាប់ៗនៅព្រៃខ្មោចកូនក្មេងហ្នឹង។ មន្ទីរយាយខុម នៅខាងជើងព្រៃខ្មោចកូនក្មេងហ្នឹងប្រហែល២០០ម៉ែត្រទេ។ ដល់តែយកប្រគល់ឱ្យយាយខុម ៗមានកម្លាំងគេការពារខ្លួនគេនៅជុំវិញខ្លួនគេនោះ គេប្រគល់ឱ្យយកទៅសម្លាប់ព្រៃខ្មោចកូនក្មេងហ្នឹង។ អាហ្នឹងបានខ្ញុំស្គាល់អាហ្នឹងវាកើតមុនខ្ញុំ។ ដល់កើតក្រោយអាក្រាំងតាចាន់ដែលមានជង្រុកហ្នឹង អាហ្នឹងកើតក្រោយ ខ្ញុំអត់ដឹង។

[១៦:០៨:១៧]

**ស៖** សូមអរគុណលោក។ ខ្ញុំចង់សួរសំណួរចុងក្រោយ ថាតើនៅពេលដែលប្រជាជនគេយកគាត់ទៅសម្លាប់នៅកន្លែងព្រៃខ្មោចកូនក្មេងហ្នឹង គេតម្រូវឱ្យគាត់កាប់រណ្ដៅកប់ខ្លួនឯង ឬមួយមានការ

រៀបចំទុករួចជាស្រេច?

**ឆ៖** បាទ សូមមានប្រសាសន៍ អារឿងយកទៅសម្លាប់ហ្នឹង អ្នកណាទៅកាប់រណ្ដៅឲ្យ កាប់វាយចោលលើដីនៅហាលថ្ងៃ ហាលភ្លៀងហ្នឹង នៅក្បាលអារាត់អារាយពេញដី ពេញផ្លូវហ្នឹង គ្មានអ្នកណាកប់ អ្នកណាធ្វើអីទេ ដូចសត្វធាតុអ៊ីចឹង អត់មានធ្វើរណ្ដៅ ធ្វើអីទេ។

**ស៖** តើអំឡុងពេលហ្នឹងមានចំនួនសាកសពគរច្រើនដែរឬទេ បើតាមការសង្កេតរបស់លោក?

**ឆ៖** បាទ អាហ្នឹងបើចង់ដឹង ទាល់តែទៅមើលក្នុងជង្រុក ជង្រុកហ្នឹងធំណាស់ ហើយប៉ុល ពត សម្លាប់តែក្បាលមនុស្សធំទេ។ ហើយដល់ពី៧៩ ពួកប៉ុល ពត ចាញ់យួន រត់ចូលព្រៃ ទាំងអម្រែក១ ទាំងគ្រួសារ យួនវាតត្បាតពេក ឃើញទាំងចាស់ ទាំងក្មេង បាញ់រះ ងាប់ទាំងក្មេង ទាំងចាស់ ទាំងក្បាលតូចក្បាលធំ យកមកដាក់ជង្រុកហ្នឹង។ ច្រើនណាស់ ៧៩ហ្នឹង។ ប៉ុល ពត សម្លាប់តែក្បាលធំទេ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណចំពោះការឆ្លើយដ៏ក្បោះក្បាយរបស់លោក។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៦:១០:៤២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ មុននេះខ្ញុំចង់បញ្ជាក់ពីរឿងពេលវេលាផងដែរ ហើយទី២ មេធាវីនាំមុខ -- មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីលើកអំពីការសង្កេតរបស់សាក្សី ហើយដែលនេះមេធាវីមិនបានបញ្ជាក់ពីមូលដ្ឋានថាតើសាក្សីបានឃើញ បានដឹង បានឮដោយរបៀបណាទេនូវអង្គហេតុដែលបានលើកឡើងមកនេះ គឺគាត់បាននិយាយនូវអ្វីតាមដែលគាត់ចង់និយាយ ហើយមិនបានបញ្ជាក់ពីមូលដ្ឋានដែលថា តើសាក្សីបានដឹង បានឮហ្នឹងនៅពេលណា? កើតឡើងដោយរបៀបណា? គឺអត់បានបញ្ជាក់ទេ។ បាទ សូមអរគុណ។

**លោកស្រី ទី ស្រ៊ីនណា៖**

នាងខ្ញុំសូមធ្វើការឆ្លើយតប លោកប្រធាន។ ដោយសារតែទី១ ខ្ញុំមើលទៅលើកត្តាពេលវេលាដែលពេលវេលា ខ្ញុំគិតថាវាជាចុងម៉ោងទៅហើយ ដូច្នេះហើយ ខ្ញុំមិនបានធ្វើការបញ្ជាក់ទៅដល់គាត់ទេ

ហើយម្យ៉ាងទៀត បើយើងពិនិត្យទៅលើពាក្យថា “សង្កេត”របស់គាត់ហ្នឹង ខ្ញុំសំដៅទៅលើសាក្សីរូបនេះ គាត់បានដឹងច្បាស់ហើយ គាត់បានឆ្លើយកាត់នៅក្នុងរបបហ្នឹង គាត់បានដឹង បានយល់ បានច្បាស់ហើយ នៅក្នុងរបបហ្នឹង បានខ្ញុំប្រើពាក្យ “សង្កេត” ព្រោះបើសិនជាគាត់មិនបានឆ្លងកាត់ទេ គាត់មិនអាចសង្កេតបានទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ។ អង្គជនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី០៨ ខែឧសភា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ឯក ហឿន តាមរយៈប្រព័ន្ធសោតទស្សន៍។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណ លោក ឯក ហឿន។ ដំណើរការស្ដាប់សក្ខីកម្មរបស់លោកក្នុងនាមជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងធ្វើតាមរយៈប្រព័ន្ធសោតទស្សន៍ ដូចបានធ្វើនៅថ្ងៃនេះដែរ ហើយនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ដូច្នេះ សូមលោកមានវត្តមានឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ លោកអាចសម្រាកបានហើយ លោក ឯក ហឿន។

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*